# ថ្ងៃទី០១ ខែ កុម្ភៈ ឆ្នាំ២០២២

## ពលករខ្មែរបន្តវិលត្រឡប់ពីប្រទេសថៃចូលស្រុកកំណើតវិញ ក្នុងពេលបុណ្យចូលឆ្នាំចិន

https://kbn.news/ January 31, 2022

**រាជធានីភ្នំពេញ៖** ខណៈបុណ្យចូលឆ្នាំចិនចូលមកដល់ កម្លាំងប៉ុស្តិ៍អូរអន្លក់សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យ ទទួលពលករវិលត្រឡប់មកពីប្រទេសថៃចំនួន២៨៣នាក់។ ការទទួលនេះធ្វើឡើងដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរៈ៨១៩ នៅថ្ងៃទី២៩ ខែ មករា ឆ្នាំ២០២២ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យ បានទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ។

បន្ទាប់ពីសាកសួរ, កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩ រួចចំនួន ២៨៣នាក់ ស្រី១០០នាក់.ក្មេង៥៧នាក់.ស្រី២៤នាក់ កម្លាំងយើងបានកត់ឈ្មោះរួច ក្រុមគ្រូពេទ្យធ្វើតេសរហ័ស ជាលទ្ធផលអវិជ្ជមានកូវីដ១៩ ទាំងអស់ ។ ពលករចំនួន ៤៨នាក់.ស្រី២១នាក់ ក្មេង៧នាក់.ស្រី៤នាក់ បញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន ។ ពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន២៣៥ន. ស្រី៧៩ន. ក្មេង៥០នាក់.ស្រី២០នាក់. ក្នុងនោះបានចាក់វ៉ាក់សាំងអោយក្មេងចាប់ពីអាយុ៥ឆ្នាំដល់១៨ឆ្នាំ ចំនួន ១៦.ស្រី៨នាក់. ក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ៕

## កងកម្លាំងអាជ្ញាធរ បន្តទទួលពលករ
## វិលត្រឡប់មកស្រុកវិញ ដែលភាគីថៃ បញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្រុកកំរៀង

https://gdlf-kh.com/ 2022/01/31/ Seng Chanmonirith ខេត្តបាត់ដំបង D819

នៅថ្ងៃទី៣១ ខែ មករា ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរៈ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យ បានទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង។

ពលករដែលវិលត្រលប់មកកម្ពុជាវិញ សរុបចំនួន២៣៣នាក់, ស្រី៨២នាក់ និងក្មេង៣៣នាក់ បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩រួចរាល់ ក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័ស និងជាលទ្ធផល គឺអវិជ្ជមានកូវីដ-១៩ ទាំងអស់។ ក្នុងនោះពលករដែលមានកាតចាក់វ៉ាក់សាំងចំនួន១៨៦នាក់ (ស្រី៦៥នាក់, ក្មេង៣០នាក់) ចំណែកពលករចំនួន៤៦នាក់, ស្រី១៦នាក់ និងក្មេង៣នាក់ ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ដោយបានចាក់វ៉ាក់សាំងអោយក្មេងចាប់ពីអាយុ៥ឆ្នាំដល់២៤ឆ្នាំចំនួន១៥នាក់(ស្រី៥នាក់)ហើយក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ។

## អាជ្ញាធរស្រុកសំពៅលូន បន្តទទួល
## ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/01/31/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃអាទិត្យ ១៣រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្ត្រភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង សរុបបានចំនួន២១នាក់ (ស្រី០៨នាក់ ក្មេង០៨នាក់ ក្មេងស្រី០១នាក់)។

ក្រោយពីទទួលបាន កម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ហេតុ សុំបងប្អូនសហការជាមួយកម្លាំងដើម្បីត្រួតពិនិត្យសម្ភារៈហាមឃាត់ កាំបិត០៦ដើម, កណ្តៀរ០១ដើម និងអប់រំណែនាំ រួចក៏បានប្រគល់បងប្អូនទាំងអស់ឲ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺអវិជ្ជមានទាំងអស់ រួចក្រុមគ្រូពេទ្យអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន០៤នាក់ ស្រី០២នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ)។ ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្ទេនអត់ចេញ ចំនួន១៧នាក់ (ស្រី០៦នាក់ ក្មេង០៨នាក់ ក្មេងស្រី០៣នាក់) ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## អាជ្ញាធរស្រុកសំពៅលូន បន្តទទួល
## ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 30/01/2022 Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៧និង១០នាទី នាថ្ងៃអាទិត្យ ១៣រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ុង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី កៅ ប៊ុណ្ណា (មេបញ្ជាការរងកងអនុសេនាធំ) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន២៧នាក់ (ស្រី០៨នាក់ ក្មេង០២នាក់ ក្មេងស្រី០១នាក់)។

ក្រោយពីទទួល កម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីពិនិត្យសម្ភារៈហាមឃាត់ដកហូត កាំបិត០២ដើម, ដែលស្រួច០៣ដើម, ញញួរ០១ និងបានអប់រំណែនាំរួចកម្លាំងយើងបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺវិជ្ជមាន០១នាក់ (ប្រុស) រួចក្រុមគ្រូពេទ្យអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនចំនួន២១នាក់ ស្រី០៧នាក់ ក្មេង០២នាក់ ក្មេងស្រី០១នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ)។ ចំណែកអ្នកវិជ្ជមានម្នាក់ និងអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្កេនអត់ចេញ ចំនួន០៥នាក់ (ស្រី០១នាក់) ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កពេងចក្រម្សៅមីស្ថិតក្នុងភូមិអូរល្វាឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## ថ្ងៃទី០២ ខែ កុម្ភៈ ឆ្នាំ២០២២

### រយៈពេល ២ ថ្ងៃ
### ពលករប្រុស-ស្រី និងកូនៗ ៥១៦ នាក់ ត្រឡប់មកពីថៃតាមច្រកអូរអន្លក់ ខេត្តបាត់ដំបង

https://www.postkhmer.com/ គឹម សារុំ | Publication date 31 January 2022 | 18:21 ICT

**បាត់ដំបង:** គិតពីថ្ងៃទី ២៩-៣០ មករា ឆ្នាំ ២០២២ មានពលករប្រុស-ស្រី និងក្មេងៗជាកូនពលករ ចំនួន ៥១៦នាក់បានឆ្លងដែនត្រឡប់ពីប្រទេសថៃវិញតាមច្រកអូរអន្លក់ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។ ឯប្រហែល១០ថ្ងៃមុនរដូវចូលឆ្នាំចិន-វៀតណាម មានពលករប្រុស-ស្រីប្រមាណជិត១០០នាក់បានត្រឡប់មកពីប្រទេសថៃតាមប៉ុស្តិ៍គីឡូ១៣ ក្នុងភូមិអូរ ឃុំសន្តិភាពស្រុកសំពៅលូន។

លោកម៉ង់ ស៊ី មេបញ្ជាការវរសេនាតូច៨១៩ ឈរជើងប្រចាំច្រកអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ឱ្យដឹងនៅថ្ងៃទី៣១ មករា ថា គិតពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ មករា ឆ្នាំ២០២២ មានពលករស្រី-ប្រុស រួមទាំងកូនៗរបស់ពួកគេចំនួន៥១៦នាក់បានឆ្លងដែនវិលត្រឡប់មកពីប្រទេសថៃវិញ។ ក្នុងចំនួនពលករទាំងនេះ មានអ្នកខ្លះទើបតែចាក់វ៉ាក់សាំងការពារជំងឺកូវីដបាន១ដូស និងពលករខ្លះចាក់វ៉ាសាំងបាន២ដូស ពីប្រទេសថៃរួចទៅហើយ។ លោកថ្លែងថា៖«ពលករយើងដែលគាត់ត្រឡប់មកពីប្រទេសថៃវិញ គឺសុទ្ធតែបានចាក់ថ្នាំវ៉ាក់សាំងគ្រប់ៗគ្នាហ្នឹង គ្រាន់តែអ្នកខ្លះទើបតែចាក់បាន១ដូសទេ។ បើអ្នកខ្លះចាក់បាន១ដូស គឺគ្រូពេទ្យតម្រូវឱ្យពួកគាត់ទៅធ្វើចត្តាឡីស័ក ដើម្បីចាក់វ៉ាក់សាំងបន្ថែមទៀត»។ លោកបន្តថា ពលករចំនួន៩៤នាក់(ក្មេង៧នាក់)ក្នុងចំណោម៥១៦នាក់ត្រូវបានគ្រូពេទ្យបញ្ជូនទៅធ្វើចត្តាឡីស័ក នៅមណ្ឌលធ្វើចត្តាឡីស័កគីឡូ៩ ក្នុងស្រុកសំពៅលូន ខេត្តបាត់ដំបង។

ដោយឡែកលោក ប្រាក់ សាយ មេបញ្ជាការវរសេនាតូច៨១៧ ប្រចាំការនៅប៉ុស្តិ៍គីឡូ១៣ ក្នុងភូមិអូរ ឃុំសន្តិភាព ស្រុក សំពៅលូន ឱ្យដឹងនៅថ្ងៃទី៣១ មករា ថា ក្នុងរយៈពេលជិត១០ថ្ងៃ មុនរដូវចូលឆ្នាំប្រពៃណីចិន-វៀតណាម នៅប៉ុស្តិ៍គីឡូ១៣ ក្នុងភូមិអូរ ស្រុកសំពៅលូន មានពលករឆ្លងដែនចូលមកពីប្រទេសថៃប្រមាណជិត១០០នាក់ប៉ុណ្ណោះ។ មូលហេតុនៃការវិលត្រឡប់នេះ ត្រូវបានពលករទាំងនោះប្រាប់ថា ដោយសារពួកគាត់ទៅយូរហើយ និងម្យ៉ាងអស់ការងារធ្វើ។ លោកថា ចំពោះពលករដែលឆ្លងដែនចូលមកតាមប៉ុស្តិ៍គីឡូ១៣ ក្នុងភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន គឺគ្រូពេទ្យ និងសមត្ថកិច្ចរបស់លោកតែងតែធ្វើការណែនាំ និងអប់រំ អំពីការឆ្លងជំងឺកូវីដរួចជាស្រេចមុននឹងអនុញ្ញាតឱ្យពួកគាត់ត្រឡប់ទៅលំនៅឋានវិញ។

លោកបញ្ជាក់ថា ពាក់ព័ន្ធនឹងមេខ្យល់លួចនាំពលករឆ្លងដែនក្នុងរយៈពេលកំពុងផ្ទុះជំងឺកូវីដ គឺកម្លាំងសមត្ថកិច្ចរបស់លោកឃាត់បានមេខ្យល់ប្រមាណ២០នាក់ហើយ។ ប៉ុន្តែក្នុងរយៈពេលចុងឆ្នាំ២០២១ និងដើមឆ្នាំ២០២២នេះ មិនឃើញមានមេខ្យល់លួចនាំពលករឆ្លងដែនទៅប្រទេសថៃទេ។ លោកប្រាក់ សាយ ថ្លែងថា៖«យើងចាប់បាន

មេខ្យល់ខ្លះទៅ ឥឡូវឃើញមានផ្លូវស្រោលច្រើន មិនសូវមានបទល្មើសលួចឆ្លងដែនទេ។ ការងារនេះ យើងឃ្លាំចាំមើលពួកគាត់រហូត នៅតាមតំបន់ឈរជើង ទាំងពួកគាត់ត្រឡប់មកវិញ ទាំងពលករដែលត្រូវបានមេខ្យល់លួចនាំឆ្លងដែន»៕

## ប្រទេសថៃត្រូវការពលករ
## ចំណាកស្រុករហូតដល់ ៨០ម៉ឺននាក់ជាបន្ទាន់ ពលករខ្មែរស្ថិតក្នុងចំណោមបញ្ជីកំពូល

https://www.khmertimeskh.com/ Khmer Times February 1, 2022

សហព័ន្ធឧស្សាហកម្មថៃ (FTI) បាននិយាយថា ប្រទេសថៃត្រូវការពលករចំណាកស្រុកចំនួន ៨០០,០០០ ជាបន្ទាន់ ដើម្បីបម្រើវិស័យផលិតកម្ម ក៏ដូចជាអាជីវកម្មទេសចរណ៍ និងសេវាកម្មដែលកំពុងជួបការលំបាកក្នុងការដោះស្រាយកង្វះកម្លាំងពលកម្ម។ ក្រុមហ៊ុនជាច្រើនកំពុងចុះឈ្មោះជាមួយរដ្ឋាភិបាល ដើម្បីនាំចូលពលករពីប្រទេសមីយ៉ាន់ម៉ា កម្ពុជា និងឡាវ ខណៈដែលតម្រូវការពលករកើនឡើង ដោយសារសេដ្ឋកិច្ចងើបឡើងវិញ។

លោក Kriengkrai Thiennukul អនុប្រធាន FTI បាននិយាយថា "វិស័យឧស្សាហកម្មត្រូវការពលករចំណាកស្រុកច្រើនជាងគេ ដោយបច្ចុប្បន្នមានតម្រូវការកើនឡើងដល់ ៥០០,០០០នាក់" ។ សហគ្រិន ក្នុងវិស័យទេសចរណ៍ និងសេវាកម្មពាក់ព័ន្ធ ត្រូវការ ពលករប្រមាណ ៣០០,០០០នាក់។ លោក Kriengkrai បានថ្លែងថា៖ «វិស័យអាជីវកម្មចង់ឲ្យរដ្ឋាភិបាលពន្លឿនដំណើរការនាំចូលពលករចំណាកស្រុក។

ថ្មីៗនេះ អាជ្ញាធរបានចាប់ផ្តើមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសជិតខាង ដើម្បីដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្មធ្ងន់ធ្ងរ។ វិស័យនាំចេញដែលបានពង្រីកយ៉ាងឆាប់រហ័សកាលពីឆ្នាំមុន បន្ទាប់ពីការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោកបានជំរុញឱ្យមានតម្រូវការពលកម្ម។ ប្រតិបត្តិករអាជីវកម្មនៅក្នុងឧស្សាហកម្មចំនួន ៤៥ ជាពិសេសផ្នែកម្ហូបអាហារ ចង់ជួលពលករបន្ថែមទៀត ក៏ដូចជាអាជីវកម្មក្នុងវិស័យសណ្ឋាគារផងដែរ នេះបើយោងតាម FTI ។

វិធានការបិទខ្ទប់ពីមុន ដែលបានដាក់ចេញ ដើម្បីទប់ស្កាត់ការរីករាលដាលនៃមេរោគកូវីដ-១៩ ដែលបានវាយប្រហារប្រទេសថៃនៅដើមឆ្នាំ២០២០ បានបណ្តាលឱ្យពលករចំណាកស្រុកមួយចំនួនត្រឡប់ទៅប្រទេសរបស់ពួកគេវិញ ដោយសារតែសកម្មភាពអាជីវកម្មជាច្រើនត្រូវបានផ្អាក ដែលបណ្តាលឱ្យពួកគេបាត់បង់ការងារ។ ស្ថានភាពបានប៉ះពាល់ខ្លាំងដល់ កង្វះកម្លាំងពលកម្មនៅក្នុងប្រទេសថៃដែលបានចាប់ផ្តើមមុនពេលជំងឺរាតត្បាត។ ទោះបីជាប្រទេសថៃត្រូវការពលករបរទេសកាន់តែច្រើនក៏ដោយ ការចូលដោយខុសច្បាប់នៃជនចំណាកស្រុក ជាពិសេសអ្នកដែលមកពីប្រទេសមីយ៉ាន់ម៉ាដែលភៀសខ្លួនចេញពីភាពចលាចលនយោបាយនៅក្នុងប្រទេសរបស់ពួកគេ បានបង្ករជាការព្រួយបារម្ភមួយចំនួន អំពីលទ្ធភាពនៃការផ្ទុះឡើងនៃ ការឆ្លងកូវីដ-១៩ សារជាថ្មី។

FTI ពីមុនបានស្នើឱ្យរដ្ឋាភិបាលអនុវត្តគម្រោងfactory sandbox schemeនៅជិតព្រំដែន រួមទាំងនៅស្រុក Mae Sot នៃខេត្ត Tak ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងដើម្បីទប់ស្កាត់ការរីករាលដាលថ្មី នេះបើយោងតាមលោក Kriengkrai ។ គម្រោងនេះ រួមមានវិធានការដើម្បីរក្សាកម្មករឱ្យនៅដាច់ដោយឡែក ចាក់វ៉ាក់សាំង និងរៀបចំការធ្វើដំណើរដោយផ្ទាល់ពីព្រំដែនទៅកាន់រោងចក្ររបស់ពួកគេ។ លោកបាននិយាយថា សហព័ន្ធជឿជាក់ថាគម្រោងនេះនឹងជួយអាជ្ញាធរទប់ស្កាត់ ក្រុមចម្លងថ្មី ក៏ដូចជាកាត់បន្ថយការចូលដោយខុសច្បាប់របស់ពលករចំណាកស្រុក និងការជួញដូរមនុស្ស។ ទន្ទឹមនឹងនេះ ពលករខ្មែរចំណាកស្រុក ចំនួន ២២៦ នាក់ ក្រុមទី១ ក្រោមការព្រមព្រៀងគ្នានៃអនុស្សរណៈនៃការយោគយល់ (MoU) ស្តីពីកិច្ចសហប្រតិបត្តិការការងាររវាងរដ្ឋាភិបាលថៃ និងកម្ពុជា នឹងមកដល់ប្រទេសថៃនៅថ្ងៃនេះ។ នេះជាចំនួនតិចតួចដែលបានផ្តល់ឱ្យ តម្រូវការដ៏ធំរបស់ប្រទេសថៃ ដែលរំពឹងថានឹងត្រូវបំពេញដោយពលករមកពីប្រទេសកម្ពុជា មីយ៉ាន់ម៉ា និងឡាវ៕ Bangkokpost/*Khmer Times*

## ពលករចំណាកស្រុកខ្មែរជាង ៣៨៥,000 នាក់បានទទួលការចាក់វ៉ាក់សាំងនៅប្រទេសថៃ

https://www.khmertimeskh.com/ Khmer Times February 1, 2022

ពលករចំណាកស្រុកខ្មែរប្រមាណ ៣៨៥,១៨៨ នាក់ដែលធ្វើការក្នុងប្រទេសថៃ ត្រូវបានចាក់វ៉ាក់សាំងនៅចន្លោះពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០២១ ដល់ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២។ នៅក្នុងព័ត៌មានដែលទទួលបានដោយកាសែតខ្មែរថាមស៍ ក្រាហ្វបង្ហាញថា ចំនួនពលរដ្ឋខ្មែរស្ថិតក្នុងចំណោម ចំនួនជនបរទេសដែលមានអត្រាចាក់វ៉ាក់សាំងច្រើនជាងគេទីពីរ នៃជនបរទេសចំនួន១០ជាតិសាសន៍ នៅក្នុងប្រទេសថៃ។ ក្រាហ្វក៏បានបង្ហាញបន្ថែមទៀតថា ជនបរទេសសរុបចំនួន ២,១៥៤,៨៤៩ នាក់ត្រូវបានចាក់វ៉ាក់សាំង។ សហគមន៍ពលករចំណាកស្រុកច្រើនជាងគេបំផុត ដែលបានទទួលការចាក់វ៉ាក់សាំងបង្ការ គឺមកពីប្រទេសមីយ៉ាន់ម៉ា ដែលមាន ចំនួនសរុប ១,៣០៥,៩២០ នាក់។ ពលរដ្ឋមីយ៉ាន់ម៉ា ក៏មានចំនួនពលករចំណាកស្រុកបរទេសច្រើនបំផុតក្នុងប្រទេសថៃ។

ពលករខ្មែរដែលបានទទួលវ៉ាក់សាំងបង្ការមានចំនួន ១៧,៨៨ ភាគរយ ធៀបនឹងប្រជាជនមីយ៉ាន់ម៉ា ៦០,៦១ ភាគរយ និងប្រជាជនឡាវចំនួន ១៩២,៧៨៩ នាក់ ស្មើនឹង ៨,៩៥ ភាគរយ។ ប្រទេសផ្សេងទៀតដែលជាប់ចំណាត់ថ្នាក់កំពូលទាំង១០ ក្នុងចំណោមជាតិសាសន៍ដែលគេចាក់វ៉ាក់សាំងនៅប្រទេសថៃ គឺមានប្រទេសចិននៅលេខ៤ ជប៉ុន ក្រិក ឥណ្ឌា ហ្វីលីពីន អង់គ្លេស និងសហរដ្ឋអាមេរិក។ ព័ត៌មាននេះត្រូវបានផ្តល់ដោយមជ្ឈមណ្ឌលចាក់វ៉ាក់សាំងបង្ការរបស់ក្រសួងសុខាភិបាលសាធារណៈ (MOPH) របស់ប្រទេសថៃ ការវិភាគ និងការពិពណ៌នា៖ ការិយាល័យសហប្រតិបត្តិការអន្តរជាតិ។ ប្រទេសថៃបាននិយាយថា ខ្លួនត្រូវការពលករចំណាកស្រុករហូតដល់ ៨០ ម៉ឺននាក់ ដើម្បីបំពេញការងារក្នុងឧស្សាហកម្មផ្សេងៗក្នុងប្រទេសថៃ៕

## ថៃទទួលពលករខ្មែរជិត២០០នាក់តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតលើកដំបូង

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០១ ខែ កុម្ភៈ ឆ្នាំ ២០២២ ម៉ោង ១០:២៦

ខេត្តបន្ទាយមានជ័យ ៖ ពលករកម្ពុជាតាមរយៈក្រុមហ៊ុនមួយចំនួន១៨៥នាក់ ត្រូវបានអនុញ្ញាតឲ្យធ្វើដំណើរទៅធ្វើការលើទឹកដីថៃជាលើកដំបូង តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតខ្លងលឹក នៅព្រឹកថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ ២០២២នេះ ក្រោយភាគីថៃបិទអ្នកដំណើរថ្មើរជើង ហើយបើកឲ្យដំណើរការតែរថយន្តធុនធំរបស់គេអស់រយៈពេលជាង២ឆ្នាំមកហើយ ដោយសារតែបញ្ហាជំងឺរាតត្បាតនៃកូវីដ១៩។

ពលករកម្ពុជាចំនួន១៨៥នាក់ខាងលើ ក្នុងនោះមានស្រី៨៨នាក់ ដោយពួកគេបានចាកចេញពីប្រទេសកម្ពុជាតាមរយៈក្រុមហ៊ុន ទូចម៉ាណាក់ម៉ែនផៅវ័រស៊ុប្លាយ គ្រោងទៅធ្វើការផ្នែករោងចក្រសាច់មាន់ នៅខេត្តឈុនបូរី ប្រទេសថៃ។ ហើយការបើកទទួលពលករជាលើកដំបូងតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតនេះ គេឃើញមានមន្ត្រីមកពីក្រសួង និងមន្ទីរពាក់ព័ន្ធ ព្រមទាំងសមត្ថកិច្ចថៃបានចូលមកទទួលស្វាគមន៍ពលករកម្ពុជា ដល់ខាងទឹកដីកម្ពុជាផងដែរ។

លោក ខេង តារា មន្ត្រីមកពីមន្ទីរការងារខេត្ត បានប្រាប់កោះសន្តិភាពនៅមាត់ច្រកទ្វារអន្តរជាតិប៉ោយប៉ែតថា ពលករដែលចេញពីកម្ពុជាទៅធ្វើការលើទឹកដីថៃ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតនៅថ្ងៃនេះ គឺមានចំនួន១៨៥នាក់ ក្នុងនោះស្រី៨៨នាក់។ លោកថា លក្ខខណ្ឌរបស់ភាគីថៃ ពាក់ព័ន្ធនឹងវិធានការក្រសួងសុខាភិបាលរបស់គេ គឺមាន២ចំណុច ដោយទី១- ពលករដែលមានឯកសារចាក់វ៉ាក់សាំងរួចរាល់ ត្រូវធ្វើចត្តាឡីស័កចំនួន៧ថ្ងៃ និងទី២- សម្រាប់ពលករមិនមានឯកសារចាក់វ៉ាក់សាំង ត្រូវធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃលើទឹកដីថៃ មុនពេលចូលទៅធ្វើការងារ។

លោក ង៉ោ ម៉េងជ្រួន អភិបាលរងខេត្តបន្ទាយមានជ័យ បានប្រាប់តាមទូរស័ព្ទដែរថា ការបញ្ជូនពលករខ្មែរទៅធ្វើការលើទឹកដីថៃនេះ គឺធ្វើឡើងផ្អែកលើអនុសារណៈ MOU នៃក្រសួងការងារកម្ពុជា និងថៃ ដែលបានឯកភាពគ្នារួចហើយ និងមានកាទទួលខុសត្រូវពីមន្ទីរការងារ និងក្រុមហ៊ុននាំ និងទទួលពលករផងដែរ។ លោកអភិបាលរងរូបនេះ បានបញ្ជាក់ទៀតថា នៅមិនទាន់មានព័ត៌មានពីការបើកច្រកទ្វារអន្តរជាតិប៉ោយប៉ែតខ្លងលឹក ពីភាគីថៃឲ្យទូលំទូលាយសម្រាប់ពលរដ្ឋ និងទេសចរណ៍នៅឡើយទេ៕

## សមត្ថកិច្ចថៃចាប់
## បញ្ជូនពលករខ្មែរជាង២០០នាក់មកប្រទេសកម្ពុជាវិញក្នុងពេលកំពុងសែនចូលឆ្នាំចិន

https://www.facebook.com/neakmeasnews/ ចេញផ្សាយថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២២ ដោយ ជីវ័ន្ត

(ខេត្តបាត់ដំបង)៖ កម្លាំងបញ្ជាការដ្ឋានវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៩ បានសហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យដែលឈរជើងតាមខ្សែបន្ទាត់ព្រំដែន បានទទួលពលករខ្មែរប្រុសស្រីជាង២០០នាក់ ដែលភាគីខាងនៃសមត្ថកិច្ចថៃចាប់បញ្ជូនមកអោយអាជ្ញធរកម្ពុជា ដើម្បីរាប់ចំអោយត្រឡប់ទៅស្រុកកំណើតវិញ តាមច្រកទ្វាតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។ លោកវរសេនីយ៍ឯកម៉ង់ ស៊ី មេបញ្ជាការដ្ឋានវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានអោយដឹងថា ដោយអនុវត្តន៍តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោសាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ក្នុងការការពារទប់ស្កាត់បទល្មើសឆ្លងដែនពិសេសការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ ក្នុងការត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញាមេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រដែលខ្លួនទទួលខុសត្រូវ ជាក់ស្តែងនៅព្រឹកថ្ងៃ ទី៣១ ខែមករា ឆ្នាំ២០២២នេះ លោកបានចាត់អោយកម្លាំងប៉ុស្តិ៍អូរអន្លក់សហការជាមួយកម្លាំងកងយោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យ បានចុះទទួលពលករខ្មែរប្រុសស្រីសរុប ២៣៣នាក់ ដែលភាគីខាងថៃចាប់បញ្ជូនមកតាមច្រកទ្វាតំបន់អូរអន្លក់ ក្នុងស្រុកកំរៀង ខេត្តបាត់ដំបង។ លោកបន្តថា ពលករខ្មែរដែលសមត្ថកិច្ចខាងប្រទេសថៃចាប់បញ្ជូនមកអោយអាជ្ញាធរកម្ពុជាវិញនាពេលនេះសរុបទាំង ២៣៣នាក់ ក្នុងនោះស្រីចំនួន ៨២នាក់និងក្មេងចំនួន ៣៣នាក់ផងដែរ ដែលត្រូវបានក្រុមគ្រូពេទ្យធ្វើតេសរហ័សស្វែងរកមេរោគដែលជាលទ្ធផល វិជ្ជមានកូវីដ១៩ ចំនួន០១នាក់ជាស្ត្រី និងពលករចំនួន ៤៦នាក់ស្រី១៦នាក់និងក្មេង០៣នាក់ត្រូវបានចាត់បញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូនដោយឡែកពលករខ្មែរដែលមានកាតចាក់វ៉ាក់សាំងចំនួន ១៨៦នាក់ ស្រី ៦៥នាក់និងក្មេង ៣០នាក់ត្រូវក្រុមគ្រូពេទ្យធ្វើការអប់រំណែនាំអំពីវិធានការ ការពារការឆ្លងជំងឺកូវី-១៩រួចបានអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតវិញផងដែរ។

# ថ្ងៃទី០៣ ខែ កុម្ភៈ ឆ្នាំ២០២២

## អាជ្ញាធរស្រុកសំពៅលូន បន្តទទួល
## ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/02/01/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង១៤និង០០នាទី នាថ្ងៃអង្គារ ១៥រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរ

សេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០២នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្ត បាត់ដំបង ចំនួន០៦នាក់ ស្រី០៣នាក់ (ក្មេង០២នាក់ ក្មេងស្រី០១នាក់)។

ក្រោយពីទទួល កម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីពិនិត្យសម្ភារៈហាមឃាត់មិនមាន និងបានអប់រំណែនាំរួចកម្លាំងយើងបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺអវិជ្ជមានទាំងអស់ រួចក្រុមគ្រូពេទ្យអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនវិញ។

## អាជ្ញាធរស្រុកសំពៅលូន បន្តទទួល
## ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/02/01/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៩និង០០នាទី នាថ្ងៃអង្គារ ១៥រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០២នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន៨០នាក់ (ស្រី៣៧នាក់ ក្មេង១៣នាក់ ក្មេងស្រី០៤នាក់)។

ក្រោយពីទទួល កម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីពិនិត្យសម្ភារៈហាមឃាត់មិនមាន និងបានអប់រំណែនាំរួចកម្លាំងយើងបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺអវិជ្ជមានទាំងអស់ រួចក្រុមគ្រូពេទ្យអនុញ្ញាតឲ្យបងប្អូនប្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន៣៥នាក់ ស្រី១៥នាក់ ក្មេង០៦នាក់ ក្មេងស្រី០២នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ)។ ចំណែកអ្នកមានបានចាក់វ៉ាក់សាំងតែស្កេនអត់ចេញ ចំនួន៤៥នាក់ (ស្រី២២នាក់ ក្មេង០៧នាក់ ក្មេងស្រី០២នាក់) ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័ក នៅចំណុចរោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## អាជ្ញាធរស្រុកសំពៅលូន ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ ពីប្រទេសថៃ និងប្រគល់ទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣

https://gdlf-kh.com/ 2022/02/01/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៧និង៣០នាទី នាថ្ងៃចន្ទ ១៤រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡេ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុ៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០២នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០២នាក់ (ស្រីម្នាក់)។

ក្រោយពីទទួល កម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីពិនិត្យសម្ភារៈហាមឃាត និងបានអប់រំណែនាំរួចកម្លាំងយើងបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺអវិជ្ជមាន រួចបានប្រគល់បងប្អូនទាំងអស់អោយទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣។

## ពលរដ្ឋខ្មែរហូរចូលប្រទេសថៃ ខណៈដែលប្រទេសនេះបើកឲ្យពលករចំណាកស្រុកឡើងវិញ

https://www.khmertimeskh.com/ Khmer Times February 2, 2022

ពលករចំណាកស្រុកបានចាប់ផ្តើមហូរចូលប្រទេសថៃកាលពីថ្ងៃអង្គារ ខណៈដែលប្រទេសនេះបានបើកព្រំដែនរបស់ខ្លួនឡើងវិញ បន្ទាប់ពីរយៈពេលពីរឆ្នាំ ដោយមានតម្រូវការ ក្នុងការបំពេញកង្វះកម្លាំងកម្លាំងពលកម្មដែលត្រូវបានគេប៉ាន់ស្មានថា មានចំនួន ៨០០,០០០ នាក់។

អភិបាលរងខេត្ត លោក ណាតាឆៃ ណាមពុនសុខសាន្ត បាននិយាយថា ពលករខ្មែរសរុបចំនួន ១៨៤នាក់ បានឆ្លងកាត់ប៉ុស្តិ៍ត្រួតពិនិត្យបានខ្លងលឹក ក្នុងស្រុកអារ៉ាញ់ប្រាថេត ខេត្តស្រះកែវ។ ព្រះរាជាណាចក្រថៃត្រូវការពលករចំណាកស្រុកប្រមាណ ៨០០,០០០ នាក់ជាបន្ទាន់ ដើម្បីបម្រើដល់វិស័យផលិតកម្ម ទេសចរណ៍ និងសេវាកម្ម នេះបើយោងតាមសហព័ន្ធឧស្សាហកម្មថៃ។ ក្រសួងការងារកំពុងចុះឈ្មោះពលករមកពីប្រទេសកម្ពុជា មីយ៉ាន់ម៉ា និងឡាវ។ ពលករទាំងអស់នឹងត្រូវធ្វើចត្តាឡីស័កក្នុងប្រទេសថៃ។

នៅក្រោមដំណើរការចុះឈ្មោះរបស់ក្រសួងការងារ និយោជកក្នុងប្រទេសថៃត្រូវបង់ថ្លៃចត្តាឡីស័កចំនួន ៨,៥០០ បាតសម្រាប់ពលករចំណាកស្រុកម្នាក់ៗដែលពួកគេចុះឈ្មោះ។ ពលករចំណាកស្រុកម្នាក់ៗ ត្រូវចំណាយពេលមួយសប្តាហ៍នៅក្នុងមណ្ឌលចត្តាឡីស័កកូវីដ-១៩ ដែលអ្នកណាដែលមិនបានចាក់វ៉ាក់សាំងបង្ការ នឹងទទួលបានការចាក់វ៉ាក់សាំងនៅទីនោះ។ ដំណើរការចុះឈ្មោះរបស់នាយកដ្ឋានការងារ ដើម្បីនាំពលករបរទេសចូលដំណើរការរហូតដល់ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០២៣៕ The Nation

## ពលករMOUខ្មែរ ជាង ២០០ នាក់ បញ្ជូនទៅធ្វើការនៅថៃ តេស្តអវិជ្ជមានកូវីដទាំងអស់

https://www.kampucheathmey.com/ ថ្ងៃពុធ ២ កុម្ភៈ ២០២២ដោយ Sorn Phanith

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជាបានឱ្យដឹងនៅរសៀលថ្ងៃទី ០២ កុម្ភៈ នេះថា ពលករMOUចំនួន ២២០នាក់ បញ្ជូនទៅធ្វើការនៅប្រទេសថៃ កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ មានលទ្ធផលតេស្តអវិជ្ជមានកូវីដ១៩ទាំងអស់។ ប៉ុន្តែត្រូវធ្វើចត្តាឡីស័ក៧ថ្ងៃទៀតមុនចេញទៅធ្វើការនៅតាមរោងចក្រ។ លោកបានបន្តថាពលករទាំងនោះ បានបញ្ជូនតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែតទល់នឹងខេត្តស្រះកែវ ហើយមានការទៅទទួលស្វាគមន៍ដោយផ្ទាល់ពីមន្ត្រីក្រសួងការបរទេសថៃ ក្រសួងការងារថៃអភិបាលខេត្តស្រះកែវ។ ចំណែកភាគីកម្ពុជាមានតំណាងក្រសួងការងារ និងលោកអភិបាលខេត្តបន្ទាយមានជ័យដែលធ្វើឱ្យការបញ្ជូនប្រព្រឹត្តិទៅដោយរលូនព្រោះថា នេះជាលើកទី ១ ហើយបន្ទាប់ពីមានការរាតត្បាតជំងឺកូវីដ១៩។ លោកបានបន្តទៀតថា ពលករចំនួន ២២០ នាក់ពេលទៅដល់ទឹកដីថៃបានធ្វើតេស្តលើកទី១រួចហើយ ដោយទទួលបានលទ្ធផលអវិជ្ជមានទាំងអស់ ហើយកំពុងធ្វើចត្តាឡីស័ក ៧ ថ្ងៃ នៅបន្ទប់ដ៏ស្អាតដោយមានការផ្គត់ផ្គង់អាហារ ៣ ពេលដោយឥតគិតថ្លៃ ហើយនៅថ្ងៃទី ៧ ត្រូវធ្វើតេស្តម្តងទៀតបើលទ្ធផលនៅអវិជ្ជមានទៀត ទើបអនុញ្ញាតឱ្យទៅរោងចក្រធ្វើការតែម្តង។

លោកបានបន្ថែមថា ការទទួលបានលទ្ធផលតេស្តអវិជ្ជមាននេះ បានធ្វើឱ្យភាគីថៃមានទំនុកចិត្តខ្ពស់មកលើពលករខ្មែរយើង ព្រោះពួកគេបានចាក់វ៉ាក់សាំងបានគ្រប់ដូសរហូតដល់ដូសជំរុញ ឬដូសទី ៣ និងដូសទី ៤ ហើយវ៉ាក់សាំង ដែលចាក់សុទ្ធតែវ៉ាក់សាំងមានគុណភាពដូចជាអាស្ត្រាហ្សេនេកា វ៉ាក់សាំងម៉ូដេណានិងវ៉ាក់សាំងហ្វាយហ្សើរ ដែលធ្វើឱ្យកម្រិតហានិភ័យនៃការឆ្លងមានកម្រិតទាបបំផុត។ លោកបានបន្តទៀតថា ពលករខ្មែរដែលអាចទៅធ្វើការនៅប្រទេសថៃ ត្រូវមានលក្ខខណ្ឌមួយចំនួនដូចជា ត្រូវមានកាតចាក់វ៉ាក់សាំង ធ្វើតេស្តរកជំងឺកូវីដ១៩ រយៈពេល ៧២ ម៉ោងតាមម៉ាស៊ីនPCR ឬតេស្តរហ័សដែលធ្វើដោយគ្រូពេទ្យជំនាញ ដើម្បីបញ្ជាក់វិញ្ញាបនបត្រថា មិនមានឆ្លងជំងឺកូវីដ១៩។ ពេលទៅដល់ព្រំដែនពលករ ត្រូវធ្វើតេស្តហើយបើលទ្ធផលតេស្តអវិជ្ជមាន ត្រូវបន្តធ្វើចត្តាឡីស័ករយៈពេល ៧ ថ្ងៃ និងថ្ងៃទី ៧ ត្រូវធ្វើតេស្តម្តងទៀតហើលទ្ធផលនៅអវិជ្ជមានទៀតទើបអនុញ្ញាតឱ្យទៅរោងចក្រធ្វើការតែម្តង។ លោកបានឱ្យដឹងទៀតថា ក្នុងករណីមានវិជ្ជមានកូវីដ១៩ ត្រូវបញ្ជូនទៅកន្លែងព្យាបាលហើយរាល់ការចំណាយទៅលើព្យាបាលជាបន្ទុករបស់និយោជកថៃទាំងស្រុង។ លោក អន ប៊ុនហាក់ បានបញ្ជាក់ថា ពលករចំនួន២២០នាក់ ទៅធ្វើការនៅប្រទេសថៃ គឺធ្វើការនៅរោងចក្រសាច់មាន់ PANU SPOULTRY GROUP CO., LTD. នៅខេត្តឈុនបុរីដោយពួកគេម្នាក់ៗទទួលបានប្រាក់ខែពី៥០០ទៅ៧០០ដុល្លារក្នុង១ខែ៕ **អត្ថបទ៖ សំអឿន**

# ថ្ងៃទី០៤ ខែ កុម្ភៈ ឆ្នាំ២០២២

## ក្រសួងសុខាភិបាលមានសុទិដ្ឋិនិយ ដោយសារករណីអូមីក្រុងថ្មីភាគច្រើនជាករណីស្រាល

https://www.khmertimeskh.com/ Yim Sreylin / Khmer Times February 2, 2022

អស់រយៈពេលជាងពីរឆ្នាំដែលជំងឺរាតត្បាតកូវីដ-១៩ បានបង្កផលវិបាក រហូតដល់មានករណីស្លាប់ជាច្រើន ក៏ប៉ុន្តែពេលនេះ យើងមើលឃើញថាវីរុសបម្លែងថ្មី អូមីក្រុង មានកម្រិតស្រាលជាងវីរុស ដែលតា ដែលបានឆក់យកជីវិតមនុស្សជាង ៣,០០០ នាក់នៅក្នុងប្រទេសកម្ពុជា។ បើទោះបីវីរុស អូមីក្រុង និងវីរុសបម្លែងថ្មីផ្សេងៗបណ្តាលឲ្យមានករណីឆ្លងកើនឡើងក៏ដោយ ក៏មិនមានករណីស្លាប់ណាមួយត្រូវបានរាយការណ៍ក្នុងរយៈពេលជាច្រើនខែមកនេះដែរ។ ហើយអាជ្ញាធរសុខាភិបាលបានសន្មតថានេះជាលទ្ធផលនៃអត្រាការចាក់វ៉ាក់សាំងខ្ពស់ក្នុងទូទាំងប្រទេស ជម្រើសនៃការព្យាបាលប្រសើរឡើង និងវិធានការសុខភាពដែលមានប្រសិទ្ធភាព។

លោក ហុក គឹមចេង អ្នកនាំពាក្យក្រសួងសុខាភិបាល និយាយកាលពីម្សិលមិញថា មានកត្តាចំនួនប្រាំដែលចង្អុលឆ្ពោះទៅរកការបញ្ចប់ជំងឺរាតត្បាត បើទោះជាវីរុសអូមីក្រុងមានការចម្លងខ្ពស់ជាងមុនក៏ដោយ ជាពិសេស វីរុសបំប្លែងខ្លួនអូមីក្រុងរងប្រភេទ BA.2 ។ លោកលើកឡើងថា៖ «ទីមួយ អត្រាករណីស្លាប់បានថយចុះដល់សូន្យក្រោយពីមនុស្សជាង ៣,០០០ នាក់ត្រូវស្លាប់ដោយសារជំងឺកូវីដ-១៩ និងវីរុសបម្លែងថ្មីរបស់វា។ អស់រយៈពេលជាងបីខែហើយ កម្ពុជាមិនបានកត់ត្រាករណីស្លាប់ដោយសារជំងឺកូវីដ-១៩ ទេ។ ទីពីរចំនួននៃការឆ្លងក្នុងកម្រិតធ្ងន់ធ្ងរបានថយចុះពីអ្នកជំងឺប្រហែល ១,៥០០ នាក់មកមិនលើសពី ២០០ នាក់ដែលកំពុងទទួលការព្យាបាលនៅក្នុងបន្ទប់សង្គ្រោះបន្ទាន់»។ លោកបន្តថា៖ «ទីបី ករណីឆ្លងវីរុស ដែលតា ដំលែងមានខ ណៈវត្តមានរបស់វីរុសអូមីក្រុងនិងវីរុសបម្លែងខ្លួនរងកើតមាន។

ករណីឆ្លងវីរុសដែលតា មិនត្រូវបានរាយការបន្ថែមទៀត ហើយវាក៏លែងជាមូលហេតុដែលគួរព្រួយបារម្ភទៀតដែរ»។ លោកថា៖ «ទី៤ ជម្រើសព្យាបាលមានភាពប្រសើរឡើង ហើយដោយសារការឆ្លងមានកម្រិតស្រាលអ្នកជំងឺអាចទទួលការព្យាបាលនៅផ្ទះបាន»។ លោកបន្ថែមថា៖ «ជាចុងក្រោយ គឺអត្រានៃការចាក់វ៉ាក់សាំងខ្ពស់ដែលគ្រប់ដណ្តប់លើកត្តាចំនួនបួនខាងលើ។ យើងខ្ញុំអរគុណលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបាននាំយកវ៉ាក់សាំងទៅចាក់ជូនគ្រប់ជាតិសាសន៍ក្នុងប្រទេសដោយមិនគិតថ្លៃ»។ លោកកត់សម្គាល់ថាវីរុស អូមីក្រុង មានកម្រិតជំងឺស្រាលជាងមុន ខណៈករណីឆ្លងកើនឡើងដែលមិនធ្លាប់មានពីមុនមកនៅក្នុងករណីឆ្លងទូទាំងប្រទេស ដែលអាចប្រៀបធៀបបានជាមួយនឹងជំងឺគ្រុនផ្តាសាយបាន។

ជាមួយគ្នានេះដែរ លោក សុខ លូ អភិបាលខេត្តបាត់ដំបង និយាយកាលពីម្សិលមិញថា ការគំរាមកំហែងនៃមេរោគកូវីដ-១៩ ដែលឆ្លងដោយពលករចំណាកស្រុកត្រឡប់មកពីប្រទេសថៃ លែងជាមូលហេតុដែលគួរឲ្យព្រួយបារម្ភទៀតហើយ ដោយសារការធ្វើតេស្តតឹងរ៉ឹងនៅតាមព្រំដែន។ លោកបន្តថា៖ «បទពិសោធន៍កន្លងមកក្នុងការគ្រប់គ្រងលំហូរចូលនៃពលករចំណាកស្រុក និងការកើនឡើងនៃករណី Delta បានអនុញ្ញាតឲ្យពួកយើងស្ថិតក្នុងស្ថានភាពប្រសើរជាងមុនក្នុងការដោះស្រាយជាមួយករណីឆ្លងនាំចូលនៃវីរុស Omicron និងវីរុសបម្លែងខ្លួនរង BA.2 នាពេលនេះ»។

បើតាមលោកឌី រ៉ាដូ អភិបាលរងខេត្តឧត្តរមានជ័យ ក្នុងចំណោមពលករចំណាកស្រុកជាង ៥០០ នាក់ដែលស្ថិតនៅក្រោមការធ្វើចត្តាឡីស័ក គឺមិនមានចំនួនលើសពីមួយរយនាក់ ដែលកំពុងទទួលការព្យាបាលនៅមជ្ឈមណ្ឌលកូវីដ-១៩ ឡើយ។ លោកនិយាយថា៖ «ពួកគេបានត្អូញត្អែរថា ការឆ្លងមានកម្រិតស្រាល ប៉ុន្តែពួកគេមិនត្រូវបានអនុញ្ញាតឲ្យទទួលការព្យាបាលនៅផ្ទះដូចនៅផ្នែកផ្សេងទៀតនៃប្រទេសឡើយ។ ទោះយ៉ាងណាដោយសារតែវីរុស អូមីក្រុង និងវីរុសបម្លែងខ្លួនរងមានសន្ទុះឆ្លងខ្ពស់ យើងមិនអនុញ្ញាតឲ្យមានការព្យាបាលនៅផ្ទះនោះទេ ដើម្បីការពារការរីករាលដាលណាមួយកើតមាន»។

លោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាល បាននិយាយក្នុងសារជាសំឡេងកាលពីម្សិលមិញថា លោកស្រីចង់ធ្វើការអំពាវនាវយ៉ាងខ្លាំងក្លា និងជាថ្មីទៀតដល់បងប្អូនជនរួមជាតិ ឲ្យបន្តអនុវត្តវិធានការ ៣កុំ និង ៣ការពារ។ លោកស្រីបន្តថា៖ «ហើយសម្រាប់អ្នកមិនទាន់បានចាក់វ៉ាក់សាំង សូមអញ្ជើញមកទទួលចាក់វ៉ាក់សាំងទាំងអស់គ្នា។ ជាពិសេស វ៉ាកសាំងដូសជំរុញដើម្បីបង្កើនការការពារក្នុងប្រព័ន្ធរាងកាយ ក្នុងការប្រយុទ្ធប្រឆាំងនឹងវីរុសអូមីក្រុង និងវីរុសបម្លែងខ្លួនរង ដែលបាននិងកំពុងរីករាលដាលជារៀងរាល់ថ្ងៃ»៕

## កម្ពុជានឹងបញ្ជូនពលករ MOU ៨០០ នាក់បន្ថែមទៀត ទៅធ្វើការនៅថៃ ចុងខែនេះ

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ៣ កុម្ភៈ ២០២២ដោយ KC Virak

នៅចុងខែកុម្ភៈ ឆ្នាំ២០២២នេះ កម្ពុជានឹងបញ្ជូនពលករ MOU ប្រមាណ ៨០០ នាក់បន្ថែមទៀតទៅធ្វើការនៅប្រទេសថៃ បន្ទាប់ពីបានបញ្ជូន ២២០ នាក់រួចហើយ កាលពីថ្ងៃទី ០១ ខែកុម្ភៈ ថ្មីៗនេះ។

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា បានឱ្យដឹងនៅព្រឹកថ្ងៃទី ០៣ ខែកុម្ភៈនេះថា តាមភាគីថៃជូនដំណឹង ពលករ MOU ប្រមាណ ៨០០ នាក់នេះនឹងត្រូវបញ្ជូនទៅពីរលើក គឺនៅថ្ងៃទី២១ និងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ដោយទៅធ្វើការនៅក្រុមហ៊ុនស៊ីភី ផ្នែកចំណីអាហារដ៏ធំរបស់ថៃ និងបញ្ជូនទៅធ្វើការនៅតាមក្រុមហ៊ុនតូចៗ ដែលមានតម្រូវការពលករពី ១០ ឬ ២០ នាក់ជាបន្តបន្ទាប់ទៀត។ លោក អន ប៊ុនហាក់ បានបន្តថា៖ "យើងបានបញ្ជូនឈ្មោះស្នើសុំពលករប្រមាណ ៣ ០០០ ទៅ ៣ ៥០០ នាក់ទៅធ្វើការដោយស្របច្បាប់នៅប្រទេសថៃទៅលើផ្នែករោងចក្រចំណីអាហារដូចជា សាច់មាន់ សាច់ជ្រូក និងសំណង់ ហើយរហូតមកដល់ពេលនេះមានក្រុមហ៊ុន ១ ទៅ ២ ប៉ុណ្ណោះបានឆ្លើយតបមានតម្រូវការពលករជាង ១ ០០០ នាក់ ខណៈពលករមួយចំនួនទៀតត្រូវរង់ចាំឯកសារពីភាគីថៃ និងវីសាទើបអាចកំណត់ការនាំចេញបាន"។

លោក អន ប៊ុនហាក់ បានបញ្ជាក់ថា ពលករចំនួន ២២០ នាក់ដែលបានបញ្ជូនកាលពីថ្ងៃទី ០១ កុម្ភៈ គឺធ្វើការនៅរោងចក្រសាច់មាន់ PANU SPOULTRY GROUP CO., LTD. នៅខេត្តឈុនបុរី ដោយពួកគេម្នាក់ៗទទួលបានប្រាក់ខែពី ៥០០ ទៅ ៧០០ ដុល្លារក្នុង១ខែ ហើយពួកគេទទួលបានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីភាគីថៃ ទាំងកន្លែងធ្វើចត្តាឡីស័ក និងការផ្តល់អាហារ ព្រោះពលករខ្មែរមានអាទិភាពជាងគេដោយសារបានចាក់វ៉ាក់សាំងបានគ្រប់ដូសរហូតដល់ដូសជំរុញ ឬដូសទី៣ និងដូសទី៤ ដែលធ្វើឱ្យកម្រិតហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ មានកម្រិតទាបបំផុត។

លោកបានបន្ថែមទៀតថា ពលករខ្មែរដែលអាចទៅធ្វើការនៅប្រទេសថៃត្រូវមានលក្ខខណ្ឌមួយចំនួនដូចជា ត្រូវមានកាតចាក់វ៉ាក់សាំង ធ្វើតេស្តរកជំងឺកូវីដ-១៩ រយៈពេល ៧២ ម៉ោង តាមម៉ាស៊ីន PCR ឬតេស្តរហ័សដែលធ្វើដោយគ្រូពេទ្យជំនាញដើម្បីបញ្ជាក់វិញ្ញាបនបត្រថាមិនមានឆ្លងជំងឺកូវីដ-១៩។ ពេលទៅដល់ព្រំដែនពលករត្រូវធ្វើតេស្ត ហើយបើលទ្ធផលតេស្តអវិជ្ជមានត្រូវបន្តធ្វើចត្តាឡីស័ករយៈពេល ៧ ថ្ងៃ និងថ្ងៃទី៧ ត្រូវធ្វើតេស្តម្តងទៀត បើលទ្ធផលនៅអវិជ្ជមានទៀតទើបអនុញ្ញាតឱ្យទៅរោងចក្រធ្វើការតែម្តង។ លោក អន ប៊ុនហាក់ បានឱ្យដឹងទៀតថា ក្នុងករណីមានវិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនទៅកន្លែងព្យាបាល ហើយរាល់កាចំណាយទៅលើការព្យាបាលជាបន្ទុករបស់និយោជកថៃទាំងស្រុង៕ អត្ថបទ៖ សំអឿន

## ក្រុមពលករខ្មែរ
## ជំបូងដែលត្រូវបានព្រមព្រៀងក្រោមអនុស្សរណៈការងារបានមកដល់ប្រទេសថៃ

https://www.khmertimeskh.com/ Khmer Times February 3, 2022

បច្ចុប្បន្នប្រទេសថៃត្រូវការពលករចំណាកស្រុកប្រមាណ ៨០០,០០០ នាក់ ដើម្បីបម្រើវិស័យផលិតកម្ម ទេសចរណ៍ និងសេវាកម្ម និងដើម្បីដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្ម រដ្ឋាភិបាលថៃបានចុះហត្ថលេខាលើអនុស្សរណៈ ជាមួយកម្ពុជា មីយ៉ាន់ម៉ា និងឡាវ ដែលអនុញ្ញាតឱ្យពលករមកពីប្រទេសទាំងនេះមានការងារធ្វើនៅក្នុងប្រទេសថៃ។

ថៃបានបើកព្រំដែនរបស់ខ្លួនឡើងវិញជាមួយកម្ពុជា ដើម្បីដោះស្រាយកង្វះកម្លាំងពលកម្មដែលបង្កឡើងដោយជំងឺរាតត្បាតកូវីដ-១៩។ អភិបាលរងខេត្តស្រះកែវ លោក Nattachai Nampoonsuksan បានរាយការណ៍

ថា ពលករខ្មែរសរុបចំនួន ១៨៤នាក់ បានឆ្លងកាត់ប៉ុស្តិ៍ត្រួតពិនិត្យ Ban Khlong Luek ក្នុងស្រុក Aranyaprathet ក្នុងខេត្តស្រះកែវ កាលពីថ្ងៃអង្គារ ទី ១ ខែ កុម្ភៈ។ ក្រុមនេះស្ថិតក្នុងចំណោមពលករចំណាកស្រុកដែលត្រូវបានអនុញ្ញាតឱ្យធ្វើការក្នុងប្រទេសថៃក្រោមអនុស្សរណៈនៃការយោគយល់ការងារដែលបានចុះហត្ថលេខារវាងប្រទេសថៃ និងប្រទេសជិតខាង។

យោងតាមសហព័ន្ធឧស្សាហកម្មថៃ បច្ចុប្បន្ននេះប្រទេសថៃ ត្រូវការពលករចំណាកស្រុកប្រមាណ ៨០០,០០០ នាក់ ដើម្បីបម្រើដល់វិស័យផលិតកម្ម ទេសចរណ៍ និងសេវាកម្ម។ ដើម្បីដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្ម រដ្ឋាភិបាលថៃបានចុះហត្ថលេខាលើអនុស្សរណៈ ជាមួយប្រទេសកម្ពុជា មីយ៉ាន់ម៉ា និងឡាវ ដោយអនុញ្ញាតឱ្យពលករមកពីប្រទេសទាំងនេះមានការងារធ្វើនៅក្នុងប្រទេសថៃ។ និយោជកក្នុងប្រទេសថៃត្រូវបានក្រសួងការងារតម្រូវឱ្យបង់ថ្លៃធ្វើចត្តាឡីស័កចំនួន ៨,៥០០ បាតសម្រាប់ពលករបរទេសម្នាក់ៗដែលបានចុះឈ្មោះ។ កម្មករម្នាក់ៗត្រូវចំណាយពេល១សប្តាហ៍ធ្វើចត្តាឡីស័ក ខណៈដែលអ្នកដែលមិនទាន់បានចាក់វ៉ាក់សាំង នឹងត្រូវបានចាក់វ៉ាក់សាំង។

នាយកដ្ឋានការងាររបស់ក្រសួងបានបើកបណ្តាញសម្រាប់ប្រតិបត្តិករអាជីវកម្មដើម្បីស្នើសុំជួលកម្មករចំណាកស្រុក ជាមួយនឹងក្រុមហ៊ុនដែលអាចបង់ថ្លៃលិខិតអនុញ្ញាតការងារ និងការធ្វើចត្តាឡីស័កសម្រាប់បុគ្គលិករបស់ពួកគេចុះឈ្មោះក្នុងដំណើរការនេះ។ រយៈពេលចុះឈ្មោះសម្រាប់នាំពលករបរទេសបញ្ចប់នៅថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០២៣៕ *(NNT)/Pattaya Mail*

## ប្រទេសថៃអនុញ្ញាតឱ្យពលករចំណាកស្រុករួមទាំងពលករចំណាកស្រុកមកពីកម្ពុជាស្នាក់នៅរយៈពេល៦ខែទៀតបន្តទៀត

https://www.khmertimeskh.com/ Khmer Times February 4, 2022

ក្រសួងការងារកំពុងពិភាក្សាជាមួយប្រទេសជិតខាងក្រោមអនុស្សរណៈនៃការយោគយល់គ្នា ដើម្បីអនុញ្ញាតឱ្យពលករចំណាកស្រុក ដែលបានបញ្ចប់អាណត្តិធ្វើការរយៈពេល ៤ ឆ្នាំនៅឆ្នាំនេះ អាចបន្តការងារក្នុងប្រទេសថៃបានរយៈពេល៦ខែទៀត។

លោក Boonchob Suttamanaswong រដ្ឋលេខាធិការប្រចាំការរបស់រដ្ឋមន្ត្រីបាននិយាយថាគោលបំណងនេះគឺដើម្បីជួយអាជីវកម្មដែលពឹងផ្អែកលើពលករចំណាកស្រុកដើម្បីអោយដំណើរការលក់មានភាពរលូនក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ-១៩។ លោកបានថ្លែងបន្ទាប់ពីកិច្ចប្រជុំរបស់គណៈកម្មាធិការគោលនយោបាយស្តីពីការគ្រប់គ្រងពលករចំណាកស្រុក។ លោកបានបន្តទៀតថា គោលបំណងគឺដើម្បីការពារការខ្វះខាតកម្លាំងពលកម្ម និងធានាបរិយាកាសការងារអោយមានសុវត្ថិភាពពីកូវីដ-១៩ ដោយធានាថាបុគ្គលិកដដែលអាចនៅធ្វើការជាមួយក្រុមហ៊ុនបានយូរ។

កម្ពុជាមានពលករចំណាកស្រុកប្រមាណ២០ម៉ឺននាក់ ដែលធ្វើការនៅប្រទេសថៃ ក្នុងវិស័យផ្សេងៗ ដូចជាផលផល កសិដ្ឋាន រោងចក្រកែច្នៃត្រី និងផ្លែឈើ ធ្វើការតាមផ្ទះ និងសំណង់ជាដើម។ ពលករចំណាកស្រុកកម្ពុជាមានចំនួនច្រើនជាងគេទីពីរ នៃពលករបរទេសនៅប្រទេសថៃ បន្ទាប់ពីប្រទេសមីយ៉ាន់ម៉ា។ ពលករចំណាកស្រុកកម្ពុជាជាង ៣៨៥.០០០នាក់ បានចាក់វ៉ាក់សាំងនៅប្រទេសថៃ។ Bangkokpost/Khmer Times

# ថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ២០២២

## ពលករចំណាកស្រុកជាង ១ពាន់នាក់ បានការងារស្របច្បាប់នៅថៃ

https://www.khmertimeskh.com/ ទិត្យ គង់នៅ / Khmer Times February 4, 2022

កម្ពុជានឹងបញ្ជូនពលករចំណាកស្រុកជាង ១.០០០នាក់ ទៅប្រទេសថៃក្នុងខែនេះ ដើម្បីធ្វើការសំណង់ និងនៅរោងចក្រកែច្នៃសាច់ ក្រោមអនុស្សរណៈនៃការយោគយល់គ្នាថ្មី (MoU) ។

ប្រធានសមាគមទីភ្នាក់ងារការងារហត្ថពលកម្មកម្ពុជា លោក អន ប៊ុនហាក់ បាននិយាយកាលពីម្សិលមិញថា ប្រទេសថៃបានប្រកាសថា នឹងបញ្ជូនពលករប្រមាណ ៤០០ នាក់នៅថ្ងៃទី ២១ ខែកុម្ភៈ និង ៤០០ នាក់ទៀតនៅថ្ងៃទី ២៨ ខែកុម្ភៈ ដើម្បីធ្វើការឱ្យក្រុមហ៊ុនអាហារដ៏ធំរបស់ប្រទេសថៃ គឺក្រុមហ៊ុន CP ខណៈក្រុមហ៊ុនខ្លះត្រូវការកម្មករតែ ១០ ឬ ២០ នាក់ប៉ុណ្ណោះ។ លោកថា៖ «យើងបានស្នើសុំទៅភាគីថៃសម្រាប់កម្មករពី ៣000 ទៅ ៣ ៥00 នាក់ ដែលបានដាក់ពាក្យទៅធ្វើការស្របច្បាប់នៅក្នុងប្រទេសថៃ ក្នុងឧស្សាហកម្មម្ហូបអាហារ ដូចជាការកែច្នៃសាច់មាន់ និងសាច់ជ្រូក ក៏ដូចជានៅក្នុងការសាងសង់»។ លោកបានបន្ថែមថា មកដល់ពេលនេះ មានតែក្រុមហ៊ុនមួយ ឬពីរប៉ុណ្ណោះដែលបានឆ្លើយតប។

លោកថា ពលករជាង១ពាន់នាក់បានត្រៀមរួចរាល់ ខណៈខ្លះទៀតត្រូវរង់ចាំឯកសារពីភាគីថៃ និងសម្រាប់ទិដ្ឋាការ ទើបអាចកំណត់កាលបរិច្ឆេទចេញទៅធ្វើការនៅប្រទេសថៃបាន។ លោក ប៊ុនហាក់ បញ្ជាក់ថា កម្មករចំនួន ២២០នាក់ ដែលត្រូវបានបញ្ជូនកាលពីថ្ងៃអង្គារ កំពុងធ្វើការនៅក្រុមហ៊ុន Panus Poultry Group Co Ltd ក្នុងខេត្តឈុនបុរី។ ពួកគេម្នាក់ៗនឹងទទួលបានប្រាក់ខែពី ៥00 ទៅ ៧00 ដុល្លារក្នុងមួយខែ។ លោកថា ពលករនៅប្រទេសថៃ នឹងទទួលបានការយកចិត្តទុកដាក់ច្រើនជាងពលករចំណាកស្រុកដទៃទៀត សម្រាប់ការស្នាក់នៅ និងអាហារ ព្រោះពួកគេមានអាទិភាពខ្ពស់បំផុត ដោយសារពួកគេត្រូវបានចាក់វ៉ាក់សាំងពេញលេញ ហើយហានិភ័យនៃការឆ្លងជំងឺកូវិត១៩ របស់ពួកគេទាបណាស់។ លោកថា ពលករខ្មែរដែលអាចទៅធ្វើការនៅប្រទេសថៃបានត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចជា ចាក់វ៉ាក់សាំងកូវិត១៩ពេញលេញ និងធ្វើតេស្តអវិជ្ជមាន ៧២ ម៉ោងមុនពេលមកដល់ ដែលធ្វើឡើងដោយអ្នកឯកទេសដើម្បីបញ្ជាក់លទ្ធផលអវិជ្ជមានកូវិត១៩។

លោកបានបញ្ជាក់បន្ថែមថា នៅពេលដែលកម្មករទៅដល់ព្រំដែន ពួកគេត្រូវបានធ្វើតេស្ត ហើយប្រសិនបើលទ្ធផលអវិជ្ជមាន ពួកគេនៅតែត្រូវធ្វើតេស្តរយៈពេលប្រាំពីរថ្ងៃ មុនពេលពួកគេត្រូវបានអនុញ្ញាតឱ្យចូលរោងចក្រ។ ប្រសិនបើពួកគេធ្វើតេស្តវិជ្ជមាន ពួកគេត្រូវបានបញ្ជូនទៅមជ្ឈមណ្ឌលព្យាបាល ហើយការចំណាយលើការព្យាបាលទាំងអស់គឺជាបន្ទុករបស់និយោជកថៃ។

កាសែតបាងកកប៉ុស្តិ៍កាលពីសប្តាហ៍មុនបានរាយការណ៍ថារដ្ឋាភិបាលបានចុះហត្ថលេខាលើ MoU ជាមួយប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ាកាលពីខែធ្នូឆ្នាំមុន ដើម្បីធានាឱ្យមានតុល្យភាពដ៏ល្អរវាងការទប់ស្កាត់ការរីករាលដាលនៃមេរោគកូវិត១៩ និងឆ្លើយតបទៅនឹងតម្រូវការកើនឡើងសម្រាប់ពលករចំណាកស្រុក ។ នេះបើតាមរដ្ឋមន្ត្រីក្រសួងការងារលោក Suchart Chomklin បានមានប្រសាសន៍។ លោកបន្តថា ពលករខ្មែរទាំងនេះត្រូវនាំចូលតាមសំណើរបស់និយោជកនៅខេត្តឈុនបុរី និងអយុធ្យា។ សម្រួលដោយ៖ សុ ជាតា

## រកឃើញពលករខ្មែរម្នាក់កើតជំងឺកូវីដ ក្នុងចំណោមពលករខ្មែរត្រឡប់មកពីថៃ២៨៤នាក់

https://kbn.news/ February 4, 2022

**ខេត្តបាត់ដំបង៖** នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២ កម្លាំងសមត្ថកិច្ចស្នងការនគរបាលខេត្តបាត់ដំបង សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យ បានទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង។ សមត្ថកសិច្ច បានឲ្យដឹងថា ពលករដែលវិលត្រលប់មកកម្ពុជាវិញ សរុបចំនួន២៨៤នាក់, ស្រី១០៩នាក់ និងក្មេង៣៨នាក់។ បន្ទាប់ពីសាកសួរកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩រួចរាល់ ក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័ស និងជាលទ្ធផល គឺវិជ្ជមានកូវីដ-១៩ម្នាក់។ ក្នុងនោះពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន២៣៤នាក់ (ស្រី៨៧នាក់, ក្មេង៣២នាក់) ចំណែកពលករចំនួន៥០នាក់, ស្រី២២នាក់ និងក្មេង៦នាក់ ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ដោយបានចាក់វ៉ាក់សាំងអោយក្មេងចាប់ពីអាយុ ៥ឆ្នាំ ដល់ ១៨ឆ្នាំ ចំនួន១៦នាក់ (ស្រី៩នាក់) ហើយក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ។

## ក្មេងស្រីខ្មែរ២នាក់បងប្អូន ត្រូវម្ដាយបោះបង់ចោលកណ្ដាលទីក្រុងបាងកក

https://www.kampucheathmey.com/ ថ្ងៃសុក្រ ៤ កុម្ភៈ ២០២២ដោយ Kang Tola

ក្មេងស្រីវ័យជាង១០ឆ្នាំ ២នាក់បងប្អូន កំពុងទទូចសុំឲ្យសមត្ថកិច្ចថៃ ជួយបញ្ជូនពួកគេមកកាន់ប្រទេសកម្ពុជាវិញ បន្ទាប់ពីត្រូវបានម្ដាយបង្កើតបោះបង់ចោល នៅកណ្ដាលទីក្រុងបាងកក។ កាលពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២២ ប៉ូលិសថៃបាននាំក្មេងស្រី២នាក់ ដែលជាជនជាតិខ្មែរ កំពុងដើរគ្មានគោលដៅនៅតាមវាលឆ្នេរសមុទ្រផាត់តាយ៉ា ប៉ុន្មានថ្ងៃមកហើយ ដោយមិនមានឃើញឪពុក ម្ដាយ ឬបងប្អូនមកជាមួយសោះ។ នៅចំពោះមុខសមត្ថកិច្ច ក្មេងស្រីខ្មែរទាំង២នាក់ ដែលបងឈ្មោះ សុមាលី អាយុ១៥ឆ្នាំ និងប្អូនឈ្មោះ ណាណា អាយុ១២ឆ្នាំ បានរៀបរាប់ថា នាងមានម្ដាយ និងប្អូន១នាក់ទៀត ព្រមទាំងបានមករស់នៅ ផាត់តាយ៉ា រយៈពេលជាង២ឆ្នាំ មកហើយ ដោយកាលណោះស្នាក់នៅផ្ទះជួល ហើយម្ដាយរបស់នាងបានប្ដីជាជនបរទេស។

មួយរយៈក្រោយមកម្ដាយនាងបានបែកបាក់គ្នា ដោយប្ដីដែលជាជនបរទេសនោះក៏បានត្រឡប់ទៅស្រុកគាត់វិញ និងបានផ្ដាច់ជំនួយទាំងអស់ ដែលធ្វើអោយម្ដាយ និងពួកនាងត្រូវចាកចេញពីផ្ទះជួល មករស់នៅតាមឆ្នេរសមុទ្រ និងគ្មានគោលដៅ។ នាងសុមាលី បានរៀបរាប់បន្តថា ទីបំផុតនៅចុងខែមករា នេះ ម្ដាយនាងបាននាំពួកនាងជិះឡានក្រុងទៅកាន់ទីក្រុងបាងកក ដោយពេលទៅដល់ទីនោះ ម្ដាយបានប្រាប់ពួកនាងទាំង២នាក់ថា អោយចាំមួយភ្លែត រួចគាត់ក៏ពរប្អូនដើរចេញទៅបាត់ ដោយមិនឃើញត្រឡប់មកវិញឡើយ ហេតុរយៈពេល២ថ្ងៃ ទើបមានតម្រួតមកសួរនាំ។

នៅក្នុងទីក្រុងបាងកក នាងបានសំណូមពរដល់សមត្ថកិច្ចថៃ សុំឲ្យជួយបញ្ជូននាងមកកាន់ប្រទេសកម្ពុជាវិញ ប៉ុន្តែដោយសារសមត្ថកិច្ចមិនអាចសម្រេចបាន ទើបពួកនាងសុំអោយបញ្ជូនទៅកាន់ផាត់តាយ៉ា ដោយប៉ូលិសយល់ព្រមដោយបានចេញសោហ៊ុយឡានក្រុង និងប្រាក់កាសមួយចំនួនតូចសម្រាប់ចាយវាយ។ ទីបំផុតនាងបាននាំប្អូនស្រីធ្វើដំណើរទៅកាន់ឆ្នេរសមុទ្រដូចដើមក្រែងបានជួបនឹងអ្នកម្ដាយវិញ ប៉ុន្តែអ្វីៗមិនបានដូចបំណងឡើយ។ បច្ចុប្បន្នតម្រួតប្រចាំតំបន់ផាត់តាយ៉ាកំពុងទាក់ទងទៅខាងអន្តោប្រវេសន៍ដើម្បីសម្របសម្រួល និងបានបញ្ជូននាងទៅកាន់ស្រុកកំណើតវិញតាមសំណូមពរ ដោយឡែកម្ដាយនាងគឺបាត់ដំណឹងឈឹងតែម្ដង៕ *សោ និយមរ័ត្ន*

## អាជ្ញាធរបញ្ជូនពលករពីថៃ ១២៩នាក់ទៅមណ្ឌលចត្តាឡីស័ក

https://www.khmertimeskh.com/ ខ្មែរថាមស៍ February 4, 2022

អាជ្ញាធរនៅតាមខ្សែបន្ទាត់ព្រំដែននៃស្រុកកំរៀង ខេត្តបាត់ដំបង បានសម្រេចធ្វើការបញ្ជូនពលករខ្មែរចំនួន ១២៩នាក់ ក្នុងចំណោមពលករចំនួន៥៧៧នាក់ ដែលថៃបញ្ជូនមកប្រទេសកម្ពុជាវិញ ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២២នេះ ទៅកាន់មណ្ឌលចត្តាឡីស័កគីឡូ៩ ស្រុកសំពៅលូន ក្នុងនោះ ក៏បានរកឃើញស្រ្តីម្នាក់មានផ្ទុកមេរោគកូវីដ-១៩ ហើយត្រូវបានបញ្ជូនទៅមណ្ឌលព្យាបាលផងដែរ។ ការបញ្ជូនពលករទាំង៥៧៧នាក់ ទៅធ្វើចត្តាឡីស័ក និងព្យាបាលជំងឺកូវីដ-១៩ នាពេលនេះធ្វើឡើង បន្ទាប់ពីខាងភាគីថៃ បានបញ្ជូនពលករខ្មែរចូលមកប្រទេសកម្ពុជាវិញ តាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង និង បន្ទាប់ពីមន្ត្រីជំនាញបានរកឃើញពួកគាត់មានកាតចាក់វ៉ាក់សាំងកូវីដ-១៩ហើយ តែស្តែនមិនចេញទិន្នន័យ ហើយពកលរជាស្ត្រីម្នាក់មានវិជ្ជមានកូវីដ-១៩ ។ នេះបើតាមការផ្តល់ព័ត៌មានពីនាយការិយាល័យផ្សព្វផ្សារអប់រំនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង លោកវរៈសេនីយ៍ឯក សួន ស៊ីវ៉ា នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២២នេះ ដោយលោកបានបញ្ជាក់ទៀតថា ចំពោះពលករចំនួន៤៤៧នាក់ ដែលមានកាតចាក់វ៉ាក់សាំងបានត្រឹមត្រូវ ត្រូវបានក្រុមគ្រូពេទ្យអនុញ្ញាតឲ្យវិលប្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនវិញ បន្ទាប់ពីបានយកសំណាកធ្វើតេស្តរហ័ស ដោយឧបករណ៍ Rapidtest មានលទ្ធផលអវិជ្ជមានទាំងអស់គ្នា៕

## សមត្ថកិច្ចនៅប៉ុស្តិ៍
## ព្រំដែនអូរអន្លក់ក្នុងស្រុកកំរៀងបានទទួលពលករខ្មែរ ២៨៤ នាក់ ដែលថៃបញ្ជូនមកវិញ

https://www.postkhmer.com/ ភ្នំពេញ ប៉ុស្តិ៍ | Publication date 04 February 2022 | 15:13 ICT

**បាត់ដំបង:** កម្លាំងនគរបាលប៉ុស្តិ៍ព្រំដែនអូរអន្លក់ក្នុងឃុំតាសែន ស្រុកកំរៀង សហការជាមួយកម្លាំងកងយោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យនៅថ្ងៃទី ៤ ខែកុម្ភៈបានទទួលពលករខ្មែរចំនួន ២៨៤ នាក់ ដែលថៃបញ្ជូនត្រឡប់មកវិញ។ បើតាមអគ្គស្នងការដ្ឋាននគរបាលជាតិ ពលករខ្មែរដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀងនោះមានចំនួន ២៨៤ នាក់ (ស្រី ១០៩ នាក់) ក្មេង ៣៨ នាក់ (ក្មេងស្រី ២០ នាក់) ត្រូវបានសមត្ថកិច្ចខ្មែរនៅច្រកព្រំដែនបានធ្វើការសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងធ្វើការអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវីដ ១៩។ បន្ទាប់ពីសមត្ថកិច្ចបានកត់ឈ្មោះ និងសួរនាំរួចមក ក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័សជាលទ្ធផល អវិជ្ជមានកូវីដ ១៩ ទាំងអស់។ ក្នុងនោះពលករចំនួន ៥០ នាក់ (ស្រី ២២ នាក់) ក្មេង ០៦ នាក់ (ក្មេងស្រី ០៥ នាក់) ដែលមិនទាន់បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ ១៩ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ ៩ ក្នុងស្រុកសំពៅលូន។ ចំណែកពលករដែលមានកាតចាក់វ៉ាក់សាំងចំនួន ២៣៤ នាក់ (ស្រី ៨៧ នាក់) ក្មេង ៣២ នាក់ (ក្មេងស្រី ១៥ នាក់) និងក្មេងចាប់ពីអាយុ ០៥ ឆ្នាំដល់ ១៨ ឆ្នាំ ត្រូវបានក្រុមគ្រូពេទ្យចាក់វ៉ាក់សាំងឱ្យចំនួន ១៦ នាក់ (ស្រី ០៩ នាក់) ត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ៕

## ភាគីថៃ បានបញ្ជូនពលករខ្មែរចំនួន ២៦៦នាក់ មកតាមច្រកតំបន់អូរអន្លក់

https://cen.com.kh/ Posted ByPen Srey NeatFebruary 6, 2022

បាត់ដំបង ៖ ទីបញ្ជាការវរសេនាតូចលេខ ៨១៩ ស្រុកកំរៀង-ស្រុកភ្នំព្រឹក បានឲ្យដឹងថា នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរៈ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់សហការជាមួយកម្លាំងកងឃោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យ បានទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃ បានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង។ បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩ រួច ចំនួន២៦៦នាក់ ស្រី១០៩នាក់ ក្មេង៤២នាក់ ស្រី១៧នាក់ កម្លាំងយើងបានកត់ឈ្មោះរួច ក្រុមគ្រូពេទ្យធ្វើតេសរហ័ស ។ ជាលទ្ធផល អវិជ្ជមានកូវីដ១៩ ទាំងអស់ , ពលករចំនួន ៥១នាក់ ស្រី២១នាក់ ក្មេង៦នាក់ បញ្ជូនទៅធ្វើចត្តាឡីស័ក នៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន, ពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន២១៥នាក់ ស្រី៨៨នាក់ ក្មេង៣៦នាក់ ស្រី១៧នាក់ ក្នុងនោះបានចាក់វ៉ាក់សាំង ឲ្យក្មេងចាប់ពីអាយុ៥ឆ្នាំដល់១៨ឆ្នាំ ចំនួន១៦ ស្រី៩នាក់, ក្រុមគ្រូពេទ្យអនុញ្ញាត ឲ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ៕ សុទ្ធ លី

## នគរបាលស្រុកកំរៀង ឃាត់ខ្លួនមេខ្យល់ម្នាក់ បម្រុងនាំពលរដ្ឋឆ្លងដែន ទៅប្រទេសថៃ

https://cen.com.kh/ Posted ByPen Srey NeatFebruary 6, 2022

បាត់ដំបង ៖ ដោយមានការសម្របសម្រួលនីតិវិធីពីឯកឧត្តម កែវ សុជាតិ ព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង១៧និង០០នាទី លោកវរសេនីយ៍ទោ វេ គឹមចត់ អធិការនគរបាលស្រុកកំរៀង ដឹកនាំកម្លាំងសហការជាមួយកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៩ ដែលមានលោកវរសេនីយ៍ឯក ម៉ង់ ស៊ី ជាមេបញ្ជាការបង្រ្កាបករណីនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន១ករណី ក្នុងបទល្មើសជាក់ស្តែង។ សមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យ ជាមេខ្យល់ម្នាក់ និងទប់ស្កាត់ពលករបម្រុងឆ្លងដែនចំនួន០៣នាក់ (ស្រី០២នាក់) អនីតិជន។ ជនសង្ស័យជាមេខ្យល់ឈ្មោះ រិទ្ធ វាសនា ហៅ យ៉ត ភេទប្រុស អាយុ៣៦ឆ្នាំ រស់នៅភូមិដូង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង មុខរបរ កម្មករ ។ ជនសង្ស័យ ត្រូវបានសមត្ថកិច្ចនគរបាលស្រុក កសាងសំណុំរឿងបញ្ជូនទៅ ការិយាល័យជំនាញដើម្បីអនុវត្តតាមច្បាប់ ។ រីឯប្រជាពលរដ្ឋរងគ្រោះបានអប់រំណែនាំឱ្យវិលទៅលំនៅដ្ឋានវិញ ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

## ក្នុងចំណោម ៦ ប្រទេស ថៃមានពលករខ្មែរទៅធ្វើការច្រើនជាងគេ

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ៦ កុម្ភៈ ២០២២ដោយ Dy Bunnara

បច្ចុប្បន្ននេះកម្ពុជាបានបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសចំនួន ៦ ប្រទេស ហើយក្នុងនោះមានតែប្រទេសថៃមានពលករទៅធ្វើការច្រើនជាងគេ។

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជាបានឱ្យដឹងនៅព្រឹកថ្ងៃទី០៦ កម្ភៈនេះថា ក្នុងវិបត្តិកូវីដ១៩នេះ មានតែប្រទេសថៃទេ ដែលបានបើកប្រទេសទទួលពលករទៅធ្វើការក្នុងចំណោម ៦ប្រទេស។ ចំណែក ៥ ប្រទេសផ្សេងទៀត នៅមិនទាន់បើកព្រំដែនទទួលពលករធ្វើការនៅឡើយទេ។ បើតាមប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា ក្នុងចំណោម ៦ ប្រទេសដែលកម្ពុជាបញ្ជូនពលករទៅធ្វើការនោះមានតែប្រទេសថៃ

ទេមានពលករធ្វើការច្រើនជាងគេដោយមានប្រមាណ ១លាន២សែននាក់ បន្ទាប់មកកូរ៉េខាងត្បូង ជប៉ុន សឹង្ហបុរី ហុងកុងនិង ម៉ាឡេស៊ី។ លោក អន ប៊ុនហាក់ បានបញ្ជាក់ថា បើទោះបីជាថៃបើកទទួលពលករក៏ពិតមែន ថៃបានមានអាទិភាពពលករខ្មែរមុនគេដោយសារពលករខ្មែរ ដោយសារបានចាក់វ៉ាក់សាំងបានគ្រប់ដូសរហូតដល់ដូសជំរុញឬដូសទី៣និងដូសទី៤ ដែលធ្វើឱ្យកម្រិតហានិភ័យនៃការឆ្លងជំងឺកូវីដ១៩មានកម្រិតទាបបំផុត។

ជាក់ស្តែងកម្ពុជាបានបញ្ជូនពលករ MOU ជាលើកដំបូងចំនួន២២០នាក់កាលពីថ្ងៃទី០១ខែកម្ភៈឆ្នាំ២០២២ ដោយធ្វើការនៅរោងចក្រសាច់មាន់ PANU SPOULTRY GROUP CO., LTD. នៅខេត្តឈុនបុរីដោយពួកគេម្នាក់ៗទទួលបានប្រាក់ខែពី ៥០០ ទៅ ៧០០ដុល្លារក្នុង១ខែ ហើយក៏ទទួលបានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីភាគីថៃទាំងកន្លែងធ្វើចត្តាឡីស័ក និងការផ្តល់អាហារ។ នៅនៅចុងខែនេះកម្ពុជានឹងបញ្ជូនពលករ MOU ចំនួន៨០០នាក់បន្ថែមទៀតទៅធ្វើការនៅថៃនឹងត្រូវបញ្ជូនទៅពីរលើកគឺនៅថ្ងៃទី២១និងថ្ងៃទី២៨ខែកម្ភៈឆ្នាំ២០២២ ដោយទៅធ្វើការនៅក្រុមហ៊ុនស៊ីភីផ្នែកចំណីអាហារដ៏ធំរបស់ថៃ និងបញ្ជូនទៅធ្វើការនៅតាមក្រុមហ៊ុនតូចៗដែលមានតម្រូវការពលករពី១០ឬ២០នាក់ជាបន្តបន្ទាប់ទៀត។

ពលករខ្មែរដែលអាចទៅធ្វើការនៅប្រទេសថៃ ត្រូវមានលក្ខខណ្ឌមួយចំនួនដូចជាត្រូវមានកាតចាក់វ៉ាក់សាំង ធ្វើតេស្តរកជំងឺកូវីដ១៩ រយៈពេល៧២ម៉ោងតាមម៉ាស៊ីនPCR ឬតេស្តរហ័សដែលធ្វើដោយគ្រូពេទ្យជំនាញដើម្បីបញ្ជាក់វិញ្ញាបនបត្រថា មិនមានឆ្លងជំងឺកូវីដ១៩។ ពេលទៅដល់ព្រំដែនពលករត្រូវធ្វើតេស្តហើយបើលទ្ធផលតេស្តអវិជ្ជមានត្រូវបន្តធ្វើចត្តាឡីស័ករយៈពេល៧ថ្ងៃ និងថ្ងៃទី៧ត្រូវធ្វើតេស្តម្តងទៀតហើលទ្ធផលនៅអវិជ្ជមានទៀតទើបអនុញ្ញាតឱ្យទៅរោងចក្រធ្វើការតែម្តង។ លោក អន ប៊ុនហាក់ បានឲ្យដឹងថា ក្នុងករណីមានវិជ្ជមានកូវីដ១៩ត្រូវបញ្ជូនទៅកន្លែងព្យាបាល ហើយរាល់ការចំណាយទៅលើការព្យាបាលជាបន្ទុករបស់និយោជកថៃទាំងស្រុង៕ សំអឿន

## ថ្ងៃទី០៨ ខែ កុម្ភៈ ឆ្នាំ២០២២

### អាជ្ញាធរស្រុកសំពៅលូន បន្តទទួល

### ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/02/06/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៨និង០០នាទី នាថ្ងៃអាទិត្យ ៥កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០២នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០៨នាក់ (ស្រី០៣នាក់ ក្មេង០២នាក់ ក្មេងស្រី០១នាក់)។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើការកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីត្រួតពិនិត្យសម្ភារៈហាមឃាត់ (ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក) ជាលទ្ធផល មិនមាន រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺអវិជ្ជមាន បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន០៧នាក់ ស្រី០២នាក់ ក្មេង០២នាក់ ក្មេងស្រី០១នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ) ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្ដែនអត់ចេញ ចំនួន០១នាក់ (ស្រី) ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័ក ចំណុចរោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## កងកម្លាំងអាជ្ញាធរ បន្តទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃ បញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្រុកកំរៀង

https://gdlf-kh.com/ 2022/02/06/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរៈ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យ បានទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង។ ពលករដែលវិលត្រលប់មកកម្ពុជាវិញ សរុបចំនួន២៦៦នាក់, ស្រី១០៩នាក់ និងក្មេង៤២នាក់ បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩រួចរាល់ ក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័ស និងជាលទ្ធផល គឺវិជ្ជមានកូវីដ-១៩ ម្នាក់។ ក្នុងនោះពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន២១៥នាក់ (ស្រី៨៨នាក់, ក្មេង៣៦នាក់) ចំណែកពលករចំនួន៥១នាក់, ស្រី២១នាក់ និងក្មេង៦នាក់ ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ដោយបានចាក់វ៉ាក់សាំងអោយក្មេងចាប់ពីអាយុ ៥ឆ្នាំ ដល់ ១៨ឆ្នាំ ចំនួន១៦នាក់ (ស្រី៩នាក់) ហេីយក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ។

# ថ្ងៃទី០៩ ខែ កុម្ភៈ ឆ្នាំ២០២២

## យុទ្ធនាការគាំទ្រ

## ទិវាអន្តរជាតិ ដើម្បីសុវត្ថិភាពអ៊ីនធឺណិត ក្រោមប្រធានបទ "រួមគ្នាលើកម្ពស់ការពារ និងគោរពសិទ្ធិកុមារ តាមរយៈ ការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយការទទួលខុសត្រូវ"

https://www.information.gov.kh/ AKP ភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស អញ្ជើញជាអធិបតីបើកយុទ្ធនាការគាំទ្រទិវាអន្តរជាតិ ដើម្បីសុវត្ថិភាពអ៊ីនធឺណិត ក្រោមប្រធានបទ "រួមគ្នាលើកម្ពស់ការពារ និងគោរពសិទ្ធិកុមារតាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយការទទួលខុសត្រូវ" នាព្រឹកថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ។

## ទូតអាមេរិកមកទឹកដីខេត្តបន្ទាយមានជ័យដើម្បីស្វែងយល់អំពីសក្តានុពលនិងការជួញដូរមនុស្សឆ្លងដែន

https://www.kampucheathmey.com/ ថ្ងៃអង្គារ ៨ កុម្ភៈ ២០២២ដោយ Kang Tola

បន្ទាយមានជ័យ ៖ ព្រឹកថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២២នេះ លោកតែទ្រីកមើហ្វី ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា បានធ្វើដំណើរទៅកាន់ទឹកដីខេត្តបន្ទាយមានជ័យ ដើម្បីស្វែងយល់អំពីសក្តានុពល នៃខេត្តជាប់ព្រំដែនមួយនេះ ព្រមទាំងសកម្មភាពនៃការជួញដូរមនុស្សឆ្លងដែន និងវិស័យសុខាភិបាលផងដែរ ក្នុងដំណើរទេស្សនកិច្ចនោះលោកទូតក៏បានជួបពិភាក្សាការងារជាមួយលោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានមានជ័យផងដែរ។

លោក អ៊ុំ រាត្រី បានជម្រាបជូនឯកអគ្គរដ្ឋទូតថា ខេត្តបន្ទាយមានជ័យស្ថិតនៅប៉ែកពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជាមានចម្ងាយប្រមាណ៣៥៩គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានព្រំប្រទល់ជាប់ប្រទេសថៃ ប្រវែង១៥៣គីឡូម៉ែត្រ ហើយខេត្តនេះមានផ្ទៃដីសរុប៦.៦៧៩គីឡូម៉ែត្រការ៉េចែកចេញជា២ក្រុង៧ស្រុក ៥៥ឃុំ ១០សង្កាត់ និង ៦៥៨ភូមិមានប្រជាជនពលរដ្ឋប្រមាណ៧៩ម៉ឺននាក់ ក្នុងនោះមាន៨៥% ប្រកបមុខរបរធ្វើស្រែចំការ និង១៥% ជាអាជីវករពាណិជ្ជករសិប្បករកម្មករនេសាទត្រីនិងចិញ្ចឹមសត្វ។ លោកបាននិយាយបន្តថា ខេត្តបន្ទាយមានជ័យមានច្រកសេដ្ឋកិច្ចសំខាន់ៗចំនួន៣ គឺច្រកអន្តរជាតិប៉ោយប៉ែត ច្រកទ្វាបឹងត្រកួន និង ច្រកព្រំដែនម៉ាឡៃ ខេត្តក៏មានតំបន់សេដ្ឋកិច្ចពិសេស៥កន្លែងនៅក្រុងប៉ោយប៉ែត គឺតំបន់សេដ្ឋកិច្ចពិសេសអូរនាង តំបន់សេដ្ឋកិច្ចពិសេសសានកូ តំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែតភីភី តំបន់សេដ្ឋកិច្ចពិសេសលីអ៊ុតនី ព្រមទាំងឧទ្យានឧស្សាហកម្ម១កន្លែង នៅក្រុងសិរីសោភ័ណ។

ដោយឡែកនៅក្រុងប៉ោយប៉ែត មានក្រុមហ៊ុនជប៉ុនចំនួន៦កន្លែង កំពុងដំណើរការនៅតំបន់សេដ្ឋកិច្ចពិសេសសានកូ និង១ក្រុមហ៊ុនទៀត នៅតំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែតភីភី ផលិតសម្ភារៈបរិក្ខារអេឡិចត្រូនិច។ ក្នុងនោះលោកបានថ្លែងអំណរគុណដល់ប្រជាជន និងរដ្ឋាភិបាលសហរដ្ឋអាមេរិកតាមរយៈការខិតខំប្រឹងប្រែងរបស់សម្តេចតេជោហ៊ុន សែន នាយករដ្ឋមន្ត្រី ក្នុងកម្មវិធីCOVAXបានផ្តល់វ៉ាក់សាំងJohnsonandJohnson សម្រាប់ការជូនប្រជាពលរដ្ឋក្នុងខេត្តបន្ទាយមានជ័យមួយចំនួនផងដែរដែលខេត្តទទួលបានពីថ្នាក់ជាតិផ្តល់មក។

លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជាបានលើកថា ប្រតិភូស្ថានទូតមកទស្សនកិច្ចនៅខេត្តបន្ទាយមានជ័យក្នុងគោលបំណងចង់សិក្សាស្វែងយល់ពីសក្តានុពលខេត្ត បញ្ហាការជួញដូរមនុស្សឆ្លងដែន និងផ្នែកសុខាភិបាលផ្នែកអប់រំ។ លោកទូតបានគូសបញ្ជាក់ថា លោកពិតជារីករាយដែលបានមកកាន់ខេត្តបន្ទាយមានជ័យជាលើកទី២ ដែលលោកបានអញ្ជើញមកកាលពី៨ឆ្នាំមុន ជាមួយក្រុមគ្រួសារក្នុងដំណើរទេស្សនកិច្ចសិក្សាស្វែងយល់ និងបំពេញបេសកកម្មការងារមួយចំនួននាពេលនោះ៕ *ដោយ ៖ វ៉ាន់ណាង*

## អាជ្ញាធរស្រុកសំពៅលូន នៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ និងប្រគល់ទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣

https://gdlf-kh.com/ 2022/02/08/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃអង្គារ ៧កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ

មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្ត្រ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង សរុបបានចំនួន០៥នាក់ ស្រី០២នាក់។ ក្រោយពីទទួលបានកម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំ រួចក៏បានប្រគល់បងប្អូនទាំងអស់អោយទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣។

## អាមេរិកសន្យា
## ជួយលើកកម្ពស់សុខភាពសាធារណៈ និងវិស័យអាទិភាពមួយចំនួនក្នុងខេត្តបាត់ដំបង

https://btv.com.kh/ 02/08/2022 04:02 PM

បាត់ដំបង៖ លោកស្រី ណែនសុី អ៊ីសលីក នាយិកាបេសកកម្មភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់ការអភិវឌ្ឍអន្តរ ជាតិ (USAID) បានសន្យាបន្តជួយលើកកម្ពស់សេវាសុខភាពសាធារណៈ និងវិស័យអាទិភាពសំខាន់ៗ មួយចំនួនក្នុងខេត្តបាត់ដំបង។ ក្នុងជំនួបពិភាក្សារការងារជាមួយឯកឧត្តម សុខ លូ អភិបាលខេត្តបាត់ដំបង នារសៀលថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ ២០២២ លោកស្រី ណែនសុី អ៊ីសលីក បានរាយការណ៍អំពីលទ្ធផលការងារជាច្រើន ដែលអង្គការUSAID បានសម្រេចកន្លងមក និងលើកទិសដៅសម្រាប់កិច្ចការបន្ទាប់ទៀតក្នុងការចូលរួមអភិវឌ្ឍខេត្តបាត់ដំបង ។ លោកស្រី គូសបញ្ជាក់ថា អង្គការ USAID នឹងបន្តជួយទៅលើគម្រោងនានា ដូចជាលើវិស័យ កសិកម្ម ជួយការបណ្តុះបណ្តាល និងរកទីផ្សារដល់កសិករក្នុងការនាំចេញ វិស័យសុខាភិបាល វិស័យបរិស្ថាន និងវិស័យអប់រំ ក៏ដូចជាគម្រោងទប់ស្កាត់ការជួញដូរមនុស្ស នៅក្នុងខេត្តបាត់ដំបង ។ បន្ថែមពីនេះលោកស្រី ណែនសុី អ៊ីសលីក បានសម្តែងការអបអរសាទរ ដែលក្រុងបាត់ដំបង នៃខេត្តបាត់ដំបង បានទទួលពានរង្វាន់ទេសចរណ៍ស្អាតអាស៊ានលើកទី៣ (២០២២-២០២៤) ។

ជាការឆ្លើយតបឯកឧត្តម សុខ លូ បានថ្លែងអំណរគុណដល់អង្គការ USAID ដែលកន្លងមក បានខិតខំប្រឹងក្នុងការចូលរួមអភិវឌ្ឍខេត្តបាត់ដំបង លើវិស័យសំខាន់ៗជាច្រើន ជាពិសេសវិស័យសុខាភិបាល។ ឯកឧត្តម បានបន្តទៀតថា បច្ចុប្បន្ននេះ ខេត្តបាត់ដំបង ជួបបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹង បញ្ហាបរិស្ថាន ជាទុក្ខកង្វល់ ដែលរដ្ឋបាលខេត្តត្រូវដោះស្រាយជាបន្ទាន់ ដូច្នេះ ឯកឧត្តម ក៏បានស្នើដល់អង្គ ការUSAID ជួយដល់ខេត្តបាត់ដំបង និងជាពិសេសស្នើជួយឡដុតសំរាម ដើម្បីពន្លឿនដល់ការដុតសំរាមឱ្យកាន់តែឆាប់រហ័ស និងឈានទៅដោះស្រាយបញ្ហាសំរាមឱ្យបានល្អប្រសើរឡើង៕អត្ថបទ៖ នឿត សុភ័ក្រ្ត

# ថ្ងៃទី១០ ខែ កុម្ភៈ ឆ្នាំ២០២២

## ពលករខ្មែរជាង ១ពាន់នាក់
## បានវិលពីថៃ តាមច្រកខេត្តបាត់ដំបង ក្នុងសប្តាហ៍ទី១ខែនេះ ព្រោះកង្វះការងារ

https://news.btv.com.kh/ 02/09/2022 04:02 PM

បាត់ដំបង៖ ក្នុងរយៈពេល១សប្តាហ៍ ដើមខែកុម្ភៈ ឆ្នាំ២០២២នេះ មានពលករខ្មែរប្រមាណ១៤០០នាក់ បានវិលត្រឡប់មកពីប្រទេសថៃ តាមច្រកព្រំដែននានាក្នុងភូមិសាស្ត្រខេត្តបាត់ដំបង ខណៈពលករភាគច្រើនមានកាតចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩។

យោងតាមរបាយការណ៍របស់ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានឱ្យដឹងថា ពលករទាំងអស់ ដែលត្រឡប់មកពីប្រទេសថៃ ត្រូវបានយកសំណាកធ្វើតេស្តរហ័សរកជំងឺកូវីដ-១៩ នៅចំណុចច្រក ព្រំដែន ហើយចំពោះអ្នកវិជ្ជមាន ក្រុមគ្រូពេទ្យនឹងបញ្ជូនទៅព្យាបាល អ្នកអវិជ្ជមានគ្មានកាតចាក់វ៉ាក់សាំង ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័ក ចំណែកអ្នកអវិជ្ជមានមានកាតចាក់វ៉ាក់សាំងគ្រប់២ដូស ត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញរៀងៗខ្លួន។ របាយការណ៍ដដែល បានបញ្ជាក់ថា ក្នុងចំណោមពលករខ្មែរជាង១ពាន់នាក់ ដែលវិលត្រឡប់មក ពីប្រទេសថៃ មានពលករចំនួន២នាក់ ត្រូវបានធ្វើធ្វើតេស្តរកឃើញជំងឺកូវីដ១៩ និងត្រូវបានបញ្ជូនទៅព្យាបាល នៅក្នុងមណ្ឌលព្យាបាលស្រុកសំពៅលូន។

បើតាមក្រុមពលករ បានឱ្យដឹងថា ពួកគេបានវិលត្រឡប់មកស្រុកកំណើតវិញ ដោយសារកង្វះការងារជាពិសេសក្នុងមួយរយៈពេលចុងក្រោយនេះ ភាគីថៃបានចុះរឹតបន្តឹងវិធានការសុខាភិបាល នៅតាមកន្លែងធ្វើការងារ និងតាមទីសាធារណៈ ក្រោមហេតុផលទប់ស្កាត់ការចម្លងជំងឺកូវីដ១៩ ហើយគ្រប់ការធ្វើ សំណាក និងព្យាបាលជំងឺកូវីដ១៩ សុទ្ធតែតម្រូវឱ្យបង់ប្រាក់ ដែលជាហេតុអ្វីឱ្យពលករគ្មានលទ្ធភាពបង់លុយតាមការទាមទាររបស់អាជ្ញាធរថៃ។ វិធានការសុខាភិបាលនៅច្រកព្រំដែនខេត្តបាត់ដំបង ត្រូវបានបន្តរឹតបន្តឹងដើម្បីទប់ស្កាត់ការចម្លង ជំងឺកូវីដ-១៩ បំប្លែងថ្មីប្រភេទអូមីក្រុង ខណៈរំហូរពលករខ្មែរវិលត្រឡប់មកពីប្រទេសថៃ មានការកើនឡើងជាបន្តបន្ទាប់។

ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលឆ្លងជំងឺកូវីដ-១៩ កងកម្លាំងចម្រុះការពារព្រំដែន ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង បានធ្វើការទំនាក់ទំនង និងសហការយ៉ាងជិតស្និទជាមួយភាគីថៃ ដើម្បី ទប់ស្កាត់មិនឲ្យប្រជាពលរដ្ឋខ្មែរលបលួចឆ្លងដែនចូលទៅក្នុងទឹកដីថៃ ដោយមិនស្របច្បាប់។អត្ថបទ៖ នឿត សុកគ្រ្គ

## ធុរកិច្ចថៃនិយាយថា ពលករចំណាកស្រុកខ្មែរ
## មានចំនួន ២១ ភាគរយ នៃពលករចំណាកស្រុក ដែលត្រូវការចំនួន ៩០.០០០ នាក់

https://www.khmertimeskh.com/ Khmer Times February 9, 2022

ប្រតិបត្តិករអាជីវកម្ម បានដាក់សំណើទៅក្រសួងការងារស្នើសុំពលករចំណាកស្រុកប្រហែល ៩០,០០០ នាក់ ក្រោមអនុស្សរណៈយោគយល់គ្នា (MoU) ដែលបានចុះហត្ថលេខាជាមួយប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ាកាលពីខែធ្នូ ឆ្នាំមុន។

រដ្ឋមន្ត្រីក្រសួងការងារ លោក Suchart Chomklin បាននិយាយថា ក្រសួងបានទទួលពាក្យស្នើសុំចំនួន ១.៣៤៩ ពីនិយោជក ដែលស្វែងរកកម្លាំងពលកម្មចំណាកស្រុកសរុបចំនួន ៩០.០៧១ នាក់។ សំណើភាគច្រើនមាន ៧២.២% គឺតម្រូវការសម្រាប់ពលករមកពីប្រទេសមីយ៉ាន់ម៉ា ខណៈដែលមាន ២០.៩% សម្រាប់តម្រូវការពលករមកពីប្រទេសកម្ពុជា និង ៦.៨% មកពីប្រទេសឡាវ។ លោក Suchart បាននិយាយថា ក្រុមទី១ នៃពលករ

កម្ពុជាចំនួន ១៥៨នាក់ ក្រោម MoU បានមកដល់ និងកំពុងធ្វើចត្តាឡីស័ករយៈពេល ៧ថ្ងៃ នៅក្នុងស្រុកអារញ្ញ ខេត្តស្រះកែវ។ ពលករចំណាកស្រុកបានចាក់វ៉ាក់សាំងយ៉ាងពេញលេញ និងមានការធានារ៉ាប់រងសុខភាពដែលគ្រប ដណ្តប់លើការព្យាបាលកូវីដ-១៩ ។ លោកបានបន្តថា បន្ទាប់ពីធ្វើចត្តាឡីស័ក កម្មករនឹងត្រូវនាំទៅកន្លែងធ្វើដោយ ធ្វើដំណើតាមផ្លូវបិទជិត។ នាយកដ្ឋានការងារនឹងធ្វើការជាមួយខេត្ត និងប៉ុស្តិ៍ត្រួតពិនិត្យអន្តោប្រវេសន៍ ដើម្បីរៀបចំ កន្លែងធ្វើចត្តាឡីស័ក។

អគ្គនាយកនៃអគ្គនាយកដ្ឋានការងារលោក Pairoj Chotikasathien បាននិយាយថា ដំបូងឡើយនាយក ដ្ឋានបានអនុញ្ញាតឲ្យពលករខ្មែរចំនួន ២២០ នាក់ ចូលប្រទេស ប៉ុន្តែមាន ៣៥ នាក់ក្នុងចំណោមពួកគេ មិនទាន់ ត្រៀមខ្លួនរួចរាល់ក្នុងការធ្វើដំណើរទៅប្រទេសថៃនៅឡើយទេ៕ ប្រភព: Bangkokpost

## ថ្ងៃទី១១ ខែ កុម្ភៈ ឆ្នាំ២០២២

### ពលរដ្ឋ២៨៣នាក់ ត្រឡប់ពីថៃចូលកម្ពុជាដោយអ្នកខ្លះធ្វើចត្តាឡីស័ក និងខ្លះទៀតត្រូវទៅស្រុកកំណើតរៀងៗខ្លួន

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ១០ ខែ កុម្ភៈ ឆ្នាំ ២០២២ ម៉ោង ១០:០០

ខេត្តបាត់ដំបង ៖ កម្លាំងនគរបាលសហការជាមួយកម្លាំងយោធាទទួលប្រជាពលរដ្ឋ២៨៣នាក់ ត្រឡប់ពី ប្រទេសថៃចូលកម្ពុជាវិញ នៅស្រុកកំរៀង នាថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ ។នេះបើយោងតាមផេក អគ្គស្នង ការដ្ឋាននគរបាលជាតិបានផ្សាយនាថ្ងៃទី១០ ខែកុម្ភៈនេះ ។ ដោយអនុវត្តន៍តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារ វរសេនាតូចនគរបាលការពារព្រំដែនគោក ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកង យោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យ បានទទួលពលករវិលត្រឡប់មកស្រុកវិញតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិ អូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ។

ប្រជាពលរដ្ឋចំនួន ២៨៣នាក់ (ស្រី១១០នាក់) ក្មេង៦១នាក់ (ក្មេងស្រី២៣នាក់) កម្លាំងសមត្ថកិច្ចបាន សាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩ រួច ក្រុមគ្រូពេទ្យបាន ធ្វើតេស្តរហ័ស ជាលទ្ធផល ៖

-វិជ្ជមានកូវីដ១៩ ចំនួន ១នាក់ (ស្រី ១នាក់) ក្មេងស្រីទៅតាមម្តាយ ១នាក់ បញ្ជូនទៅព្យាបាលនៅមណ្ឌល គ្រារជួ ស្រុកសំពៅលូន។

-ពលករចំនួន ៤៥នាក់ (ស្រី ១៥នាក់) ក្មេង ៨នាក់ (ស្រី១នាក់) បញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌល គីឡូ៩ ស្រុកសំពៅលូន។

-ពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន២៣៧នាក់ (ស្រី ៩៣នាក់) ក្មេង ៥២នាក់ (ស្រី ២១នាក់) ក្នុងនោះបានចាក់វ៉ាក់សាំងអោយក្មេងចាប់ពីអាយុ ៥ឆ្នាំដល់ ១៨ឆ្នាំ ចំនួន២៥នាក់ (ស្រី ១៥នាក់) ក្រុមគ្រូពេទ្យ អនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ៕

# កុមារប្រើពេលច្រើនលើអ៊ីនធឺណិត
# អាចប្រឈមការគំរាមកំហែង បោកប្រាស់ ការបៀតបៀនផ្លូវភេទ

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 10 February 2022 | 10:59 ICT

**ភ្នំពេញៈ** មន្ត្រីរាជរដ្ឋាភិបាល និងសង្គមស៊ីវិលអះអាងថា ការប្រើប្រាស់ពេលវេលាច្រើនរបស់កុមារលើប្រព័ន្ធអ៊ីនធឺណិតអាចប្រឈមនឹងបញ្ហាផ្សេងៗដូចជាការគំរាមកំហែង ការបោកប្រាស់ ការបៀតបៀនផ្លូវភេទជាដើម ខណៈការរីករាលដាលនូវជំងឺកូវីដ ១៩ បាននាំមកនូវការផ្លាស់ប្ដូរជាច្រើនដល់របៀបរបបរស់នៅ និងការរៀនសូត្ររបស់កុមារ។

លោកស្រី ទេព រ៉ូដា អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ថ្លែងក្នុងយុទ្ធនាការគាំទ្រទិវាអន្តរជាតិ ដើម្បីសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ ២០២២ កាលពីថ្ងៃទី ៨ ខែកុម្ភៈនេះថា ក្នុងពិភពលោកបច្ចុប្បន្នប្រព័ន្ធអ៊ីនធឺណិតមានស្ទើរគ្រប់ទីកន្លែង និងបានក្លាយជាវេទិកាកំពុងពេញនិយមបំផុតក្នុងការប្រាស្រ័យទាក់ទងគ្នា។ ជាមួយគ្នានេះប្រទេសកម្ពុជាសេវាអ៊ីនធឺណិតក៏មានស្ទើរគ្រប់ទីកន្លែងដែរ ប្រជាពលរដ្ឋអាចប្រើប្រាស់វានៅទីកន្លែងណាពេលណាក៏បានឱ្យតែមានទូរស័ព្ទស្មាតហ្វូន ឬឧបករណ៍អេឡិចត្រូនិកដែលអាចភ្ជាប់ប្រព័ន្ធអ៊ីនធឺណិតបាន។ លោកស្រីថ្លែងថា៖ «ការអភិវឌ្ឍនូវបច្ចេកវិទ្យាបានផ្ដល់ផលជាវិជ្ជមាន និងអវិជ្ជមាន ហើយចំពោះអ្នកប្រើប្រាស់ជាកុមារក៏មានការកើនឡើងច្រើនគួរឱ្យកត់សម្គាល់ដែរ ដែលក្នុងនោះក្នុងចំណោមអ្នកប្រើប្រាស់ ៣ នាក់ គឺមាន ១ នាក់ជាកុមារ»។ លោកស្រីបន្តថា ប្រព័ន្ធអ៊ីនធឺណិតមិនត្រឹមតែជាទីកន្លែងដែលកុមារអាចស្វែងរកព័ត៌មាន រឿងរ៉ាវ ការរៀនសូត្រ ការស្រាវជ្រាវ ចំណេះដឹង និងលេងកម្សាន្ត ឬភ្ជាប់ទំនាក់ទំនងប៉ុណ្ណោះទេ ប៉ុន្តែក៏ជាទីកន្លែងផ្ដល់នូវហានិភ័យ និងគ្រោះថ្នាក់យ៉ាងខ្លាំងដល់កុមារ និងអ្នកប្រើប្រាស់ជាច្រើនដែរ ដោយសារតែពួកគេមិនបានយល់ពីគុណសម្បត្តិ និងគុណវិបត្តិ ឬមិនទាន់ចេះប្រើប្រាស់វាឱ្យបានត្រឹមត្រូវ។

លោកស្រីបានឱ្យដឹងថា ប្រព័ន្ធអ៊ីនធឺណិតបានផ្ដល់ហានិភ័យដល់កុមារដូចជា ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ការលួងលោម ការរុកកួនឆាឆៅ និងបញ្ហាជាច្រើនទៀត។ កុមារ និងយុវជនអាចមានកង្វល់ ពាក់ព័ន្ធនឹងឯកជនភាព ដោយសារតែពួកគេបានទទួលសារជាតំណភ្ជាប់ជាអត្ថបទ រូបភាព វីដេអូ ដែលពួកគេមិនចង់បាន រួមនឹងខ្លឹមសារមួយចំនួនពាក់ព័ន្ធនឹងផ្លូវភេទ និងមាតិកាញុះញង់ អុចអាលបំភិតបំភ័យជាដើម។ លោកស្រីអះអាងថា៖ «ក្នុងពេលថ្មីៗចុងក្រោយនេះការរីករាលដាលនូវជំងឺកូវីដ ១៩ បាននាំមកនូវការផ្លាស់ប្ដូរជាច្រើនដល់របៀបរបបរស់នៅ និងការរៀនសូត្ររបស់កុមារ ជាក់ស្ដែងការសិក្សានៅសាលាត្រូវបានជំនួសដោយការប្រើប្រាស់ប្រព័ន្ធអនឡាញ មានន័យថាកុមារត្រូវការប្រើប្រាស់ពេលវេលាច្រើនលើប្រព័ន្ធអ៊ីនធឺណិតដែលគេអាចប្រឈមនឹងបញ្ហាផ្សេងៗ ដូចជាការគំរាមកំហែង ការបោកប្រាស់ ការបៀតបៀនផ្លូវភេទ ការធ្វើបាបពីជនមិនស្គាល់មុខមកលើអារម្មណ៍ និងស្មារតីរបស់ពួកគេ»។

តាមស្ថិតិ National Center for Missing and exploited Children របស់សហរដ្ឋអាមេរិកបានបង្ហាញករណីនៃរបាយការណ៍ ស្ដីពីសម្ភារកេងប្រវ័ញ្ចផ្លូវភេទចំពោះកុមារលើបណ្ដាញអ៊ីនធឺណិតនៅក្នុងប្រទេសកម្ពុជាបានកើនឡើងទ្វេដងក្នុងអំឡុងពេលកូវីដ ១៩ នេះ គឺពីប្រមាណ ៩ ម៉ឺនករណីក្នុងឆ្នាំ ២០១៩ កើនដល់ ១៨ ម៉ឺនករណីក្នុងឆ្នាំ ២០២០។

លោកស្រី ទេព រ៉ូដា បញ្ជាក់ថា តួលេខទាំងនេះ គឺជាតួលេខសរុបនៃការរាយការណ៍ដែលបានមកពីបណ្ដាក្រុមហ៊ុនបច្ចេកវិទ្យាធំៗរបស់សហរដ្ឋអាមេរិកដែលពួកគេអាចស្វែងរកដឹងពីទីតាំងនៃការបង្ហោះ (Upload) ឬចែករំលែករូបភាព ឯកសារទាំងនោះលើប្រព័ន្ធរបស់ខ្លួន។ លោកស្រី រ៉ូដា ថ្លែងថា ចំពោះករណីក្នុងប្រទេសកម្ពុជា កិច្ចពិគ្រោះយោបល់ជាមួយយុវជន និងកុមារ ដែលត្រូវបានធ្វើឡើងក្នុងឆ្នាំ ២០២០ បានរកឃើញថា ១៥ ភាគរយនៃ

កុមារដែលចូលរួមកិច្ចពិគ្រោះយោបល់បានរាយការណ៍ថា ពួកគេធ្លាប់មានមនុស្សមិនស្គាល់មុខទាក់ទងមកលើបណ្ដាញសង្គម។ កុមារ ២ ភាគរយទៀតបានរៀបរាប់ថា ពួកគេធ្លាប់ត្រូវបានជនមិនស្គាល់មុខស្នើឱ្យចែករំលែករូបភាព សកម្មភាពបែបមិនសមរម្យ និងសកម្មភាពបែបស្និទ្ធស្នាលនៅចំពោះមុខកាមេរ៉ាដែលភ្ជាប់ទៅនឹងអ៊ីនធឺណិត។ ដោយមានកំណើនចរាចរណ៍លើការរំលោភបំពាន និងការចែកចាយបន្តនូវរូបភាព អាសអាភាស របស់កុមារលើបណ្ដាញអ៊ីនធឺណិត ក្រុមហ៊ុនបច្ចេកវិទ្យាធំៗជាច្រើននៅលើសកលលោក បាននិងកំពុងចាត់វិធានការទប់ស្កាត់ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យារបស់ពួកគេ។

អង្គការសកម្មភាពដើម្បីកុមារ (APLE) គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NCCT) ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MPTC) និងសាខាកាកបាទក្រហមកម្ពុជារាជធានី ដោយមានការឧបត្ថម្ភ គាំទ្រពីអង្គការដៃគូ ក្រុមហ៊ុនឯកជន និងគណៈកម្មាធិការសុវត្ថិភាពអ៊ីនធឺណិតនៅថ្ងៃទី ៨ ខែកុម្ភៈ បានសហការគ្នាប្រារព្ធយុទ្ធនាការគាំទ្រទិវាអន្តរជាតិ ដើម្បីសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ ២០២២ នៅវិទ្យាស្ថានជាតិអប់រំ។ ការប្រារព្ធយុទ្ធនាការនេះ គឺដើម្បីលើកកម្ពស់ការយល់ដឹងយ៉ាងទូលំទូលាយអំពីសុវត្ថិភាពអ៊ីនធឺណិតនៅកម្ពុជា។ យុទ្ធនាការនេះក៏ជាការលើកកម្ពស់ការចូលរួមធ្វើឱ្យបច្ចេកវិទ្យាអ៊ីនធឺណិតកាន់តែមានសុវត្ថិភាពសម្រាប់កុមារ និងការប្រើប្រាស់ប្រកបដោយការទទួលខុសត្រូវ សេចក្ដីគោរព ការគិតពិចារណា និងភាពច្នៃប្រឌិត។ តាមរយៈយុទ្ធនាការនេះធ្វើឡើងដើម្បីផ្សព្វផ្សាយទៅដល់កុមារ និងយុវជនវ័យក្មេង ឪពុកម្ដាយ និងអ្នកថែទាំកុមារ គ្រូបង្រៀន អ្នកអប់រំ បុគ្គលិកសង្គម ក្រុមហ៊ុនអ៊ីនធឺណិត អ្នកធ្វើការសម្រេចចិត្ត និងអ្នកនយោបាយដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមចំណែកក្នុងការធ្វើឱ្យប្រព័ន្ធអ៊ីនធឺណិតកាន់តែល្អប្រសើរ និងមានសុវត្ថិភាព។

តាមសេចក្ដីប្រកាសព័ត៌មាន យុទ្ធនាការនេះប្រារព្ធឡើង ក្រោមប្រធានបទរួមមួយគឺ «រួមគ្នាលើកកម្ពស់ការពារ និងគោរពសិទ្ធិកុមារតាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយការទទួលខុសត្រូវ» ដោយមានអ្នកចូលរួមជាង ៣០០ នាក់ រួមមាន កុមារ យុវជន មន្ត្រីរាជរដ្ឋាភិបាល គ្រូបង្រៀន បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងប្រតិបត្តិករអ៊ីនធឺណិត។ ដោយឡែក តាមរយៈយុទ្ធនាការនេះនឹងរៀបចំកម្មវិធីបែបនេះជាមួយកុមារ និងយុវជននៅតាមសាលារៀនចំនួន ២ ទៀតក្នុងរាជធានីភ្នំពេញនាពេលខាងមុខ ដោយមានអ្នកចូលរួមជាង ៣០០ នាក់បន្ថែមទៀត។

លោកស្រី សឿ សុជាតា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡាថ្លែងក្នុងពិធីប្រកាសយុទ្ធនាការនេះថា ក្នុងនាមក្រសួងអប់រំ ក្នុងនាមប្រជាជន តាមរយៈសកម្មភាពយុទ្ធនាការនៅក្នុងពេលនេះ និងបង្ហាញទៅកាន់សកលលោកថា កម្ពុជាកំពុងតែធ្វើដំណើរឆ្ពោះទៅកាន់ទិសដៅអភិវឌ្ឍន៍តាមគន្លងមួយយ៉ាងត្រឹមត្រូវ។ លោកស្រីថ្លែងថា៖ «អ្វីដែលយើងធ្វើនៅថ្ងៃនេះ បានបញ្ជាក់នូវសុឆន្ទៈរបស់យើងទាំងអស់គ្នាក្នុងការប្ដេជ្ញាចិត្ត ធ្វើដំណើរប្រកបដោយសុឆន្ទៈលើការអភិវឌ្ឍធនធានមនុស្សរបស់កម្ពុជាឆ្លើយតបទៅនឹងទំនើបកម្មនៃបច្ចេកវិទ្យា និងបដិវត្តន៍ឧស្សាហកម្ម ៤.០»។

លោក សំលៀង សីលា នាយកប្រតិបត្តិ នៃអង្គការសកម្មភាពដើម្បីកុមារថ្លែងថា ការចូលរួមប្រារព្ធទិវាសុវត្ថិភាពអ៊ីនធឺណិតនេះ បានសម្ដែងនូវការប្ដេជ្ញាចិត្តដ៏មោះមុតរបស់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងការការពារកុមារពីគ្រប់ទម្រង់ទាំងអស់នៃការរំលោភបំពាន រួមទាំងការរំលោភបំពានតាមប្រព័ន្ធអនឡាញ និងបានក្លាយជាចំណែកដ៏ធំមួយនៃការផ្លាស់ប្ដូរឥរិយាបថ និងការជំរុញលើកទឹកចិត្តឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាអ៊ីនធឺណិត ប្រកបដោយការទទួលខុសត្រូវ ការគោរព ការចេះគិតពិចារណា និងភាពច្នៃប្រឌិត។ លោក សំលៀង សីលា បានថ្លែងថា៖ «យើងសង្ឃឹមថា ទិវានេះនឹងក្លាយទៅជាទិវាជាតិមួយដែលត្រូវប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ»៕

## អាជ្ញាធរស្រុកសំពៅលូន ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ និងប្រគល់ទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣

https://gdlf-kh.com/ 2022/02/10/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៧និង០០នាទី នាថ្ងៃព្រហស្បតិ៍ ៩កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី កៅ-ប៊ុណ្ណា (មេបញ្ជាការរងកងអនុសេនាធំ), កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ផុក-លឹមឃី (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញត្រង់ចំណុចភូមិសាស្ត្រ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០៤នាក់,(ស្រី០២នាក់, ក្មេងប្រុស០១នាក់)។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើការកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣។

# ថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ២០២២

## សម្តេចតេជោ ហ៊ុន សែន ស្នើឱ្យកូរ៉េខាងត្បូង បង្កើនកូតាសម្រាប់ពលករកម្ពុជា និងអរគុណចំពោះការផ្តល់វ៉ាក់សាំងដល់ពួកគេ

http://freshnewsasia.com/ 2022-02-11 07:03pm

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានស្នើដល់ លោក មូន ជេអ៊ីន ប្រធានាធិបតីសាធារណរដ្ឋកូរ៉េ (កូរ៉េខាងត្បូង) បង្កើនកូតា ក្នុងការទទួលយកពលករខ្មែរទៅធ្វើការនៅក្នុងប្រទេសនេះ ឱ្យបានច្រើនឡើងថែមទៀត។

លោកបណ្ឌិត កៅ គឹមហួន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បានបញ្ជាក់ឱ្យដឹងថា សំណើរបស់ សម្តេចតេជោបានធ្វើឡើងក្នុងឱកាសដែលសម្តេចបានជួបពិភាក្សាការងារជាមួយ លោក មូន ជេអ៊ីន អំឡុងបំពេញទស្សនកិច្ច នៅសាធារណរដ្ឋកូរ៉េ និងធ្វើជាសហប្រធានកិច្ចប្រជុំកំពូលសន្តិភាពពិភពលោកឆ្នាំ២០២២ ក្រោមមូលបទ « **ឆ្ពោះទៅកាន់សន្តិភាពនៅឧបទ្វីបកូរ៉េ**»។ លោកបណ្ឌិត បានអះអាងថា បន្ថែមលើការស្នើឱ្យកូរ៉េខាងត្បូង បង្កើនកូតាសម្រាប់ការទទួលយកពលករខ្មែរនេះ សម្តេចក៏បានថ្លែងអំណរគុណ ដល់រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ដែលបានផ្តល់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ដល់ពលករខ្មែរនៅក្នុងប្រទេសនេះផងដែរ។ កូរ៉េជាប្រទេសដែលមានពលករខ្មែរធ្វើការច្រើនជាងគេលំដាប់ទី២ បន្ទាប់ពីប្រទេសថៃ។ របាយការណ៍ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឱ្យដឹងថា បច្ចុប្បន្ននេះ ពលករកម្ពុជាដែលកំពុងបម្រើការងារនៅសាធារណរដ្ឋកូរ៉េ មានប្រមាណ ៤៥,០០០នាក់ ខណៈដែលឆ្នាំ២០២១ កន្លងទៅនេះ គ្រាដែលពិភពលោករងការរាតត្បាតជំងឺកូវីដ១៩ ប្រទេសកូរ៉េខាងត្បូង បានទទួលពលករកម្ពុជាចំនួន ២៥០០នាក់។

គិតត្រឹមឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ឱកាសការងារនៅក្រៅប្រទេសជូនប្រជាពលរដ្ឋ បានចំនួនជាង ១៣០១៦០៩នាក់ (ស្រី ៥២៨៧៩៩នាក់) ក្នុងនោះប្រទេសថៃមានចំនួន ១២២០១៩៧នាក់ ប្រទេសកូរ៉េមានចំនួន ៤៥៨៦០នាក់ ប្រទេសម៉ាឡេស៊ីមានចំនួន ២៣០២៧នាក់ ប្រទេសជប៉ុនមានចំនួន ១១៤៥៣ នាក់ ប្រទេសសិង្ហបុរីមានចំនួន ៨២១ នាក់ ហុងកុងមានចំនួន ២០២ នាក់ និងអារ៉ាប់ប៊ីសាអូឌីតចំនួន ៤៣ នាក់៕

## អង្គការសហប្រជាជាតិ ផ្ញើលិខិតអញ្ជើញកម្ពុជា ចូលរួម កិច្ចសន្ទនាអន្តរជាតិ ពាក់ព័ន្ធនឹងការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍

http://freshnewsasia.com/ 2022-02-11 01:15pm

**(ភ្នំពេញ)៖** លោក António Guterres អគ្គលេខាធិការអង្គការសហប្រជាជាតិ បានផ្ញើលិខិតអញ្ជើញរាជរដ្ឋាភិបាលកម្ពុជា ឲ្យចាត់តំណាងទៅចូលរួមក្នុងកិច្ចសន្ទនាអន្តរជាតិ ពាក់ព័ន្ធនឹងការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM)។ នេះបើតាមការឲ្យដឹងពីលោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅព្រឹកថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២ ក្នុងសិក្ខាសាលាថ្នាក់ជាតិ ស្តីពី ការរៀបចំផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅសណ្ឋាគារកាំបូឌីយ៉ាណា។

បើតាមលោកស្រី ជូ ប៊ុនអេង អង្គការសហប្រជាជាតិ បានអញ្ជើញតំណាងកម្ពុជា ឲ្យចូលរួមការជជែកលើបញ្ហាដូចជា អ្វីទៅជាភាពជោគជ័យ អ្វីទៅជាបញ្ហាប្រឈម ហើយតើប្រទេសនីមួយៗ មានគំនិតផ្តួចផ្តើមអ្វីខ្លះ ជាយុទ្ធសាស្រ្តនៅក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។ លោកស្រី ជូ ប៊ុនអេង បានបញ្ជាក់យ៉ាងដូច្នេះថា៖ «**ថ្មីៗនេះ យើងបានទទួលការអញ្ជើញពីលោក António Guterres បានផ្ញើលិខិតតាមរយៈតំណាងបេសកកម្មអចិន្ត្រៃយ៍របស់កម្ពុជា ប្រចាំអង្គការសហប្រជាជាតិ នៅក្រុងហ្សឺណែវ ដើម្បីអញ្ជើញកម្ពុជាចូលរួមនៅក្នុងកិច្ចសន្ទនាអន្តរជាតិ នៅថ្ងៃទី២៨ ខែកុម្ភៈ ដល់ថ្ងៃទី២ ខែមីនា ឆ្នាំ២០២២ ដើម្បីជជែកគ្នា**»។ លោកស្រីបន្តថា កម្ពុជានឹងមានតំណាងនៅក្នុងការចូលរួមកិច្ចពិភាក្សានេះ ហើយកិច្ចពិភាក្សានេះ នឹងត្រៀមដល់កិច្ចប្រជុំលើកទី១ នៅក្នុងចំណោមប្រទេសលើពិភពលោក ដែលជាសមាជិករបស់កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលប្រារព្ធធ្វើនៅខែឧសភា ឆ្នាំ២០២២។ ក្នុងកិច្ចប្រជុំលើកទី១ នៅក្នុងចំណោមប្រទេសលើពិភពលោក ដែលជាសមាជិករបស់កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ គេនឹងរង់ចាំប្រទេសជ័យលាភី មានទាំងកម្ពុជាផងនោះ ធ្វើសេចក្តីថ្លែងការណ៍ សម្រាប់ការចែករំលែកនូវបទពិសោធន៍ លើការអនុវត្តកតិកាសញ្ញានេះ។

កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ គឺជាប្រេកខណ្ឌទូលំទូលាយទីមួយរបស់អង្គការសហប្រជាជាតិ ដែលត្រូវបានអនុម័ត តាមរយៈកិច្ចការពិភាក្សា អន្តររដ្ឋាភិបាល ដើម្បីធ្វើឱ្យកិច្ចសហការអន្តរជាតិមានភាពល្អប្រសើរ ក្នុងអភិបាលកិច្ចទេសន្តរប្រវេសន៍ជាសកល និងត្រូវបានឯកភាពគាំទ្រដោយមហាសន្និបាត អង្គការសហប្រជាជាតិ ដែលបានប្រារព្ធឡើងកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ នៅទីក្រុងញូយ៉ក ដែលមានសមាជិកចូលរួមចំនួន ១៥២ប្រទេស។ អង្គការសហប្រជាជាតិ បានផ្តល់ជ័យលាភីដល់កម្ពុជា (Champion Country) ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅឆ្នាំ២០២០ ដែលមានន័យថា កម្ពុជាទទួលបានជំនួយពីការអង្គការសហប្រជាជាតិ ក្នុងការគ្រប់គ្រងការងារទេសន្តរប្រវេសន៍។ ឥឡូវនេះ មានប្រទេសជាច្រើន កំពុងធ្វើសេចក្តីព្រាងសុំចូលជាសមាជិកប្រទេសជ័យលាភី ឬ Champion Country ក្នុងការអនុវត្តកតិកាសញ្ញានេះផងដែរ។ លោកស្រី ជូ ប៊ុនអេង បានបន្ត

ថា «ឥឡូវនេះ យើងក៏បានឃើញ ក្រុមនៃប្រទេសមួយជាច្រើន ដែលបានជដែកគ្នាធ្វើសេចក្តីព្រាង សុំចូលជាសមាជិកនៃក្រុមប្រទេសជ័យលាភី។ កម្ពុជា យើងបានចូលក្នុងចំណោមប្រទេសជ័យលាភី ទាំង ១៨ ឥឡូវនេះ ប្រទេសជ័យលាភី មានដល់ ៣០ហើយ»៕

## ក្រសួងមហាផ្ទៃចុះអនុស្សរណៈជាមួយអង្គការ ERiKSHJALPENដើម្បីបង្ការទប់ស្កាត់ការកេងប្រវ័ញ្ចលើកុមារ

https://news.btv.com.kh/ 02/11/2022 04:02 PM

ភ្នំពេញ ៖ ក្រសួងមហាផ្ទៃតាមរយៈគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស នៅរសៀលថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០២២នេះ បានចុះអនុស្សរណ នៃការយោគយល់គ្នាជាមួយ អង្គការ ERiKSHJALPEN ស្តីពីសកម្មភាពបង្ការទប់ស្កាត់ ប្រយុទ្ធប្រឆាំងរាល់ទម្រង់ នៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារ ខណៈអង្គការនេះបានជួយសង្គ្រោះកុមារកម្ពុជាពីការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទរាប់រយនាក់ក្នុងមួយឆ្នាំៗនោះ។

ថ្លែងប្រាប់ទូរទស្សន៍ BTV បន្ទាប់ពីចុះអនុស្សរណៈនោះ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានលើក ឡើងថា ការចុះអនុស្សរណៈជាមួយអង្គការជាដៃគូនេះ គឺដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ នៃការបង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារ ខណៈបញ្ហាទាំងនេះ នៅតែមានក្តីបារម្ភនៅឡើយចំពោះប្រទេសកម្ពុជានោះ។ ជាមួយគ្នានោះដែរ លោកជំទាវ ជូ ប៊ុនអេង បានឲ្យដឹងផងដែរថា រហូតមកដល់ពេលនេះក្រសួងមហាផ្ទៃ បានចុះអនុស្សរណៈជាមួយអង្គការជាដៃគូជាង១០មកហើយ ដោយអង្គការនីមួយៗមានសម្ព័ន្ធមិត្តរាប់សិបផ្សេងទៀត ដែលធ្វើកិច្ចការងារទាក់ទងនឹងបញ្ហា នៃការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅកម្ពុជានោះ។

ថ្លែងប្រាប់ទូរទស្សន៍ BTV បន្ទាប់ពីចុះអនុស្សរណៈនោះដែរ លោក កេង ប៊ុនឈឿត នាយកគ្រប់គ្រងប្រចាំអាស៊ី ERiKSHJALPEN បានឲ្យដឹងថា អង្គការរបស់លោកបានធ្វើប្រចាំនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩០មកម្លេះ ដោយបានជួយកុមារកម្ពុជារួចផុតពីការជួញដូរ កេងប្រវ័ញ្ចផ្លូវភេទ និងពីការគាប់សង្កត់ផ្សេងក្នុងមួយឆ្នាំៗរាប់រយនាក់។ លោក កេង ប៊ុនឈឿត លើកឡើងផងដែរថា ការចុះអនុស្សរណៈជាមួយគណៈកម្មាធិការជាតិប្រ យុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ គឺមានរយៈពេលប្រាំឆ្នាំ គឺចាប់ពីឆ្នាំ២០២២ដល់ឆ្នាំ២០២៦ ដើម្បីសហការជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការគាប់សង្កត់កុមារលើទម្រង់ផ្សេងនៅកម្ពុជាឲ្យមានប្រសិទ្ធភាពបន្ថែមទៀត ខណៈអង្គការនេះបានចំណាយថវិកាជាងមួយលានដុល្លារអាមេរិកជារៀងរាល់ឆ្នាំលើវិស័យនេះ៕ ចក់

## អាជ្ញាធរខេត្តឧត្តរមានជ័យ ណែនាំពលរដ្ឋឱ្យផ្អាកធ្វើដំណើរឆ្លងដែនខុសច្បាប់ទៅថៃ

https://www.postkhmer.com/ ឡាយ សាមាន | Publication date 11 February 2022 | 09:52 ICT

**ឧត្តរមានជ័យ:** ស្ថិតក្នុងស្ថានភាពកូវីដ ១៩ អស់រយៈពេល ២ ឆ្នាំមកនេះ សមត្ថកិច្ចខេត្តឧត្តរមានជ័យបានបង្កើនការរឹតបន្តឹង ក្នុងការបង្ក្រាបបទល្មើសនៅតាមព្រំដែន ជាពិសេសនៅតាមច្រករបៀង ដោយអាជ្ញាធរខេត្តនេះបានណែនាំឱ្យពលរដ្ឋផ្អាកការធ្វើដំណើរឆ្លងដែនខុសច្បាប់ ដែលមានហានិភ័យ និងងាកមកធ្វើការបង្កបង្កើនផលដាំដុះក្នុងស្រុកជំនួសវិញ។

នេះជាការលើកឡើងរបស់អភិបាលរងខេត្តឧត្តរមានជ័យ លោកស្រី មិន ជារី ថ្លែងនៅក្នុងសន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្តរបស់ក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ" នៅថ្ងៃទី ១០ កុម្ភៈ ឆ្នាំ ២០២២។ លោកស្រី មិន ជារី បានលើកឡើងថា សម្រាប់យុទ្ធសាស្រ្តរបស់ខេត្តពិតមែនតែបច្ចុប្បន្នពលរដ្ឋមិនអាចចំណាកស្រុកស្របច្បាប់ទៅប្រទេសថៃ ប៉ុន្តែគឺជាឱកាសមួយ សម្រាប់អាជ្ញាធរមូលដ្ឋាន បង្កើនការ

ផ្សព្វផ្សាយពីសក្តានុពលក្នុងស្រុកឱ្យគាត់ផ្លាស់ប្តូរផ្នត់គំនិតទៅក្រៅប្រទេស។ លោកស្រីថា៖ «គឺជារឿងល្អ មានន័យថា យើងមានឱកាសផ្សព្វផ្សាយដល់ពលរដ្ឋ តាមរយៈវិស័យផ្សេងៗឱ្យគាត់បង្កើនចំណូលជីវភាពឱ្យគាត់គិតផ្លាស់ប្តូរផ្នត់គំនិត។ ខ្ញុំទទួលស្គាល់ថា អ្នកឧត្តរមានជ័យកន្លងមក ពលរដ្ឋមួយចំនួនតូច គាត់តែងតែគិតថា ទៅធ្វើការនៅប្រទេសថៃមានចំណូលច្រើន ច្បាស់លាស់អាចផ្ញើលុយត្រឡប់មកបងប្អូនធ្វើផ្ទះសំបែងបាន ជាក់ស្តែងគាត់ទទួលបានប្រាក់កម្រៃមែន ប៉ុន្តែក្នុងកាលៈទេសៈស្ថានភាពកូវីដនេះ មិនមែនជាស្ថានភាពល្អទេ»។ ទន្ទឹមនឹងនេះដែរ លោកស្រីបានថ្លែងកោតសរសើរចំពោះមន្ទីរកសិកម្មខេត្ត ដែលបានខិតខំបង្កើតមុខរបរ និងបណ្តុះបណ្តាលបច្ចេកទេស ផ្នែកកសិកម្ម និងការចិញ្ចឹមសត្វដល់ប្រជាកសិករក្នុងខេត្ត។

លោកស្រីបញ្ជាក់ថា៖ «ក្រសួងកសិកម្មបានបង្កើនជីវភាពពលរដ្ឋនៅតាមមូលដ្ឋានដូចជាការចិញ្ចឹម ត្រី មាន់ ទា និងលើកទឹកចិត្តឱ្យដាំដុះ បង្កើនចំណូលប្រចាំថ្ងៃ ហើយក្រុមការងារបង្កើតជាបណ្តុំតាមដាន រកទីផ្សារ។ ពិតថាទីផ្សារបច្ចុប្បន្នមានការលំបាក ប៉ុន្តែក្នុងនាមជាមន្ត្រី ដែលបម្រើប្រជាពលរដ្ឋត្រូវរកទីផ្សារ ដើម្បីបង្កើនចំណូល»។ លោកស្រីបានគូសបញ្ជាក់ថា ពលរដ្ឋដែលប្រថុយប្រថានធ្វើចំណាកស្រុកដោយខុសច្បាប់ ដើម្បីប្រាក់ចំណូលប្រចាំគ្រួសារ ប៉ុន្តែបើសិនជាគាត់មានចំណូលជាក់លាក់ក្នុងមូលដ្ឋាន គាត់មិនទៅចំណាកស្រុកទេ គឺនឹងនៅជិតគ្រួសារ ហើយមិនបែកបាក់គ្រួសារ ។ បើតាមលោកស្រី មិន ធារី ខេត្តឧត្តរមានជ័យមានប្រជាពលរដ្ឋប្រមាណ ៧៥ ភាគរយជាកសិករដែលផ្ទៃដីនៅខេត្តនេះ គឺភាគច្រើនពលរដ្ឋមានដីបង្កបង្កើនផល។ លោកស្រីបន្តថា៖ «អ៊ីចឹងក្រៅពីធ្វើស្រែចម្ការ គាត់អាចដាំដំណាំ កសិផល បន្លែ រួមផ្សំ បង្កើនចំណូលគ្រួសារប្រចាំថ្ងៃបាន»។ ទាក់ទងនឹងយន្តការខេត្តក្នុងការទប់ស្កាត់ជំងឺកូវីដ ១៩ វិញលោកស្រីបញ្ជាក់ថា ៖ « យើងមានគណៈបញ្ជាការឯកភាពខេត្ត យើងមានកម្លាំងសហប្រតិបត្តិការខេត្ត កម្លាំងគយ កម្លាំងអន្តោប្រវេសន៍ មានទាំងខាងកម្លាំងការពារព្រំដែនរឹតបន្តឹងទៅលើបទល្មើសឆ្លងដែន ការពារតាមបន្ទាត់ព្រំដែន ដែលមានប្រវែង ២២៤ គីឡូម៉ែត្រ»។

ស្នងការរងទទួលការងារសេនាធិការ នៃស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ លោក រៀម សរ មានប្រសាសន៍ថា កន្លងមកមានមេខ្យល់បាននាំពលករឆ្លងដែនខុសច្បាប់តាមច្រករបៀងដោយសារខេត្តនេះ មានភូមិសាស្ត្រអំណោយផលនៅជាប់ព្រំដែនថៃងាយស្រួលដល់មេខ្យល់។ លោកបន្តថា៖ «មេខ្យល់ទាំងអស់នេះតែងតែប្រើវិធានការលួងលោមដល់ពលរដ្ឋក្រីក្រ ទីទ័លក្រ អត់មានមុខរបរច្បាស់លាស់ ឬពលរដ្ឋខ្លះ មិនសូវទទួលបានការអប់រំ គាត់ងាយរងគ្រោះក្នុងការឆបោក។ មេខ្យល់នេះពូកែបោកណាស់ ដោយសន្យាថា ធានាឱ្យមានការងារធ្វើ ទោះអត់មានច្បាប់ក៏ដោយ គាត់នឹងនាំទៅតាមច្រករបៀងដែលស្ងាត់ ប៉ុន្តែជាតុពិតមិនពិតនោះទេ គឺមានតែទទួលរងគ្រោះ ការកេងប្រវ័ញ្ចផ្នែកកម្លាំងកាយ និងកម្លាំងពលកម្ម»។ លោកថា ថ្មីៗកន្លងមកនេះ សមត្ថកិច្ចបានបង្ក្រាបមេខ្យល់ ៣ ករណី ហើយសមត្ថកិច្ចបានធ្វើការអប់រំណែនាំប្រជាពលរដ្ឋដែលរងគ្រោះ។

ប្រធានក្រុមប្រឹក្សាខេត្តឧត្តរមានជ័យលោក ស៊ី ប្រាសិទ្ធ បានថ្លែងថា ខេត្តនេះមានច្រកទ្វារព្រំដែនអន្តរជាតិចំនួន ៣ រួមមានច្រកទ្វារព្រំដែនអន្តរជាតិជាំ ស្ថិតក្នុងស្រុកអន្លង់វែង ច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ស្ថិតក្នុងក្រុងសំរោង និងច្រកទ្វារព្រំដែនអន្តរជាតិជប់គគីរ ស្ថិតក្នុងស្រុកបន្ទាយអំពិល ដែលភាគច្រើនបម្រើឱ្យគោលដៅទេសចរណ៍ ការព្យាបាលជំងឺ និងការដោះដូរទំនិញតិចតួច ច្រើនជាងគោលដៅសេដ្ឋកិច្ច។ លោកបន្តថា ប៉ុន្តែក្នុងដំណាក់កាលការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ ច្រកទាំង ៣ ត្រូវបានបិទជាបណ្តោះអាសន្ន លើកលែងតែទំនិញដែលស្ថិតក្រោមច្បាប់បញ្ញត្តិស្តីពីគយ និងការឆ្លងដែនវិលត្រឡប់មកពីប្រទេសថៃរបស់ពលករខ្មែរ ខណៈច្រកជប់គគីរត្រូវបានបិទទាំងស្រុង។ ជាមួយគ្នានេះពលរដ្ឋដែលវិលត្រឡប់មកពីថៃ មិនអនុញ្ញាតឱ្យវិលត្រឡប់ទៅវិញទេ។ ខេត្តឧត្តរមានជ័យមានព្រំប្រទល់ខាងកើតជាប់ខេត្តព្រះវិហារខាងលិចជាប់ខេត្តបន្ទាយមានជ័យខាងត្បូងជាប់ខេត្តសៀមរាប

និងខាងជើងជាប់នឹងខេត្ត ៣ របស់ប្រទេសថៃគឺខេត្តប៊ុរីរុំ ស៊ុរិន្ទ និងស៊ីសាកេតដែលលាតសន្ធឹងតាមជួរភ្នំដងរែក ជាប់ព្រំដែនប្រទេសថៃ ដែលមានប្រវែង ២២៤ គីឡូម៉ែត្រ៕

## អាជ្ញាធរថៃ បញ្ជូនពលករខ្មែរចំនួន ២២២នាក់ មកស្រុកកំណើតវិញ តាមច្រកតំបន់អូរអន្លក់

https://cen.com.kh/ Posted ByPen Srey NeatFebruary 12, 2022

បាត់ដំបង : នៅថ្ងៃសៅរ៍ ទី១២ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុវត្តនតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារ វរសេនាតូចនគរបាលការពារព្រំដែនគោក ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងឃោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យ ទៅទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ។

បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩ រួចចំនួន ២២២នាក់ ស្រី៧៤នាក់ ក្មេង៤៣នាក់ ស្រី១៨នាក់ កម្លាំងយើងបានកត់ឈ្មោះរួច ក្រុមគ្រូពេទ្យធ្វើតេសរហ័ស ជាលទ្ធផល : -អវិជ្ជមានកូវីដ-១៩ ទាំងអស់ , -ពលករចំនួន ៤១នាក់ ស្រី១៦នាក់ ក្មេង៣នាក់ ស្រី១នាក់ បញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន ខេត្តបាតដំបង , -ពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន ១៨១នាក់ ស្រី៥៨នាក់ ក្មេង៤០នាក់ ស្រី១៧នាក់ , ក្នុងនោះបានចាក់វ៉ាក់សាំង ឲ្យក្មេងចាប់ពីអាយុ៥ឆ្នាំដល់១៨ឆ្នាំ ចំនួន១៣នាក់ ស្រី៧នាក់ ។ ក្រុមគ្រូពេទ្យអនុញ្ញាតឲ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ៕ សុទ្ធ លី

## ថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ២០២២

## អង្គការនៃអង្គភាពការពារកុមារ និងគណៈកម្មធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ប្រកាសបន្តប្ដេជ្ញាប្រយុទ្ធប្រឆាំងបទល្មើសលើកុមារទូទាំងប្រទេសកម្ពុជា

https://www.postkhmer.com/ វី សុចាន់ | Publication date 13 February 2022 | 17:52 ICT

**ភ្នំពេញៈ** អង្គការនៃអង្គភាពការពារកុមារហៅថា CPU និងគណៈកម្មធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ប្រកាសបន្តប្ដេជ្ញាប្រយុទ្ធប្រឆាំងបទល្មើសលើកុមារទូទាំងប្រទេសកម្ពុជាខណៈកាលពីដើមខែនេះ មានករណីឃាតកម្មទៅលើមនុស្សមួយគ្រួសារ ដែលមានមនុស្សពេញវ័យ ២ នាក់ និងកុមារ ៣ នាក់ ថែមទាំងមានការប៉ុនប៉ងសម្លាប់កុមារម្នាក់ទៀតនៅខេត្តមណ្ឌលគិរី។ ការប្រកាសបន្តការប្ដេជ្ញាចិត្តនេះ ធ្វើឡើងក្នុងកិច្ចប្រជុំរវាងមន្ត្រីអង្គការ CPU និងលោកស្រី ជូ ប៊ុន អេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃ គ.ជ.ប.ជ នាថ្ងៃទី ១០ ខែកុម្ភៈ។ អង្គការ CPU បញ្ជាក់ក្នុងហ្វេសប៊ុកនាថ្ងៃទី ១១ ខែកុម្ភៈ ថា កិច្ចប្រជុំនេះធ្វើឡើង គឺដើម្បីពិភាក្សាអំពីគម្រងសម្រាប់ថ្ងៃអនាគតរបស់អង្គការ CPU និងបន្តការប្ដេជ្ញារវាងភាគីទាំង២ក្នុងការប្រយុទ្ធប្រឆាំងបទល្មើសលើកុមារទូទាំងប្រទេសកម្ពុជា។ ហ្វេសប៊ុក CPU បញ្ជាក់ថា៖ «យើងបានធ្វើកិច្ចប្រជុំដ៏ល្អមួយជាមួយ លោកជំទាវ ជូ ប៊ុន អេងរួមទាំងអគ្គប្រធាននៃការិយាល័យផ្នែកផ្សេងៗ ដើម្បីពិភាក្សាអំពីគម្រោងសម្រាប់ថ្ងៃអនាគតរបស់អង្គភាពការពារកុមារ (CPU) និងបន្តការប្ដេជ្ញារបស់យើងក្នុងការប្រយុទ្ធប្រឆាំងបទល្មើសលើកុមារទូទាំងប្រទេស

កម្ពុជា»។ អង្គការ CPU បន្តថា៖ «លោកជំទាវ [ជូ ប៊ុនអេង] បានថ្លែងអំណរគុណដល់ក្រុមការងាររបស់អង្គភាពការពារកុមារ ចំពោះការបំពេញភារកិច្ច និងការសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា។ នេះគឺជាឱកាសដ៏ល្អមួយដើម្បីបង្ហាញពីគម្រោងសេវាកម្ម និងវគ្គបណ្តុះបណ្តាល ដែលយើងកំពុងរៀបចំសម្រាប់ប៉ុន្មានឆ្នាំខាងមុខនេះ។ អង្គភាពការពារកុមារ (CPU) និងលោកជំទាវ បានបង្ហាញភាពប្តេជ្ញាក្នុងការបន្តកិច្ចសហការនេះ ដើម្បីប្រយុទ្ធប្រឆាំងបទល្មើសលើកុមារ និងការអនុវត្តគម្រងសំខាន់ៗបន្ថែម»។

លោកស្រី ជូ ប៊ុនអេង ប្រាប់ភ្នំពេញប៉ុស្ដិ៍នាថ្ងៃទី ១៣ ខែកុម្ភៈ ថា លោកស្រីគាំទ្រចំពោះ CPU ដែលត្រៀមស្ថាបនាអគារសម្រាប់ជួយជនរងគ្រោះជាកុមារ ជាពិសេសចំពោះបទឧក្រិដ្ឋទៅលើកុមារ ព្រោះ CPU មានក្រុមគ្រូពេទ្យ កន្លែងធ្វើកោសលវិច័យ កន្លែងផ្តល់សេវាប្រឹក្សា ឬមានជម្រកបណ្ដោះអាសន្នសម្រាប់ការសង្គ្រោះ ដើម្បីសហការជាមួយសមត្ថកិច្ចនៅក្នុងប្រតិបត្តិការស្រាវជ្រាវចំពោះបទឧក្រិដ្ឋ។ លោកស្រីថ្លែងថា៖ «យើងនឹងធ្វើកិច្ចការជាមួយគ្នាពាក់ព័ន្ធទៅនឹងបង្ការទប់ស្កាត់ ដោយសារយើងអត់ចង់ឱ្យជនរងគ្រោះហ្នឹងក្លាយទៅជាជនរងគ្រោះ ហើយបានយើងជួយសង្គ្រោះ [តាមក្រោយ] គឺយើងចង់បង្ការទប់ស្កាត់កុំឱ្យគាត់រងគ្រោះតែម្តង»។ លោកស្រី ជូ ប៊ុនអេង បន្តថា៖«អ៊ីចឹង យើងនឹងយកទិន្នន័យដែលបានមកពីខាង CPU ឬមួយក៏ក្រសួងស្ថាប័នពាក់ព័ន្ធហ្នឹង ដើម្បីយកមកចងក្រងធ្វើជាឯកសារដើម្បីធ្វើការអប់រំផ្សព្វផ្សាយហ្នឹង ហើយនិងរកគ្រប់វិធីដើម្បីបង្ការទប់ស្កាត់និងការពារកុមារហ្នឹងពីភាពរងគ្រោះដោយឧក្រិដ្ឋកម្មផ្សេងៗ»។

លោក James McCabe នាយកប្រតិបត្តិនៃអង្គការ CPU មិនបានឆ្លើយតបទៅនឹងសំណួរភ្នំពេញប៉ុស្ដិ៍កាលពីថ្ងៃទី ១៣ ខែកុម្ភៈ តាមប្រព័ន្ធតេឡេក្រាមនោះទេ។

គួរបញ្ជាក់ថា កាលពីថ្ងៃទី ១ កុម្ភៈ មានអំពើឃាតកម្មដ៏ឃោរឃៅមួយកើតឡើងទៅលើក្រុមគ្រួសារជនជាតិដើមភាគតិចព្នង ១ គ្រួសារ នៅចំណុចព្រៃចោត ស្ថិតក្នុងភូមិមេប៉ៃ ឃុំពូជ្រៃ ស្រុកពេជ្រាដាខេត្តមណ្ឌលគិរី។ អំពើឃាតកម្មនោះ មានជនរងគ្រោះក្មេង ចាស់ ប្រុស ស្រី ៥ នាក់បានស្លាប់ និងកុមារាអាយុ ១២ ឆ្នាំម្នាក់ទៀតបានរងរបួសធ្ងន់ ហើយក្រោយមក កុមារាដ៏កំសត់នោះត្រូវបានបញ្ជូនមកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យមួយក្នុងរាជធានីភ្នំពេញ។ ១សប្តាហ៍ក្រោយអំពីឃាតកម្មនេះ គឺនៅថ្ងៃទី ៨ ខែកុម្ភៈតុលាការខេត្តមណ្ឌលគិរី បានសម្រេចចោទប្រកាន់ជនសង្ស័យ ៦ នាក់ក្នុងអំពើឃាតកម្មដ៏ព្រៃផ្សៃនេះពីបទ «ឃាតកម្មគិតទុកជាមុន»និងបទ «ផ្ដើមគំនិតក្នុងអំពើឃាតកម្មគិតទុកជាមុន»៕

## អាជ្ញាធរស្រុកសំពៅលូន
## បានទទួលពលករខ្មែរ ៤៩នាក់ វិលត្រឡប់មកពីថៃ រកឃើញវិជ្ជមានកូវីដ ២នាក់

https://www.postkhmer.com/ ភ្នំពេញ ប៉ុស្តិ៍ | Publication date 12 February 2022 | 10:06 ICT

**បាត់ដំបង:** អាជ្ញាធរស្រុកសំពៅលូន នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០២២ បានទទួលពលករវិលត្រឡប់មកពីប្រទេសថៃ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ចំនួន ៤៩នាក់ក្នុងនោះមានស្រី ២៤នាក់ ក្មេង ០៨នាក់ (ក្មេងស្រី ០៤ នាក់) ហើយត្រូវបានធ្វើតេស្តរហ័សរកឃើញវិជ្ជមានជំងឺកូវីដ១៩ ចំនួន ២ នាក់។

បើតាមអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រោយពីទទួលពលករទាំងនេះ កម្លាំងសមត្ថកិច្ចពាក់ព័ន្ធ បានធ្វើការកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ ធ្វើការអប់រំណែនាំ និងសុំឱ្យពលករទាំងនោះ សហការជាមួយកម្លាំងសមត្ថកិច្ចដើម្បីត្រួតពិនិត្យសម្ភារហាមឃាត់ (ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក)។ ពលករទាំងនោះ ត្រូវបានក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុក សំពៅលូន ធ្វើតេស្តរហ័ស និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍ ហើយជាលទ្ធផលរកឃើញពលករ ២ នាក់ (ស្រី ១នាក់) វិជ្ជមានកូវីដ១៩។ បន្ទាប់មកក្រុមគ្រូពេទ្យ បានអនុញ្ញាតឱ្យពលករ ត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន ៣១ នាក់ ក្នុងនោះមានស្រី ១៣នាក់ ក្មេង ០៧នាក់ ក្មេងស្រី ០៣នាក់ (ចំពោះអ្នក

មានបណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ)។ ចំណែកអ្នកមានវិជ្ជមានកូវីដ១៩ និងអ្នកមានបណ្ណចាក់វ៉ាក់សាំងតែស្លែនអត់ចេញ ចំនួន ១៨ នាក់ ស្រី ១១នាក់ (ក្មេងស្រី ០១នាក់) ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័ក ចំណុចពេងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង ៕

## ស្នើនៃក្តីសង្ឃឹមសម្រាប់ពលករចំណាកស្រុក ខ្មែរឆ្លងដែនខុសច្បាប់ ខណៈនាយករដ្ឋមន្ត្រីថៃជំរុញឱ្យពួកគេរួមជាមួយកម្លាំងពលកម្មថៃ

https://www.khmertimeskh.com/ February 12, 2022

នាយករដ្ឋមន្ត្រី ប្រាយុទ្ធ ចាន់អូចា បានមានប្រសាសន៍កាលពីថ្ងៃសុក្រថា ជនចំណាកស្រុកខុសច្បាប់ដែលត្រូវបានចាប់បានពេលលួចឆ្លងព្រំដែន គួរតែត្រូវបានចុះឈ្មោះដើម្បីធ្វើការដោយស្របច្បាប់នៅក្នុងប្រទេសថៃ ដែលកង្វះកម្លាំងពលកម្ម និងកំពុងគំរាមកំហែងដល់ការស្តារសេដ្ឋកិច្ចឡើងវិញ។ ពលករចំណាកស្រុកកម្ពុជាត្រូវបានបញ្ជូនទៅបន្ទប់ចំនួន ២៩១ ដែលអាចដាក់កម្មករចំនួន ១,០៣៨ នាក់ នៅខេត្តស៊ីសាកេត ខេត្តសុរិន្ទ ខេត្តស្រះកែវ និងខេត្តត្រាត។ លោកនាយករដ្ឋមន្ត្រីបានផ្តល់ការណែនាំក្នុងពេលធ្វើជាប្រធានមជ្ឈមណ្ឌលគ្រប់គ្រងស្ថានការណ៍កូវីដ-១៩ កាលពីថ្ងៃសុក្រ ដើម្បីពិចារណាលើវិធានការអនុញ្ញាតឱ្យពលករពីកម្ពុជា មីយ៉ាន់ម៉ា និងឡាវ អោយចូលប្រទេសថៃឡើងវិញ ទោះបីជាស្ថិតក្នុងស្ថានភាពកូវីដ-១៩ ក៏ដោយ។

អ្នកនាំពាក្យ CCSA លោក Taweesilp Visanuyothin បានមានប្រសាសន៍ថា លោកប្រាយុទ្ធ បានចោទសួរថា ហេតុអ្វីបានជានៅតែមានអ្នកស្វែងរកការងារពីប្រទេសជិតខាងទាំងបី ត្រូវបានចាប់ខ្លួនជារៀងរាល់ថ្ងៃសម្រាប់ការព្យាយាមលួចចូលមកក្នុងព្រះរាជាណាចក្រថៃ។ លោកនាយករដ្ឋមន្ត្រីបានថ្លែងថា ស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាលគួរតែសម្របសម្រួល ដើម្បីរកមធ្យោបាយឲ្យពលករទាំងនេះចូលរួមជាមួយកម្លាំងពលកម្មថៃ ដោយស្របច្បាប់។ យោងតាមសហព័ន្ធឧស្សាហកម្មថៃ បច្ចុប្បន្នប្រទេសថៃកំពុងប្រឈមនឹងការខ្វះខាតពលករចំណាកស្រុកប្រមាណ ៨០ ម៉ឺននាក់ដែលត្រូវការសម្រាប់វិស័យផលិតកម្ម សេវាកម្ម និងទេសចរណ៍។ អ្នកនាំពាក្យមិនបាននិយាយថា តើជនចំណាកស្រុកខុសច្បាប់ដែលត្រូវបានចាប់ខ្លួនរួចហើយនឹងត្រូវបញ្ជូនត្រឡប់ទៅប្រទេសរបស់ពួកគេវិញឬអត់នោះទេ។ បច្ចុប្បន្នពួកគេប្រឈមនឹងការផាកពិន័យនិងនិរទេស។

ក្រសួងការងារបានរាយការណ៍ថា ខ្លួនមានបន្ទប់ចត្តាឡីស័កចំនួន ៤៧៦ នៅ ១៧ ទីតាំងសម្រាប់អ្នកស្វែងរកការងារពីប្រទេសមីយ៉ាន់ម៉ា និងកម្ពុជា។ អ្នកនាំពាក្យរូបនេះបានបន្ថែមថា ពលករអនុវត្តវិធានការរឹតបន្តឹងការធ្វើចត្តាឡីស័កដូចគ្នា នឹងអ្នកធ្វើដំណើរបរទេសដទៃទៀតដែរ។ សម្រាប់ជនចំណាកស្រុកមីយ៉ាន់ម៉ា គឺមានមណ្ឌលចត្តាឡីស័កចំនួនប្រាំមួយនៅខេត្តឈៀងរ៉ៃ តាក កាន់ចាណាបុរី និងរ៉ាណុង ដែលមាន ១៨៥ បន្ទប់ និងអាចដាក់កម្មករបាន ៣៣០នាក់ ។ អ្នកនាំពាក្យមិនបានផ្តល់ទិន្នន័យស្តីពីកន្លែងធ្វើចត្តាឡីស័កសម្រាប់ពលករឡាវទេ។ *Nation Thailand*

## ពលករខ្មែរនៅក្រៅប្រទេសផ្ញើប្រាក់ទៅផ្ទះចំនួន ២,៨ពាន់លានដុល្លារកាលពីឆ្នាំមុន

https://www.khmertimeskh.com/ February 12, 2022

រដ្ឋមន្ត្រីក្រសួងការងារកម្ពុជា លោក អ៊ិត សំហេង បានមានប្រសាសន៍នៅថ្ងៃសុក្រនេះថា ប្រជាជនខ្មែរប្រមាណ ១,៣ លាននាក់ បានទៅធ្វើការនៅក្រៅប្រទេស ដោយបានផ្ញើប្រាក់ទៅផ្ទះវិញប្រមាណ ២,៨ ពាន់លានដុល្លារក្នុងឆ្នាំ ២០២១។ លោករដ្ឋមន្ត្រីបានបង្ហាញតួលេខនៅក្នុងសន្និបាតប្រចាំឆ្នាំរបស់បេឡាជាតិរបបសន្តិសុខសង្គម ហើយបានបន្ថែមថា ពលករចំណាកស្រុកចំនួន ៥២៨,៧៩៩នាក់ គឺជាស្ត្រី។ លោក អ៊ិត សំហេង បានមាន

ប្រសាសន៍ថា "ការផ្ញើរប្រាក់មិនត្រឹមតែបានធ្វើឱ្យជីវភាពរបស់សមាជិកគ្រួសាររបស់ពួកគេមានភាពប្រសើរឡើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាផងដែរ។ លោកបន្តថា ពលករភាគច្រើនធ្វើការនៅប្រទេសថៃ ក្រៅពីនោះគឺធ្វើការនៅកូរ៉េខាងត្បូង ម៉ាឡេស៊ី ជប៉ុន សិង្ហបុរី ចិនហុងកុង និងអារ៉ាប៊ីសាអូឌីត។ លោកបានបន្ថែមថា ពលករខ្មែរប្រមាណ ១,២២លាននាក់បានទៅធ្វើការនៅប្រទេសថៃ ជាង ៤៥, ០០០នាក់ នៅកូរ៉េខាងត្បូង ២៣,០២៧នាក់ នៅម៉ាឡេស៊ី ១១,៤៥៣នាក់ នៅជប៉ុន៨២១នាក់ នៅសិង្ហបុរី ៨២១នាក់ នៅចិនហុងកុង២០២នាក់ និងអារ៉ាប៊ីសាអូឌីត ៤៣នាក់។ *សារព័ត៌មានស៊ីនហួ Xinhua*

## អាជ្ញាធរស្រុកសំពៅលូន ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ និងប្រគល់ទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣

https://gdlf-kh.com/ 2022/02/13/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃអាទិត្យ ១២កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្ត្រភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង សរុបបានចំនួន០៧នាក់ (ស្រី០២នាក់ ក្មេងប្រុស០២នាក់)។ ក្រោយពីទទួលបាន កម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំ រួចក៏បានប្រគល់បងប្អូនទាំងអស់អោយទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣។

## កម្លាំងសមត្ថកិច្ច ទទួលប្រជាពលរដ្ឋ ត្រឡប់ចូលប្រទេសកម្ពុជាវិញចំនួន ១៣៣នាក់ នៅស្រុកកំរៀង

https://cen.com.kh/ Posted ByPen Srey NeatFebruary 14, 2022

បាត់ដំបង ៖ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខ តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យទៅទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃ បានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ។ ប្រជាពលរដ្ឋចំនួន ១៣៣នាក់ (ស្រី ៥១នាក់) ក្មេង ២៤នាក់ (ក្មេងស្រី ១១នាក់) កម្លាំងសមត្ថកិច្ចបានសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩ រួច ក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័ស ជាលទ្ធផល ៖ -អវិជ្ជមានកូវីដ-១៩ ទាំងអស់ , -ពលករចំនួន ៤៩នាក់ (ស្រី ១៥នាក់) ក្មេង ៧នាក់ (ស្រី ៣នាក់) បញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន ខេត្តបាតដំបង

, -ពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន ៨៤នាក់ (ស្រី ៣៦នាក់) ក្មេង ១៧នាក់ (ស្រី ៨នាក់)។ ក្នុងនោះ បានចាក់វ៉ាក់សាំងឲ្យក្មេងចាប់ពីអាយុ៥ឆ្នាំដល់១៨ឆ្នាំ ចំនួន ៧នាក់ (ស្រី ៣នាក់) ក្រុមគ្រូពេទ្យអនុញ្ញាតឲ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

## អាជ្ញាធរថា លែងមានការលួចឆ្លងដែនទៅកាប់គ្រញូងនៅប្រទេសថៃ តាមច្រកខេត្តឧត្តរមានជ័យ

https://btv.com.kh/ 02/14/2022 12:02 PM

ឧត្តរមានជ័យ៖ អាជ្ញាធរខេត្តឧត្តរមានជ័យ បានអះអាងថា រយៈពេលចុងក្រោយនេះ ករណីលួចឆ្លងដែនដោយខុសច្បាប់របស់ប្រជាពលរដ្ឋ តាមច្រកព្រំដែនជាប់ខេត្តឧត្តរមានជ័យ ទៅកាប់គ្រញូងនៅប្រទេសថៃ លែងមានទៀតហើយ ។

លោកឧត្តមសេនីយ៍ត្រី រៀម សរ ស្នងការរងខេត្តឧត្តរមានជ័យ ទទួលបន្ទុកសេនាធិការ បានឱ្យដឹង ថា កន្លងទៅ ករណីលួចឆ្លងដែនទៅកាប់គ្រញូងនៅប្រទេសថៃ តាមច្រកខេត្តឧត្តរមានជ័យ គឺមានច្រើន តាមរយៈការអូសទាញផ្សេងៗ ពីសំណាក់ឈ្មួញ ប៉ុន្តែបច្ចុប្បន្ន គឺលែងមានហើយ ព្រោះអាជ្ញាធរ បានចាត់វិធានការទប់ស្កាត់និងការអប់រំផ្សេងៗ ។ លោកឧត្តមសេនីយ៍ត្រី បានបន្តថា មួយវិញទៀត ដើមឆ្នាំ២០២២នេះ ករណីលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ តាមច្រកខេត្តឧត្តរមានជ័យ ក៏ពុំមានផងដែរ ព្រោះអាជ្ញាធរ មានសមត្ថកិច្ចនៅតាម បន្ទាត់ព្រំដែន បានទប់ស្កាត់យ៉ាងតឹងរឹងបំផុត ហើយពលរដ្ឋ បានយល់ដឹងច្រើនពីបញ្ហាលួចឆ្លងដែននេះ រួមទាំងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងប្រទេសថៃច្រើនករណីក្នុងមួយថ្ងៃៗនោះ ។ ឧត្តមសេនីយ៍ត្រី រៀម សរ បានបញ្ជាក់ថា កាលពីឆ្នាំ២០២១ អាជ្ញាធរខេត្ត បានចាប់ខ្លួនមេខ្យល់ ដែលតែងនាំពលករលួចឆ្លងដែនខុសច្បាប់ ទៅប្រទេសថៃ បានចំនួន៣នាក់ ដែលពួកគេទាំងនោះ តែងតែ លួងលោម អូសទាញ និងញុះញង់ពលរដ្ឋឲ្យលួចឆ្លងដែន៕អត្ថបទ ៖ បាន សុខរិទ្ធិ

## ថ្ងៃទី១៦ ខែ កុម្ភៈ ឆ្នាំ២០២២

## ពលករខ្មែរជាង ១០០នាក់ ត្រូវទាហានថៃ ចាប់បញ្ជូនមកកាន់ស្រុកកំណើតវិញ

https://www.gntimes.com/ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២

បាត់ដំបង៖ កម្លាំងទាហានថៃ បានចាប់បញ្ជូនពលករខ្មែរប្រុសស្រីជាង ១០០នាក់ ប្រគល់ត្រឡប់មកឱ្យអាជ្ញាធរកម្ពុជាវិញ ក្រោយរកឃើញថា ពួកគាត់លួចឆ្លងដែនដោយគ្មានច្បាប់អនុញ្ញាត ។

លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៩ បានឱ្យដឹងថា កាលពីថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២២ ម្សិលមិញនេះ លោកបានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងយុទ្ធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យ ទៅទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ។ លោកបន្តថា បន្ទាប់ពីសាកសួរកត់ឈ្មោះរួចឃើញថា ពលករខ្មែរដែលទទួលត្រឡប់មកស្រុកកំណើតនាថ្ងៃនេះ សរុបមាន ១៣៣នាក់ ក្នុងនោះ ស្រី ៥១នាក់ ក្មេង២៤នាក់ ត្រូវបានក្រុមគ្រូពេទ្យធ្វើតែស្តរហ័ស ជាលទ្ធផលអវិជ្ជមានកូវីដ-១៩ ទាំងអស់ ប៉ុន្តែពលករចំនួន ៤៩នាក់ ស្រី ១៥នាក់ និងក្មេង ៧នាក់ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន ។ ដោយឡែកពលករដែលមានកាតចាក់វ៉ាក់សាំង ៨៤នាក់ ស្រី ៣៦នាក់ និងក្មេង ១៧នាក់ ត្រូវបានក្រុមគ្រូពេទ្យធ្វើការអប់រំណែនាំអំពីវិធានការ ការពារ ការឆ្លងជំងឺកូវីដ-១៩ រួចអនុញ្ញាតឱ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ៕

## ថ្ងៃនេះ! ថៃទទួលពលករខ្មែរជាង២០០នាក់ឲ្យទៅធ្វើការនៅលើទឹកដីថៃ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ១៥ ខែ កុម្ភៈ ឆ្នាំ ២០២២ ម៉ោង ១២:៤៥

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរជាង២០០នាក់ ត្រូវបានភាគីថៃអនុញ្ញាតឲ្យចូលទៅធ្វើការលើទឹកដីរបស់គេ នៅព្រឹកថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ ហើយនេះជាលើកទី៣ហើយ សម្រាប់ពលករខ្មែរដែលបានចេញពីកម្ពុជា តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតគិតត្រឹមថ្ងៃនេះ។ ពលករដែលចេញទៅធ្វើការលើទឹកដីថៃនៅថ្ងៃនេះ គឺតាមរយៈក្រុមហ៊ុន CAPRICORN MANPOWER ទៅធ្វើការផ្នែករោងចក្រសាច់មាន់ ក្នុងខេត្តនគររាជសីម៉ា នេះបើតាមការឲ្យដឹងពីតំណាងក្រុមហ៊ុនខាងលើ។

តំណាងក្រុមហ៊ុន សុំមិនអាចបញ្ជាក់លម្អិតពីចំនួនពលករ និងស្រីប្រុសប៉ុន្មាននោះទេ ដោយត្រឹមប្រាប់ថាចំនួនពលករសរុបជាង២០០នាក់តែប៉ុណ្ណោះ ប៉ុន្តែមានអ្នកខ្លះអវត្តមាន ហើយថានេះជាលើកទី១ សម្រាប់ក្រុមហ៊ុនខ្លួនដែលនាំពលករទៅធ្វើការលើទឹកដីថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត។ គួរបញ្ជាក់ថា ក្រោយភាគីថៃបើកទទួលពលករកម្ពុជា តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ចាប់ពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២២ គឺមានក្រុមហ៊ុនចំនួន២ បាននាំពលករទៅធ្វើការលើទឹកដីថៃ ដោយក្រុមហ៊ុន ទូចម៉ាណាក់ម៉ែនផៅវ័រស៊ុប្លាយ បាននាំចេញ២លើក គឺលើកទី១ នៅថ្ងៃទី១ ខែកុម្ភៈ ចំនួន១៨៥នាក់ ហើយលើកទី២ នៅថ្ងៃទី៥ ខែកុម្ភៈ ចំនួន១៤២នាក់ និងថ្ងៃនេះ គឺក្រុមហ៊ុន CAPRICORN MANPOWER ជាង២០០នាក់ផងដែរ។

លោកវរសេនីយ៍ សេម មករា ប្រធានសេនាធិការនគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត បានប្រាប់តាមទូរស័ព្ទថា ចំនួនពលករដែលចេញពីកម្ពុជាទៅធ្វើការលើទឹកដីថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតនាថ្ងៃនេះ មិនទាន់ទទួលបានទិន្ន័យច្បាស់លាស់ពីខាងក្រុមហ៊ុននាំពលករនៅឡើយទេ។ លោកថា នេះជាលើកទី៣ហើយ ដែលភាគីថៃទទួលយកពលករខ្មែរតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ផ្អែកលើអនុសារណៈ MOU រវាងក្រសួងការងារកម្ពុជា និងថៃ៕

## អាជ្ញាធរស្រុកសំពៅលូន បន្តទទួល
## ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/02/15/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង១៣និង៣០នាទី នាថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០២នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ពៅ ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន២៥នាក់ (ស្រី១៣នាក់ ក្មេង០២នាក់ ក្មេងស្រី ០១នាក់)។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីត្រួតពិនិត្យសម្ភារៈហាមឃាត់ (ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក) ជាលទ្ធផលដកហូតបាន ដែកកែង០១, កាំបិត០១ដើម, ញញួរ០២, ចបជីក០១, ដែកជ្រុង០១ និងដែកមូល០១ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល វិជ្ជមានក្មេងស្រីម្នាក់ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន១៣នាក់ ស្រី០៦នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ)។ ចំណែកអ្នកមានវិជ្ជមានកូវីដ-១៩ និងអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្វែនអត់ចេញ ចំនួន១២នាក់ (ស្រី០៧នាក់ ក្មេង០២នាក់ ក្មេងស្រី០១នាក់) ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្ហៅ ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## ថ្ងៃទី១៨ ខែ កុម្ភៈ ឆ្នាំ២០២២

### ពលករ MOU ខ្មែរ ទៅធ្វើការនៅថៃ ៤០០ នាក់ អវិជ្ជមានកូវីដទាំងអស់

https://www.kampucheathmey.com/ ថ្ងៃពុធ ១៦ កុម្ភៈ ២០២២ដោយ Sorn Phanith

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា បានឱ្យដឹងនៅរសៀលថ្ងៃទី ១៦កុម្ភៈនេះថា ពលករ MOU ៤០០ នាក់បញ្ជូនទៅធ្វើការនៅប្រទេសថៃ កាលពីថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០២២ មានលទ្ធផលតេស្តអវិជ្ជមានកូវីដ១៩ទាំងអស់។ ប៉ុន្តែត្រូវធ្វើចត្តាឡីស័ក ៧ ថ្ងៃទៀតមុនចេញទៅធ្វើការនៅតាមរោងចក្រ។ លោកបានបន្តថាពលករទាំងនោះ បានបញ្ជូនតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែតទល់នឹងខេត្តស្រះកែវ ហើយពេលទៅដល់ទឹកដីថៃ បានធ្វើតេស្តលើកទី ១ រួចហើយដោយទទួលបានលទ្ធផលអវិជ្ជមានទាំងអស់ ហើយកំពុងធ្វើចត្តាឡីស័ក ៧ ថ្ងៃ នៅបន្ទប់ដ៏ស្អាតដោយមានការផ្គត់ផ្គង់អាហារ ៣ ពេលដោយឥតគិតថ្លៃ ហើយនៅថ្ងៃទី ៧ ត្រូវធ្វើតេស្តម្តងទៀត បើលទ្ធផលនៅអវិជ្ជមានទៀតទើបអនុញ្ញាតឱ្យទៅរោងចក្រធ្វើការតែម្តង។ លោកបានបន្ថែមថា ការទទួលបានលទ្ធផលតេស្តអវិជ្ជមាននេះ បានធ្វើឱ្យភាគីថៃមានទំនុកចិត្តខ្ពស់មកលើពលករខ្មែរយើង ព្រោះពួកគេបានចាក់វ៉ាក់សាំងបានគ្រប់ដូសរហូតដល់ដូសជំរុញ ឬដូសទី ៣ និងដូសទី ៤ ដែលធ្វើឱ្យកម្រិតហានិភ័យនៃការឆ្លងមានកម្រិតទាបបំផុត។ លោកបានបន្តទៀតថា ពលករខ្មែរដែលអាចទៅធ្វើការនៅប្រទេសថៃ ត្រូវមានលក្ខខណ្ឌមួយចំនួនដូចជា ត្រូវមានកាតចាក់វ៉ាក់សាំង ធ្វើតេស្តរកជំងឺកូវីដ១៩ រយៈពេល ៧២ ម៉ោង តាមម៉ាស៊ីនPCR ឬតេស្តរហ័ស ដែលធ្វើដោយគ្រូពេទ្យជំនាញ ដើម្បីបញ្ជាក់វិញ្ញាបនបត្រថា មិនមានឆ្លងជំងឺកូវីដ១៩។

ពេលទៅដល់ព្រំដែនពលករ ត្រូវធ្វើតេស្តហើយបើលទ្ធផលតេស្តអវិជ្ជមាន ត្រូវបន្តធ្វើចត្តាឡស័ករយៈពេល ៧ ថ្ងៃ និងថ្ងៃទី ៧ ត្រូវធ្វើតេស្តម្តងទៀត បើលទ្ធផលនៅតែអវិជ្ជមានទៀត ទើបអនុញ្ញាតឱ្យទៅរោងចក្រធ្វើការតែម្តង។ លោកបានឱ្យដឹងទៀតថា ក្នុងករណីមានវិជ្ជមានកូវីដ១៩ ត្រូវបញ្ជូនទៅកន្លែងព្យាបាលហើយរាល់ការចំណាយទៅលើព្យាបាលជាបន្ទុករបស់និយោជកថៃទាំងស្រុង។ លោក អន ប៊ុនហាក់ បានបញ្ជាក់ថា ពលករចំនួន ៤០០ នាក់ ទៅធ្វើការនៅប្រទេសថៃ គឺធ្វើការនៅរោងចក្រស៊ីភី ជារោងចក្រចំណីអាហារធ្វើសាច់មាន់ សាច់ជ្រូកដោយពួកគេម្នាក់ៗទទួលបានប្រាក់ខែចាប់ពី ៥០០ ទៅ ៧០០ ដុល្លារក្នុង ១ ខែ។ ចំណែកពលករ ២២០ នាក់ដែលបានបញ្ជូនទៅកាលពីថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ ២០២២ បានចេញទៅធ្វើការរោងចក្រសាច់មាន់ PANU SPOULTRY GROUP CO., LTD. នៅខេត្តឈុនបុរីរួចរាល់ហើយដែរ។ **អត្ថបទ៖ សំអឿន**

## ហាងខារ៉ាអូខេ «នាគក្រហម»
## នៅឃុំខ្លុប ស្រុកស្អាង មានដាក់ស្រីស្អាត បន្តបំបម្រើសេវាក្តៅសាច់

https://kbn.news/ February 17, 2022

ខេត្តកណ្តាល ៖ កាលពីពេលថ្មីៗនេះ មានប្រជាពលរដ្ឋ បានរាយការណ៍ចូលក្នុងប្រអប់សារផេកស្នងការដ្ឋាននគរបាលខេត្តកណ្តាល មានខ្លឹមសារថា «មាន KTV មួយកន្លែងនៅភូមិខ្លុបក្រោម ឃុំខ្លុប ស្លាកយីហោនាគក្រហម លួចលាក់បម្រើសេវាផ្លូវភេទ ដោយមិនខ្លាចច្បាប់បន្តិចសោះ ផ្តល់ទីតាំងឲ្យស្រីៗរួមភេទអញ្ជឹង តើខុសច្បាប់អត់បង»។ក្រោយពីទទួលបានព័ត៌មាននេះភ្លាម ក្រុមការងារព័ត៌មាន និងប្រតិកម្មរហ័ស នៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល ដឹកនាំដោយលោកឧត្តមសេនីយ៍ទោស្នងការ បានបញ្ជាឲ្យកម្លាំងអធិការដ្ឋាននគរបាលស្រុកស្អាង ចុះធ្វើការស្រាវជ្រាវករណីខាងលើ ដោយនៅថ្ងៃ១៥ ខែកុម្ភៈ ឆ្នាំ២០២២ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលខ្លុប បានចុះដល់ទីតាំងហាង ខារ៉ាអូខេ ដែលមានស្លាកយីហោ «នាគក្រហម» ដែលម្ចាស់ទីតាំងមានឈ្មោះ គីម ចាន់ធឿន ភេទប្រុស អាយុ៣៨ឆ្នាំ មានទីលំនៅ ភូមិខ្លុបក្រោម ឃុំខ្លុប ស្រុកស្អាង និងបានធ្វើការអប់រំ ណែនាំ ដល់ម្ចាស់អាជីវកម្មខារ៉ាអូខេខាងលើ ឲ្យបញ្ឈប់ដាច់ខាតការលួចលាក់ផ្តល់ទីតាំងបម្រើសេវាកម្មផ្លូវភេទ និងបង្កភាពញ៉េវញ៉ៃគ្មានសណ្តាប់ធ្នាប់តាមផ្លូវសាធារណៈ ចាប់ពីថ្ងៃធ្វើកិច្ចសន្យានេះតទៅ ។ជាមួយគ្នានោះដែរ ម្ចាស់ហាង «នាគក្រហម» មានឈ្មោះ គីម ចាន់ធឿន បានសន្យាបញ្ឈប់ដាច់ខាតការលួចលាក់ផ្តល់ទីតាំងបម្រើសេវាកម្មផ្លូវភេទ និងបង្កភាពញ៉េវញ៉ៃគ្មានសណ្តាប់ធ្នាប់តាមផ្លូវសាធារណៈ ចាប់ពីថ្ងៃធ្វើកិច្ចសន្យានេះតទៅ ។ បើថ្ងៃក្រោយប្រព្រឹត្តខុសសន្យាខាងលើនេះ នឹងទទួលខុសត្រូវចំពោះមុខច្បាប់៕

## ក្នុងមួយថ្ងៃៗ មានពលករខ្មែរ
## ត្រឡប់មកពីថៃ ចន្លោះពី ២០០ ទៅ ៣០០នាក់ តាមច្រកព្រំដែនខេត្តប៉ៃលិន

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ១៧ កុម្ភៈ ២០២២ដោយ sopheak khoun

ពលករខ្មែរ ដែលត្រឡប់មកពីប្រទេសថៃ តាមច្រកទ្វារព្រំដែន នៅក្នុងខេត្តប៉ៃលិន មានចំនួនចន្លោះពី ២០០ ទៅ ៣០០ នាក់ ក្នុងមួយថ្ងៃៗ។ នេះបើតាមការឲ្យដឹងពីអាជ្ញាធរខេត្តប៉ៃលិន។

លោក គោស៊ុំ ប៊ុនសឿត អភិបាលរងខេត្តប៉ៃលិន បានមានប្រសាសន៍ក្នុងសន្និសីទសារព័ត៌មាន ស្តីពី "វឌ្ឍនភាពមូលដ្ឋានឃុំ-សង្កាត់ និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តប៉ៃលិន" នាព្រឹកថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០២២ នេះថា នាពេលបច្ចុប្បន្ននេះ មានប្រជាពលករខ្មែរ ដែលត្រឡប់មកពីប្រទេសថៃ តាមច្រកទ្វារព្រំដែនខេត្តប៉ៃលិន ចំនួនចន្លោះពី ២០០ ទៅ ៣០០នាក់ ក្នុងមួយថ្ងៃៗ។ លោកថា អាជ្ញាធរ និងមន្ត្រីសុខាភិបាល ប្រចាំនៅច្រកទ្វារព្រំដែន បានត្រួតពិនិត្យ និងធ្វើតេស្តយ៉ាងជិតដល់ចំពោះពលករ ដែលត្រឡប់មកពីប្រទេសថៃនេះ ដើម្បីបង្ការទប់ស្កាត់ការឆ្លងរាលដាល ជំងឺកូវីដ-១៩។ អភិបាលរងខេត្តប៉ៃលិន បានបន្ថែមថា «ចឹងអ្នកដែលត្រឡប់មកវិញ យើងបែងចែកគាត់ច្បាស់ អ្នកដែលមានកាតចាក់វ៉ាក់សាំង យើងមើលទៅយើងធ្វើតេស្តរ៉ាពីត អ្នកមានកាតចាក់វ៉ាក់សាំងហើយ គាត់អត់មានបញ្ហាទេ គាត់ត្រឡប់ទៅមូលដ្ឋានគាត់ ដោយឡែកអ្នកដែលមិនទាន់ចាក់វ៉ាក់សាំង ហើយយើងធ្វើតេស្តអីទៅ បើគាត់មានវិជ្ជមាន បញ្ជូនទៅមជ្ឈមណ្ឌល ចត្តាឡីស័កព្យាបាល បើគាត់អត់មានទេទៅកន្លែងចត្តាឡីស័កធម្មតា រយៈពេលពីរអាទិត្យ»។ លោក គោស៊ុំ ប៊ុនសឿត អភិបាលរងខេត្តប៉ៃលិន បានឲ្យដឹងទៀតថា ចំពោះមណ្ឌលចត្តាឡីស័ក នៅក្នុងខេត្តប៉ៃលិន នៅសល់តែពីរប៉ុណ្ណោះ ហើយចំពោះអ្នកដែលកំពុងធ្វើចត្តាឡីស័ក គឺសល់ប្រមាណ ២០០នាក់៕ អត្ថបទ៖ យួន សុភ័ក្រ

## អាជ្ញាធរស្រុកសំពៅលូន ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ និងប្រគល់ទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣

https://gdlf-kh.com/ 2022/02/17/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃព្រហស្បតិ៍ ១រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្ដិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្ដិ៍)សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី កៅ-ប៊ុណ្ណា (មេបញ្ជាការរងកងអនុសេនាធំ), កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ផុក-លឹមឃី (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញត្រង់ចំណុចភូមិសាស្ត្រ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០៤នាក់ (ស្រីម្នាក់)។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើការកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣។

## អាជ្ញាធរស្រុកសំពៅលូន បន្តទទួល ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/02/17/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង.នៅថ្ងៃព្រហស្បតិ៍ ១រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹង ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្ដិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុឹង-ម៉េត (នាយប៉ុស្ដិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០២នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្ត បាត់ដំបង ចំនួន១២នាក់ (ស្រី០៥នាក់ ក្មេងប្រុសម្នាក់)។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីត្រួតពិនិត្យសម្ភារៈហាមឃាត់ (ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក)។ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្ដិ៍ ជាលទ្ធផលគឺអវិជ្ជមាន។ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន០៧នាក់ ស្រីម្នាក់ ក្មេងប្រុសម្នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ)។ ចំណែកអ្នកមានប័ណ្ណចាក់

វ៉ាក់សាំងតែស្តែនអត់ចេញ ចំនួន០៥នាក់ ស្រី០២នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## ពលករខ្មែរប្រុស-ស្រី
## និងកូនៗ ១៧៥ នាក់ត្រឡប់មកពីថៃក្នុងនោះ ៤៨ នាក់ បញ្ជូនទៅធ្វើចត្តាឡីស័ក

https://www.postkhmer.com/ គឹម សារុំ | Publication date 17 February 2022 | 10:11 ICT

**បាត់ដំបង:** ពលករខ្មែរប្រុស-ស្រី រួមទាំងក្មេងៗជាកូនពលករចំនួន ១៧៥ នាក់ បានវិលត្រឡប់មកពីប្រទេសថៃវិញ នៅថ្ងៃទី ១៦ ខែកុម្ភៈ តាមច្រកតំបន់អូរអន្លក់ក្នុងឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ក្នុងនោះមនុស្ស ៤៨ នាក់ត្រូវបានបញ្ជូនទៅមណ្ឌលចត្តាឡីស័ក ដោយសារតែពួកគេខ្លះទើបតែចាក់វ៉ាក់សាំងបានម្តង និងមួយចំនួនមិនទាន់បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ។

លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរ ៨១៩ ប្រចាំការនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃក្នុងស្រុកកំរៀង ខេត្តបាត់ដំបងបានឱ្យដឹងថា នៅថ្ងៃទី ១៦ កុម្ភៈ កម្លាំងសមត្ថកិច្ចរបស់លោកបានទទួលពលករប្រុស-ស្រី និងក្មេងៗជាកូនពលករចំនួន ១៧៥ នាក់ (ស្រី ៦៩ នាក់) ក្នុងនោះ មានក្មេងៗចំនួន ២៩ នាក់ (ក្មេងស្រី ១២ នាក់)។ ចំពោះអ្នកដែលត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័កនៅស្រុកសំពៅលូនមានចំនួន ៤៨ នាក់ ( ស្រី ១៨ នាក់បូកក្មេង ៧ នាក់)។ ការបញ្ជូនទៅធ្វើចត្តាឡីស័កនេះ ដោយសារតែពួកគេនៅមិនទាន់បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ ១៩ នៅឡើយ។ លោកបញ្ជាក់ថា៖ «បើតាមខ្ញុំសួរ ពលករប្រាប់ថា ពួកគាត់ត្រឡប់មកស្រុកកំណើតវិញដោយសារពួកគាត់ទៅប្រទេសថៃយូរឆ្នាំដែរ ម្យ៉ាងគាត់អស់ការងារធ្វើ។ ករណីនេះគ្រូពេទ្យ និងសមត្ថកិច្ចខ្ញុំ តែងតែអប់រំដល់ពលករដែលមកវិញឱ្យយល់ដឹងពីជំងឺកូវីដ មុននឹងអនុញ្ញាតឱ្យគាត់ត្រឡប់ទៅលំនៅឋានវិញ»។

លោក ហាត ឡៃឡៃ ស្នងការរងខេត្តបាត់ដំបងទទួលផែនការងារនគរបាលព្រំដែន ឱ្យដឹងនៅថ្ងៃទី ១៦ កុម្ភៈ ថា រយៈពេលដើមខែក្នុងឆ្នាំនេះ ពលករខ្មែរត្រឡប់មកពីប្រទេសថៃមានចំនួនខ្ទង់ពាន់នាក់។ បើតាមរបាយការណ៍ពីកម្លាំងនគរបាលប៉ុស្តិ៍ច្រកអូរអន្លក់ក្នុងឃុំតាសែន ស្រុកកំរៀង និងនៅច្រកពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ពលករទាំងនោះភាគច្រើនបានចាក់វ៉ាក់សាំងការពារជំងឺកូវីដរួចរាល់ហើយ។ មូលហេតុដែលពួកគេត្រឡប់មកពីប្រទេសថៃវិញនេះ ដោយពួកគេលើកឡើងថា នៅតំបន់ដែលពួកគេរស់នៅនោះអស់ការងារធ្វើ ហើយម្យ៉ាងទៀតពួកគេចង់មកលេងស្រុកកំណើតផង។ បើតាមលោកស្នងការរងពលករទៅប្រទេសថៃភាគច្រើនស៊ីឈ្នួលធ្វើចម្ការ ឬបេះផ្លែឈើឱ្យគេ។ ពាក់ព័ន្ធនឹងចំនួនពលករដែលវិលត្រឡប់មកពីប្រទេសថៃប្រចាំខែវិញ គឺលោកមិនបានសរុបរបាយការណ៍ពីចំនួនតួលេខនេះទេ។ លោកថ្លែងថា៖ «ពលករឥឡូវក៏អត់ការងារធ្វើដែរ វាមានអ្នកដែលទើបនឹងទៅថ្មី និងអ្នកទៅយូរឆ្នាំ។ បើអ្នកដែលអត់បានចាក់វ៉ាក់សាំងទេ យើងនឹងយកគាត់ទៅធ្វើចត្តាឡីស័ក។ តែបើអ្នកដែលបានចាក់វ៉ាក់សាំងហើយ បើធ្វើតេស្តទៅមិនឃើញមានកូវីដទេ យើងឱ្យគាត់ទៅផ្ទះបាន»។

ទោះយ៉ាងណា លោកស្រី រស់ ជីវី ស្នងការរងទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ខេត្តបាត់ដំបងប្រាប់នៅថ្ងៃទី ១៦ ខែកុម្ភៈ ថា លោកស្រីពុំមានចំនួនពិតប្រាកដទេ ចំពោះពលករដែលត្រឡប់មកពីប្រទេសថៃ។ ប៉ុន្តែបើគិតពីដើមខែមករា ឆ្នាំ ២០២២ ដល់ពេលនេះ គឺពលករមានចំនួនក្បែរពាន់នាក់ហើយ។ លោកស្រីបានថ្លែងថា៖ «ពលករទាំងនោះភាគច្រើនចាក់វ៉ាក់សាំងរួចហើយ។ តែចំពោះសកម្មភាពមេខ្យល់លួចនាំពលករ ឆ្លងដែនទៅប្រទេសថៃវិញ គឺពុំឃើញមានទេ»៕

# ថ្ងៃទី២១ ខែ កុម្ភៈ ឆ្នាំ២០២២

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរលួចឆ្លងដែនខុសច្បាប់ ១៦៦នាក់ មកកម្ពុជាវិញ

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១៨ កុម្ភៈ ២០២២ដោយ Sophal Tuon

ខេត្តបាត់ដំបង៖ អាជ្ញាធរថៃ បានចាប់បញ្ជូនពលករខ្មែរប្រមាណ ១៦៦ នាក់ មកកម្ពុជាវិញ ក្រោយពួកគេលួចឆ្លងដែនខុសច្បាប់ ទៅរកការងារធ្វើនៅប្រទេសថៃ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ ។

លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យ ទៅទទួលពលករវិលត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ។ លោកក៏បានបញ្ជាក់ថា ពលករខ្មែរទាំងអស់មានចំនួន ១៦៦ នាក់ ត្រូវបានក្រុមគ្រូពេទ្យធ្វើតេស្តរហ័ស រកមេរោគកូវីដ-១៩ ជាលទ្ធផលអវិជ្ជមាន ទាំងអស់។ លោកវរសេនីយ៍ឯក ម៉ង់ ស៊ី ថា នៅក្នុងចំណោមពលករទាំងនេះ មានពលករចំនួន ៦៦នាក់ ក្នុងនោះ ស្រី៣៥នាក់ ក្មេង៩នាក់ គ្មានកាតចាក់វ៉ាក់សាំងបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន ខេត្តបាតដំបង។ ចំណែកពលករ ដែលមានកាតចាក់វ៉ាក់សាំងចំនួន១០០នាក់ ក្នុងនោះស្រី២០នាក់ និងក្មេង២៣នាក់ ត្រូវបានក្រុមគ្រូពេទ្យអនុញ្ញាតឲ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ៕ អត្ថបទ ៖ សោ និយមវ័ត្ន

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរមួយថ្ងៃៗ រាប់រយនាក់ត្រឡប់មកស្រុកវិញដោយសារឆ្លងដែនខុសច្បាប់

https://kohsantepheapdaily.com.kh/ បាត់ដំបង១៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ម៉ោង ១៤:១០

ខេត្តបាត់ដំបង ៖ ប៉ុន្មានខែចុងក្រោយនេះ និងស្របពេលជំងឺកូវីដ-១៩ កំពុងរាតត្បាតនូវមេរោគបំប្លែងថ្មី « អូមេក្រុង» គេសង្កេតឃើញពលករខ្មែរប្រុស-ស្រី មានចាស់មានក្មេងរាប់រយនាក់ក្នុងមួយថ្ងៃៗ ត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់មកកាន់ប្រទេសកំណើតវិញជាបន្តបន្ទាប់ តាមច្រកទ្វារតំបន់«អូរអន្លក់» ដែលភាគីថៃហៅច្រក « សួនស៊ុំ» ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ដែលអាជ្ញាធរថៃ អះអាងថា ជាពលករឆ្លងដែនខុសច្បាប់គ្មានលិខិតឆ្លងដែន។ ជាក់ស្តែង បើយោងរបាយការណ៍កងកម្លាំងការពារព្រំដែនខ្មែរ គឺ នៅព្រឹកថ្ងៃទី១៨ កុម្ភៈ មានពលករខ្មែរប្រុស ស្រី ជាង១៦០នាក់ ត្រូវបានអាជ្ញាធរថៃ ដឹកតាមរថយន្តបញ្ជូនមកកាន់ព្រំដែន ហើយបានបញ្ជូនត្រឡប់មកប្រទេសកំណើតវិញ តាមច្រកតំបន់«អូរអន្លក់» ឬច្រក«សួនស៊ុំ» ស្ថិតក្នុងស្រុកកំរៀង។ ពលករខ្មែរទាំងនេះ ត្រូវបានអាជ្ញាធរថៃរកឃើញថា បានឆ្លងដែនចូលទៅប្រទេសថៃ ដោយគ្មានច្បាប់(គ្មានលិខិតឆ្លងដែន) ។ កម្លាំងនគរបាលការពារព្រំដែនគោក ក្នុងអង្គភាពវរសេនាតូចលេខ៨១៩ បានសហការជាមួយកម្លាំងយោធាការពារព្រំដែន ប្រចាំច្រកទ្វារតំបន់មួយនេះ បានទទួលពលករខ្មែរទាំងនោះពីភាគីថៃ ជាមួយនឹងការអនុវត្តយ៉ាងប្រុងប្រយ័ត្ននូវវិធានការ ការពារការឆ្លងរាលដាលនូវជំងឺកូវីដ១៩ ។

បើតាមរបាយការណ៍មន្ត្រីការពារព្រំដែនពលករខ្មែរដែលភាគីថា ចាប់បញ្ជូនត្រឡប់មកស្រុកកំណើតវិញនៅព្រឹកថ្ងៃទី ១៨ កុម្ភៈ នេះ មានចំនួនសរុប១៦៦នាក់ ក្នុងនោះ មានស្ត្រីចំនួន៥៥នាក់ ហើយក្នុងចំណោមនេះមានក្មេងប្រុស ស្រីចំនួន៣២នាក់។ មន្ត្រីព្រំដែនបាននិយាយថា ក្រុមពលករទាំងនោះត្រូវបានអប់រំ និងណែនាំយ៉ាងជាក់លាក់អំពីវិធានការទប់ស្កាត់ និងការឆ្លងរាលដាលនូវជំងឺកូវីដ១៩ បម្លែងថ្មី «អូមេក្រុង» ដែលកំពុងមានសន្ទុះកាន់ខ្លាំង ។ ក្រោយពីសាកសួរ ក្រុមគ្រូពេទ្យក៏បានធ្វើតេស្តរហ័សរកមេរោគកាចសាហាវនេះ តែអវិជ្ជមានទាំងអស់។ ប៉ុន្តែយ៉ាងណា គ្រូពេទ្យបានកំណត់យកពលករប្រុស ស្រី ក្មេងចាស់ចំនួន៦៦នាក់ ដែលគ្មានប័ណ្ណចាក់វ៉ាក់សាំង ដើម្បី

បញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័កនៅស្រុកសំពៅលូន។ ដោយឡែក ពលករចំនួន១០០នាក់ទៀត ដែលមានកាន់ប័ណ្ណចាក់វ៉ាក់សាំង ត្រូវបានអនុញ្ញាតឲ្យវិលត្រឡប់ទៅកាន់លំនៅឋានរៀងៗខ្លួន។ សូមរំលឹកថា ប៉ុន្មានខែចុងក្រោយនេះ អាជ្ញាធរថៃបានចាប់បញ្ជូនពលករខ្មែរប្រុស ស្រី ក្មេងចាស់ រាប់រយនាក់ក្នុងមួយថ្ងៃៗ ឲ្យត្រឡប់មកកាន់ប្រទេសកំណើតវិញ ស្របពេលដែលការឆ្លងរាលដាលនៃជំងឺកូវីដ១៩ មិនទាន់មានសញ្ញាថមថយ។ ជាពិសេស សន្ទុះនៃការឆ្លងរាលដាលនូវមេរោគបម្លែងថ្មី «អូមេក្រុង» ដែលកំពុងផ្ទុះខ្លាំងនៅរាជធានីភ្នំពេញ និង តិចទូចនៅតាមបណ្ដាខេត្តមួយចំនួន នៃព្រះរាជណាចក្រកម្ពុជា។

មានការកត់សម្គាល់ផងដែរ ចំពោះពលករខ្មែរ ប្រុសស្រី ក្មេងចាស់ បើទោះជាត្រូវអាជ្ញាធរថៃ ចាប់បញ្ជូនមួយថ្ងៃៗ រាប់រយនាក់ឲ្យត្រឡប់មកប្រទេសកំណើតវិញ ក៏ពិតមែន ដោយចោទប្រកាន់ថា «គ្មានលិខិតឆ្លង»។ ប៉ុន្តែពលរដ្ឋខ្មែរនៅតែបន្តធ្វើចំណាកស្រុក ដោយលួចលាក់ឆ្លងដែនយ៉ាងត្រដាបត្រដួសទៅស្វែងរកការងារធ្វើនៅប្រទេសថៃ តាមរយៈការអូសទាញក្រោមរូបភាពបោកប្រាសរបស់ពួកមេខ្យល់ទុច្ចរិត ដែលគេសង្ស័យថា អាចមានការចូលរួមបើកផ្លូវងងិតឲ្យលួចឆ្លងដែន ពីមន្ត្រីការពារព្រំដែនខ្មែរមួយចំនួនផង ជាថ្នូរនឹងសំណូកសូកប៉ាន់។ ដូច្នេះហើយ ទើបអាជ្ញាធរថៃចាប់ពលករខ្មែរខុសច្បាប់ត្រឡប់មកស្រុកកំណើតវិញមិនចេះអស់។ ប៉ុន្តែយ៉ាងណា សមត្ថកិច្ចព្រំដែនក៏បានទប់ស្កាត់ និង បង្ក្រាបបានពួកមេខ្យល់នាំពលករឆ្លងដែនខុសច្បាប់ បានជាបន្តបន្ទាប់ផងដែរ បើទោះជាមានការចន្លោះប្រហោងភាគច្រើនក្តី៕

## មន្ត្រីយុត្តិធម៌កម្ពុជា-ថៃ ពិភាក្សាលើកិច្ចសហប្រតិបត្តិការរឿងព្រហ្មទណ្ឌ

https://m.postkhmer.com/ 18 February 2022 | 11:06 ICT

**ភ្នំពេញៈ** មន្ត្រីយុត្តិធម៌កម្ពុជា-ថៃ បានជួបពិភាក្សាគ្នានៅរាជធានី-ភ្នំពេញ កាលពីថ្ងៃទី ១៦ ខែកុម្ភៈ លើកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ានលើវិស័យព្រហ្មទណ្ឌ និងការប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែន ដើម្បីជាប្រយោជន៍រួមក្នុងតំបន់ ក្នុងការកាត់បន្ថយបទល្មើសនានា។ ក្នុងជំនួបនោះ ដឹកនាំដោយរដ្ឋលេខាធិការ និងជាប្រធានឧត្តមមន្ត្រីច្បាប់ និងយុត្តិធម៌អាស៊ាននៃក្រសួងយុត្តិធម៌ លោក ជិន ម៉ាលីន និងលោក Vongthep Arthakaivalvatee អតីតអគ្គលេខាធិការរងអាស៊ាន និងបច្ចុប្បន្នជាទីប្រឹក្សាពិសេសនៃវិទ្យាស្ថានយុត្តិធម៌ប្រទេសថៃ (TIJ)។ កិច្ចពិភាក្សានេះបានផ្តោតលើរបៀបវារៈចំនួន ៣ រួមមាន ១ កិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ានលើវិស័យយុត្តិធម៌ព្រហ្មទណ្ឌ និងការប្រយុទ្ធប្រឆាំងទប់ស្កាត់ និងបង្ក្រាបបទល្មើស និងការរៀបចំសន្និសីទអាស៊ានលើកទី ៣ ស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្មក្នុងតំបន់នៅភូកេត ប្រទេសថៃនាពាក់កណ្តាលខែមីនា ឆ្នាំ ២០២២ ខាងមុខនេះ។ ២ ភាគីថៃមានសំណើសុំការគាំទ្រពីកម្ពុជាលើការរៀបចំសេចក្តីប្រកាសរួមអាស៊ានស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្ម និងកិច្ចសហប្រតិបត្តិការក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌក្នុងតំបន់អាស៊ាន ដែលស្នើឡើងដោយប្រទេសថៃ។ របៀបវារៈទី ៣ សំណើសុំការគាំទ្រពីកម្ពុជាលើការរៀបចំយន្តការតំបន់អាស៊ានក្នុងការគ្រប់គ្រងស្ត្រី និងជនងាយរងគ្រោះផ្សេងទៀតក្នុងពន្ធនាគារ ដែលស្នើឡើងដោយប្រទេសថៃ។

ប្រធានឧត្តមមន្ត្រីច្បាប់ និងយុត្តិធម៌អាស៊ាននៃក្រសួងយុត្តិធម៌ លោក ជិន ម៉ាលីន បានប្រាប់ភ្នំពេញប៉ុស្តិ៍ថា គោលបំណងនៃជំនួបនេះ ខាងភាគីថៃចង់បង្ហាញពីសារៈសំខាន់នៃកិច្ចសហការនោះ និងបានសុំការគាំទ្រពីកម្ពុជាក្នុងនាមជាប្រធានអាស៊ានក្នុងឆ្នាំនេះ។ លោកថា៖ «ឥឡូវនេះខាងភាគីថៃគេចង់ស្នើរៀបចំជាសេចក្តីប្រកាសរួមមួយពាក់ព័ន្ធការទប់ស្កាត់បទល្មើស និងកិច្ចសហប្រតិបត្តិការក្នុងវិស័យព្រហ្មទណ្ឌ អ៊ីចឹងខាងភាគីថៃគេដើរជួបគ្រប់ប្រទេសទាំងអស់ ដើម្បីស្នើសុំឱ្យមានការគាំទ្រទៅលើសេចក្តីប្រកាសរួមដែលខាងភាគីថៃជាអ្នកស្នើ និងផ្តួចផ្តើមឡើង»។ លោកបន្តថា ការផ្តួចផ្តើមឱ្យមានការប្រកាសរួមនីមួយៗ វាត្រូវឆ្លងកាត់ច្រើនដំណាក់កាល ដែលមាន

ក្រុមការងារត្រូវជជែកគ្នា បន្ទាប់មកមានកិច្ចប្រជុំរដ្ឋមន្ត្រីច្បាប់អាស៊ាន ហើយត្រូវឆ្លងកិច្ចប្រជុំរដ្ឋមន្ត្រីច្បាប់ និងយុត្តិធម៌អាស៊ានបន្តទៀត។ លោកថា៖ «មុននឹងចេញ គេរៀបចំសិក្ខាសាលារួមមួយនៅខែមីនាខាងមុខនេះដើម្បីពិនិត្យមើលលើឯកសារទាំងអស់នេះពីសារៈសំខាន់ក្នុងការរៀបចំយន្តការទាំងអស់នេះ បន្ទាប់ពីដាក់ឆ្លងច្រើនដំណាក់កាលទៀត»។

លោកក៏បានរៀបរាប់ពីសិទ្ធិនៅក្នុងក្របខ័ណ្ឌអាស៊ានថា ជាទូទៅប្រទេសនីមួយៗមានសិទ្ធិស្នើ ឬលើកគម្រោងដែលជាប្រយោជន៍សម្រាប់ក្នុងតំបន់ ហើយប្រទេសនោះជាអ្នកដឹកនាំធ្វើការលើរឿងនេះ។ ទៀតសោត ការស្នើនោះត្រូវមានការឯកភាពពីប្រទេសនីមួយៗ ព្រោះប្រទេសខ្លះគេយល់ព្រម ខណៈប្រទេសខ្លះគេបដិសេធ។ យ៉ាងណាមិញលោកបានគូសបញ្ជាក់ថា ទោះបីឯកសារនោះផ្តួចផ្តើមដោយភាគីថៃក្តី ប៉ុន្តែប្រទេសក្នុងអាស៊ានត្រូវអនុវត្តរួមគ្នា ដោយសារមុននឹងចេញប្រកាសរួមនេះ គឺមានការឯកភាពពីសមាជិកក្នុងតំបន់រួចទៅហើយ។ លោក ជិន ម៉ាលីន ថា ក្នុងកិច្ចការសហការលើវិស័យយុត្តិធម៌ព្រហ្មទណ្ឌនេះ មានយន្តការច្រើនដែលត្រូវអនុវត្តរួមគ្នា រួមមានការទប់ស្កាត់បទល្មើស ការអប់រំ ការផ្សព្វផ្សាយ ហើយមានការផ្លាស់ប្តូរទណ្ឌិតគ្នាទៅវិញទៅមក មានជំនួយផ្នែកច្បាប់ និងបត្យាប័នជាដើម។ លោក ជិន ម៉ាលីន បានគូសបញ្ជាក់ផងដែរថា សារៈសំខាន់នៃកិច្ចសហប្រតិបត្តិការនេះនឹងរួមចំណែកកាត់បន្ថយបទល្មើសក្នុងប្រទេស និងតំបន់។

លោកថា៖ «ព្រោះបញ្ហាឧក្រិដ្ឋកម្មមិនមែនជាបញ្ហារបស់ប្រទេសមួយទេ គឺជាបញ្ហាតំបន់ទាំងមូល ហើយធម្មតាមានឧក្រិដ្ឋមួយកើតឡើងនៅប្រទេសយើង ហើយរត់គេចខ្លួនទៅបណ្តាប្រទេសដទៃទៀតបាន ដូចជាការលើកទឹកចិត្តឱ្យជនល្មើស កាន់តែប្រព្រឹត្តបទល្មើសដោយសារមានកន្លែងរត់គេច។ អ៊ីចឹងបើសិនជាប្រទេសទាំងអស់នេះសហការគ្នា មានន័យថា ជនល្មើសមិនអាចរត់គេចខ្លួនបាន ហើយមានយន្តការទប់ស្កាត់ អ៊ីចឹងគឺកាត់បន្ថយឧក្រិដ្ឋកម្មបទល្មើសក្នុងប្រទេសផង និងកាត់បន្ថយក្នុងតំបន់ផង ជួនកាលបទល្មើសមានលក្ខណៈឆ្លងដែន ព្រោះករណីខ្លះមិនមែនកើតមាននៅប្រទេសយើងទេ ប៉ះពាល់ប្រទេសយើងទេ ប៉ុន្តែវាប៉ះពាល់ដល់ឆ្លងដែន ដូចការចរាចរឆ្លងដែនជួញដូរមនុស្សពេលឆ្លងកាត់ប្រទេសណាប៉ះពាល់ប្រទេសនោះហើយ អ៊ីចឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់វាសំខាន់»។ លោកថា កិច្ចសហប្រតិបត្តិការនេះនៅមានការជជែកពិភាក្សាបន្តទៀតទៅថ្ងៃមុខ ព្រោះកម្ពុជាក៏ត្រូវពិនិត្យឯកសារ ឬស្នើឱ្យមានការកែប្រែខ្លឹមសារផងដែរ ក្នុងករណីចាំបាច់។ លោកថា៖ «ព្រោះយើងនៅសិក្សាលម្អិតទៀត ព្រោះនេះជាគំនិតផ្តួចផ្តើមរបស់គាត់ ប៉ុន្តែគឺយើងនឹងមានក្រុមការងារដើម្បីសិក្សាលម្អិតទៅលើឯកសារ និងយន្តការដែលគាត់ស្នើមក ហើយនឹងជជែកគ្នាថាមានការកែប្រែយ៉ាងម៉េចដើម្បីបម្រើប្រយោជន៍តំបន់ អ៊ីចឹងសួរថាគាំទ្រ ឬមិនគាំទ្រ មិនទាន់អាចឆ្លើយបានទេ»៕

## គួរឱ្យសង្វេគ! ពលករបរទេសនៅហុងកុង ត្រូវបានគេ«បោះបង់ចោល» និងដេកក្រៅផ្ទះ ខណៈពេលទីក្រុងនេះកំពុងផ្ទុះកូវីដខ្លាំង

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២

(ហុងកុង)៖ អង្គការសប្បុរសធម៌នានាបានព្រមានថា ពលករបរទេស ក្នុងទីក្រុងហុងកុងកំពុងត្រូវបាន « បោះបង់ចោល» នៅក្នុងរលកនៃមេរោគកូវីដ-១៩ ដែលកំពុងវាយលុកទីក្រុងនេះ ដោយអ្នកខ្លះ ត្រូវបង្ខំចិត្តដេកតាមផ្លូវ ឬត្រូវបានបដិសេធមិនព្យាបាលឱ្យ បន្ទាប់ពីបានធ្វើតេស្តវិជ្ជមាន។ នេះបើយោង តាមការចុះផ្សាយរបស់ សារព័ត៌មានCNA នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២។ មជ្ឈមណ្ឌលហិរញ្ញវត្ថុចិនមួយនេះ បច្ចុប្បន្នកំពុងស្ថិតក្នុងការគំរាមកំហែងនៃការផ្ទុះឡើងកូវីដ ដ៏អាក្រក់បំផុតដែលមិនធ្លាប់មានរបស់ខ្លួន ដោយមានករណីឆ្លងរាប់ពាន់នាក់ក្នុងមួយថ្ងៃ នៅពេលដែល មន្ទីរពេទ្យឈានអស់សមត្ថភាពទទួលព្យាបាលអ្នកជំងឺ។ ប្រជាជនហុងកុងរស់នៅក្នុងទីក្រុងមួយក្នុងចំនោមទីក្រុងដែលសម្បូរទៅដោយប្រជាជនច្រើន បំផុតលើ ពិភពលោក ហើយពឹងផ្អែកលើពលករបរទេស

ប្រមាណ ៣៧០,០០០នាក់ ដែលជាស្ត្រីភាគច្រើន មកពីប្រទេសហ្វីលីពីន និងឥណ្ឌូនេស៊ី ដែលធ្វើម្ហូប សម្អាត និងមើលថែទាំគ្រួសាររបស់ពួកគេ។ ពលករខ្លះត្រូវថៅកែបណ្តេញចេញពីផ្ទះ បន្ទាប់ពីធ្វើតេស្តវិជ្ជមាន ដោយបង្ខំឱ្យពួកគេដេកនៅខាងក្រៅ។ អ្នកផ្សេងទៀតបានប្រាប់ថា ពួកគេត្រូវបានគេបដិសេធមិនព្យាបាលឱ្យនៅមន្ទីរពេទ្យ ដោយសារពួកគេបានបាត់បង់ការងារ៕ អត្ថបទ៖ សាន លីម៉ា

## ជនជាតិចិនត្រូវបានក្រើនរំលឹក ពីការបោកបញ្ឆោត អោយទៅធ្វើការខារនៅបរទេស

https://www.khmertimeskh.com/ Khmer Times February 18, 2022

ស្ថានទូតចិនប្រចាំនៅកម្ពុជា បានក្រើនរំលឹកជនជាតិចិនកុំអោយចាញ់បោកក្រុមហ៊ុនលេងល្បែងតាមអ៊ីនធឺណិត ដែលជ្រើសរើសបុគ្គលិកដោយសន្យាផ្តល់ប្រាក់ខែខ្ពស់ បន្ទាប់ពីក្រុមឧក្រិដ្ឋជនបានសម្លាប់ជនជាតិចិនម្តងហើយម្តងទៀតនៅក្នុងក្រុងទេសចរណ៍ខេត្តព្រះសីហនុ។ កាលពីថ្ងៃទី១២ ខែកុម្ភៈ មន្ទីរពេទ្យ Bethune Cambodia China First Hospital រាជធានីភ្នំពេញ បានរាយការណ៍ទៅស្ថានទូតថា បុរសជនជាតិចិនម្នាក់ឈ្មោះ Li ត្រូវបានបញ្ជូលព្យាបាលនៅមន្ទីរពេទ្យក្នុងស្ថានភាពធ្ងន់ធ្ងរ ដោយសារឈាមបានចេញយ៉ាងច្រើន នេះបើយោងតាមសេចក្តីថ្លែងការណ៍របស់ស្ថានទូត។ ស្ថានទូតបាននិយាយថា បុរសនេះ "ត្រូវបានល្បួងតាមរយៈការប្រកាសរកការងារក្លែងក្លាយ" ហើយត្រូវបានបង្ខិតបង្ខំដោយឧក្រិដ្ឋជនឱ្យរត់ពន្ធចូលមកកម្ពុជា។

សេចក្តីថ្លែងការណ៍បាននិយាយថា ក្រោយមកគាត់ត្រូវបានបង្ខាំងខ្លួនដោយខុសច្បាប់ ដោយក្រុមជនពាលដែលពាក់ព័ន្ធនឹងល្បែងស៊ីសងអនឡាញ និងការឆបោកតាមអ៊ីនធើណែត នៅតំបន់ Chinatown ខេត្តព្រះសីហនុ ហើយបានបង្ហូរឈាមរបស់គាត់ជាច្រើនដងរហូតដល់គាត់ស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ។ ស្ថានទូតបានរាយការណ៍ដល់នគរបាល ដែលកំពុងធ្វើការស៊ើបអង្កេត។ ស្ថានទូតបានជំរុញពលរដ្ឋចិន ដែលមានគម្រោងមកធ្វើការនៅកម្ពុជាឱ្យប្រើប្រាស់វេទិកាស្វែងរកការងារដែលមានកេរ្តិ៍ឈ្មោះ និងចៀសវាងអន្ទាក់ នៃការបោកបញ្ឆោតដោយការផ្សព្វផ្សាយការងារមិនពិតជាមួយនឹងការផ្តល់ប្រាក់ឈ្នួលខ្ពស់។ ក្នុងករណីដែលប្រជាពលរដ្ឋរងគ្រោះ ដោយការក្លែងបន្លំ ការចាប់ជំរិត ឬការរឹតត្បិតលើសេរីភាពផ្ទាល់ខ្លួន ស្ថានទូតបានណែនាំថា ពួកគេគួរតែព្យាយាមរាយការណ៍ពីបទល្មើសនេះមកនគរបាលកម្ពុជាឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក៏ដូចជាទៅកាន់ស្ថានទូតផងដែរ ដូច្នេះការស៊ើបអង្កេតអាចដំណើរការបាន។

កាលពីខែមេសាឆ្នាំមុន ស្ថានទូតចិនប្រចាំនៅកម្ពុជា បានបង្ហាញពីការព្រួយបារម្ភអំពីការជួញដូរទាក់ទងនឹងល្បែងស៊ីសងអនឡាញ ហើយបាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយថា ពលរដ្ឋចិនពីរនាក់ត្រូវបានជួយសង្គ្រោះដោយនគរបាលមូលដ្ឋាន បន្ទាប់ពីត្រូវបានបង្ខាំងខ្លួនដោយខុសច្បាប់ ដោយជនពាលល្បែងអនឡាញ នៅក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ ស្ថានទូតបានព្រមានពលរដ្ឋចិនពីការធ្លាក់ចូលទៅក្នុង "អន្ទាក់ប្រាក់ខែខ្ពស់" ទាក់ទងនឹងការផ្តល់ជូនគួរឱ្យសង្ស័យ ហើយបានប្រាប់ក្រុមឧក្រិដ្ឋជនឱ្យ "ថយក្រោយ" បើមិនដូច្នោះទេ នឹងប្រឈមមុខនឹងការផ្តន្ទាទោសតាមច្បាប់៕ សារព័ត៌មាន China Daily

# ថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ២០២២

## ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីៈ ស្ត្រី ត្រូវបានយកចិត្តទុកដាក់ខ្ពស់ ពីថ្នាក់ដឹកនាំគ្រប់ស្ថាប័ន លើការអភិវឌ្ឍសមត្ថភាព ជាថ្នាក់ដឹកនាំ និងជាមន្ត្រីរាជការ

https://dap-news.com/national/ ByDR103Posted on February 21, 2022

**ភ្នំពេញៈ ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២២ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាពសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ ត្រូវបានលោកស្រី ជូ ប៊ុនអេង តំណាង លោកស្រី អ៊ឹង កន្ថាផាវី ជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី លើកឡើងថា ការអភិវឌ្ឍសមត្ថភាពស្ត្រីជាថ្នាក់ដឹកនាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការអភិវឌ្ឍសមត្ថភាព ដល់ស្ត្រីជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការជានារីនៅថ្នាក់ជាតិ ត្រូវបានយកចិត្តទុកដាក់ខ្ពស់ ដោយថ្នាក់ដឹកនាំស្ថាប័ន ។**

កិច្ចប្រជុំខាងលើនេះដែរ ត្រូវបានសម្តេចតេជោ វាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែង របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលបានរួមចំណែកយ៉ាងសកម្ម ក្នុងការកសាង និងអភិវឌ្ឍសង្គមជាតិ។ សម្តេចតេជោ បានបន្តថា បច្ចុប្បន្ន ស្ត្រីបានចូលរួមចំណែក ក្នុងកិច្ចការងារជាច្រើនវិស័យ។

លោកស្រី ជូ ប៊ុនអេង បានថ្លែងថា "ការអភិវឌ្ឍសមត្ថភាពស្ត្រី ជាថ្នាក់ដឹកនាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការអភិវឌ្ឍសមត្ថភាព ដល់ស្ត្រីជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការជានារី នៅថ្នាក់ជាតិ ត្រូវបានយកចិត្តទុកដាក់ខ្ពស់ ដោយថ្នាក់ដឹកនាំស្ថាប័ន ។ ពីឆ្នាំ២០២០-២០២១ ស្ត្រីចំនួន២២៣៥ នាក់ នៃចំនួនអ្នកចូលរួមសរុប ៣៨៧១ នាក់ បានចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងជំនាញនានាទាំងក្នុងប្រទេស និងក្រៅប្រទេស"។ លោកស្រីបន្តថា នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងកិច្ចការនារី បានរៀបចំកម្មវិធីអភិវឌ្ឍន៍ សមត្ថភាពមន្ត្រីកិច្ចការនារី ក្នុងការអនុវត្តការងារ ការស្វែងរកការគាំទ្រមតិ ការបញ្ជ្រាបយេនឌ័រ និងបរិយាបន្ន សីលធម៌សង្គម និងភាពជាអ្នកដឹកនាំ និងដាក់បញ្ចូល ទៅក្នុងកម្មវិធីវិនិយោគ ឃុំ សង្កាត់ និងសមាហរណកម្មផែនការឃុំ សង្កាត់ ថ្នាក់ ក្រុង ស្រុក ខណ្ឌ។ ក្រសួងបានបើកវគ្គតាមប្រព័ន្ធអនឡាញ ដើម្បីពង្រឹងតួនាទីស្ត្រី ក្នុងភាពជាអ្នកដឹកនាំ និងភារកិច្ចរបស់គណៈកម្មាធិការ ពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ អ្នកចូលរួម ១,១២៣ នាក់(ស្ត្រី៨៤០នាក់)»។ លោកស្រីបន្តទៀតថា របាយការណ៍លទ្ធផលការងារ ឆ្នាំ២០២០-២០២១ បង្ហាញពីវឌ្ឍនភាពការប្រឈមថ្មីៗ និងចំណុចសេសសល់ទាំងឡាយ ដែលយើងទាំងអស់គ្នាចាំបាច់ ត្រូវខិតខំបន្តការដោះស្រាយ ក្នុងបរិការណ៍នៃជំងឺកូវីដ១៩ ដើម្បីស្តារ និងជំរុញការអភិវឌ្ឍគ្រប់វិស័យ តាមរយៈការបន្តអនុវត្តវិធានការ ផ្នែកគោលនយោបាយ កម្មវិធីនិងសកម្មភាពជាក់លាក់នានា ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ដើម្បីការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និងចីរភាព។

គួបញ្ជាក់ថា ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី មានព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ជាព្រះប្រធានកិត្តិយស និងមានសម្តេចតេជោ ជាអនុប្រធានកិត្តិយស។ ចាប់តាំងពីឆ្នាំ២០០៦មក ថ្នាក់ដឹកនាំនៃ ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី តែងតែបើកកិច្ចប្រជុំជាទៀងទាត់ រៀងរាល់មួយឆ្នាំម្តង ក្រោមអធិបតីភាពសម្តេចតេជោ ហ៊ុន សែន។ កិច្ចប្រជុំធ្វើឡើងដើម្បីតាមដាន និងត្រួតពិនិត្យរាល់សកម្មភាពការងារ និងការអនុវត្តរាល់អនុសាសន៍ លើការងារមួយចំនួនរបស់ «ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី» ក្នុងការចូលរួមចំណែក ជាមួយរាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់សិទ្ធិសេរីភាព ឋានៈ តួនាទី ពិសេសការចូលរួមដោះស្រាយ រាល់ការងារជាអាទិភាពនានារបស់ស្ត្រី៕

# ពលករចំណាកស្រុកខ្មែរបានទៅដល់ខេត្តក្នុងប្រទេសថៃ
# ចំនួនបួន គឺស៊ីសាកេត សុរិន្ទ ស្រះកែវ និងត្រាត ដើម្បីដោះស្រាយកង្វះកម្លាំងពលកម្ម

https://www.khmertimeskh.com/ Khmer Times February 21, 2022

រដ្ឋាភិបាលថៃនឹងនាំយកពលករចំណាកស្រុកខ្មែរ និងមីយ៉ាន់ម៉ា ទៅកាន់ខេត្តចំនួនប្រាំបី របស់ប្រទេសថៃ ក្រោមកិច្ចព្រមព្រៀង ដើម្បីដោះស្រាយការជួញដូរខុសច្បាប់ និងកង្វះកម្លាំងពលកម្មប្រមាណចំនួន ៨០០,០០០ នាក់។ ទំព័រហ្វេសប៊ុក Thai Khu Fah ដែលគ្រប់គ្រងដោយរដ្ឋាភិបាលបាននិយាយកាលពីថ្ងៃអាទិត្យថា ចំណាត់ការនេះត្រូវបានធ្វើឡើងក្រោមវិធានការដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ទំព័រនេះបានបន្តថា៖ « គោលការណ៍ណែនាំនឹងស្រដៀងគ្នានឹងគោលការណ៍ ដែលអនុញ្ញាតឲ្យកម្មករកម្ពុជាធ្វើការនៅខេត្តចាន់ថាបុរី។ ក្រសួងការងារកំពុងពន្លឿនគោលការណ៍ណែនាំ ដើម្បីនាំពលករចំណាកស្រុកខ្មែរទៅកាន់ខេត្តស៊ីសាកេត សុរិន្ទ ស្រះកែវ និងត្រាត ព្រមទាំងបញ្ជូនពលករមីយ៉ាន់ម៉ាឆ្លងព្រំដែនទៅកាន់ខេត្តឈៀងរ៉ៃ តាក កានចាន់បុរី និងរ៉ាណុង។

កន្លែងធ្វើចត្តាឡីស័កសរុបចំនួន ១៧ អាចផ្ទុកពលករចំណាកស្រុកចំនួន ១,៣៦៨ នាក់ ដោយកន្លែងធ្វើចត្តាឡីស័កចំនួន ១១ នៅខេត្តស៊ីសាកេត សុរិន្ទ ស្រះកែវ និងត្រាត ដែលអាចដាក់ពលករចំនួន ១,០៣៨ នាក់ និងកន្លែងធ្វើចត្តាឡីស័កចំនួន៦ទៀត នៅឈៀងរ៉ៃ តាក កានចាន់បុរី និងរ៉ាណុងសម្រាប់ពលករចំនួន ៣៣០នាក់ ។ ប៉ុស្តិ៍ត្រួតពិនិត្យជំងឺនឹងពិនិត្យលទ្ធផលតេស្តកូវីដ-១៩ និងវិញ្ញាបនបត្រចាក់វ៉ាក់សាំងរបស់ពលករចំណាកស្រុកដែលត្រូវប្រគល់វិញ្ញាបនបត្រចូល បូករួមទាំងការធានារ៉ាប់រងសុខភាពរយៈពេលបីខែ។ ប៉ុស្តិ៍ត្រួតពិនិត្យអន្តោប្រវេសន៍នឹងពិនិត្យលិខិតឆ្លងដែន និងឯកសារផ្សេងទៀតដែលអនុញ្ញាតឱ្យជនអន្តោប្រវេសន៍ស្នាក់នៅក្នុងប្រទេសថៃរយៈពេល ៣០ ថ្ងៃ។ បន្ទាប់មក ពលករចំណាកស្រុកដែលបានចាក់វ៉ាក់សាំងត្រូវធ្វើចត្តាឡីស័កចំនួន៧ថ្ងៃ និងធ្វើតេស្ត PCR ចំនួនពីរលើក។ និយោជកនឹងទទួលខុសត្រូវលើការចំណាយលើការព្យាបាល ប្រសិនបើកម្មករណាម្នាក់មានតេស្តវិជ្ជមានកូវីដ-១៩។ ពលករចំណាកស្រុកនឹងត្រូវចេញប័ណ្ណការងារអនុញ្ញាតអោយធ្វើការរយៈពេល៣ខែដោយការិយាល័យការងារខេត្ត។ ប្រទេសថៃកំពុងប្រឈមមុខនឹងកង្វះកម្លាំងពលករចំណាកស្រុកចំនួន ៨០០,០០០ ដែលត្រូវការសម្រាប់វិស័យផលិតកម្ម ទេសចរណ៍ និងសេវាកម្ម នេះបើយោងតាមសហព័ន្ធឧស្សាហកម្មថៃ៕ *Thai Khu Fah Facebook page/The Nation*

# ត្រឹមមួយយប់ ឃាត់ខ្លួនពលរដ្ឋខ្មែរប្រុសស្រី១០នាក់ នៅ២គោលដៅផ្សេងគ្នា

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២០ ខែ កុម្ភៈ ឆ្នាំ ២០២២ ម៉ោង ១៥:១៤

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងនគរបាលការពារព្រំដែនគោកលេខ៨១៥ និងកម្លាំងយោធាវរសេនាតូចការពារព្រំដែនលេខ៥១៣ នៅវេលាម៉ោង១១និង១០នាទីយប់ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២ បានធ្វើការទប់ស្កាត់ពលរដ្ឋខ្មែរបម្រុងលួចឆ្លងដែនចំនួន០២នាក់ (ស្រី) បម្រុងលួចឆ្លងដែនដោយខុសច្បាប់តាមភូមិសាស្ត្រប៉ុស្តិ៍ស្ពានម៉ាឡៃ ស្ថិតក្នុងភូមិត្រសេកជ្រុំ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ និងនៅយប់ថ្ងៃដដែលកម្លាំងទាហាន ( ព្រាន ) ឈុតខ្មៅថៃអនុសេនាធំ ១៣.០៥ បានឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន០៨នាក់ទៀត ក្នុងនោះស្រី០៣នាក់ ដែលលួចឆ្លងចូលទឹកដីថៃ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ បានឲ្យដឹងថា ពលរដ្ឋខ្មែរចំនួន០២នាក់ (ស្រី) ក្រោយពីត្រូវកម្លាំងនគរបាល និងកម្លាំងយោធា ឃាត់ខ្លួន និងសួរនាំ ធ្វើកិច្ចសន្យារួចមក ក៏បានធ្វើការប្រគល់ទៅអធិការដ្ឋាននគរបាលស្រុម៉ាឡៃ ដើម្បីមានវិធានការបន្ត ។ លោកមេបញ្ជាការបានបញ្ជាក់ទៀតថា ដោយឡែកនៅវេលាម៉ោង១១និង៣០នាទីយប់ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២ដដែល

ក៏មានពលរដ្ឋខ្មែរចំនួន០៨នាក់ទៀត ក្នុងនោះស្រី០៣នាក់ បានលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ តាមចំណុចភូមិអូរសំព័រ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ហើយត្រូវបានទាហានព្រានឈុតខ្មៅថៃ កងអនុសេនាធំលេខ១៣.០៥ ដែលឈរជើងទល់មុខភូមិសាស្ត្រប៉ុស្តិ៍ក្បាលទំនប់ ធ្វើការឃាត់ខ្លួនផងដែរ ។ ប្រភពដដែលបន្តថា ពលរដ្ឋទាំង០៨នាក់ខាងលើនេះ បន្ទាប់ពីធ្វើការសួរនាំរួច ទាហានព្រានឈុតខ្មៅថៃកងអនុសេនាធំលេខ១៣.០៥ បានបញ្ជូនពួកគាត់ទៅកាន់អធិការដ្ឋាននគរបាលក្លងណាំសៃ ស្ថិតក្នុងភូមិបានណូន ឃុំផានសឹក ស្រុកអារញ្ញ ខេត្តស្រះកែវ ដើម្បីចាត់វិធានការបន្តទៀត ៕

## អាជ្ញាធរចិនអះអាងថា
## បុរសចិនម្នាក់រងគ្រោះដោយការជួញដូរនៅកម្ពុជាតាមរយៈការខោរគេហទំព័រ 58.com

https://www.rfa.org/khmer/ ដោយ ម៉ៅ សុជានី 2022-02-19

ពាក់ព័ន្ធនឹងជនរងគ្រោះជួញដូរមនុស្សជនជាតិចិននេះដែរ អាជ្ញាធរចិនរកឃើញថា ជនរងគ្រោះរូបនេះបានជឿលើការផ្សព្វផ្សាយពាណិជ្ជកម្មរកការងារ តាមរយៈគេហទំព័រ 58.com ដើម្បីទៅធ្វើការជាឆ្មាំសន្តិសុខ នៅតាមក្លឹបកំសាន្តរាត្រីនៅប្រទេសកម្ពុជា ដែលនឹងទទួលបានប្រាក់ខែច្រើន ជាងធ្វើឆ្មាំសន្តិសុខនៅប្រទេសចិន។

ទីភ្នាក់ងារព័ត៌មានរ៉យទ័រ (Reuters) ចុះផ្សាយកាលពីថ្ងៃទី១៨ ខែកុម្ភៈ ឲ្យដឹងថា គេហទំព័រ 58.com នេះមានជាប់ពាក់ព័ន្ធនឹងក្រុមឧក្រិដ្ឋជន រកស៊ីជួញដូរមនុស្សនៅប្រទេសកម្ពុជា។ ក្រុមហ៊ុនផ្សាយពាណិជ្ជកម្មនេះ មានលក្ខណៈស្រដៀងគ្នាទៅនឹងក្រុមហ៊ុនមួយនៅសហរដ្ឋអាមេរិក ឈ្មោះ ក្រេកលីស (Craigslist)។ ម្ចាស់ក្រុមហ៊ុននេះ សន្យាថា នឹងសហការជាមួយប៉ូលិសស៊ើបអង្កេតនៅកម្ពុជា ពាក់ព័ន្ធនឹងករណី ជួញដូរមនុស្សនេះ ទោះបីមិនទាន់ដឹងច្បាស់ថា តើការផ្សាយពាណិជ្ជកម្មការងារនេះ មានការក្លែងបន្លំលើគេហទំព័ររបស់ខ្លួនដែរឬទេ។

ទោះបីជាស្ថានទូតចិនប្រចាំកម្ពុជា បានចេញសេចក្តីថ្លែងការណ៍ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ដោយបានទទួលស្គាល់ថា លោក លី ត្រូវបានបោកបញ្ឆោត តាមការផ្សាយពាណិជ្ជកម្មមិនពិតនេះ និងត្រូវបានក្រុមឧក្រិដ្ឋជនជួញដូរមនុស្ស វាយធ្វើបាប និងបានបូមឈាមជាច្រើនដង ដោយសារគាត់មិនព្រមធ្វើការតាមការបង្ខិតបង្ខំក៏ដោយ ក៏ប៉ុន្តែស្ថានទូតមិនបានបញ្ជាក់ប្រាប់ពីគេហទំព័រផ្សាយពាណិជ្ជកម្ម 58.com នោះឡើយ។ ស្ថានទូតចិនប្រចាំនៅកម្ពុជា ក៏បានក្រើនរំលឹកដល់ប្រជាពលរដ្ឋរបស់ខ្លួន ដែលចង់មកធ្វើការនៅប្រទេសកម្ពុជា ត្រូវអនុវត្តតាមបណ្តាញផ្លូវការ និងកុំឱ្យជឿលើការផ្សាយពាណិជ្ជកម្មមិនពិត អំពីការងារដែលមានប្រាក់ខែខ្ពស់។ ក្នុងករណីមានការក្លែងបន្លំ ចាប់ជំរិត និងការរឹតត្បិតសេរីភាពផ្ទាល់ខ្លួន ជាដើម ជនរងគ្រោះ ត្រូវតែព្យាយាមរាយការណ៍ទៅស្ថានទូតអំពីស្ថានការណ៍ ដើម្បីឱ្យប៉ូលិសស៊ើបអង្កេតទាន់ពេលវេលា។ ប្រភពដដែលបន្តថា ល្បែងកាស៊ីណូភ្នាល់អនឡាញ (Online) កំពុងប្រតិបត្តិការខុសច្បាប់នៅប្រទេសកម្ពុជា និងនៅប្រទេសហ្វីលីពីន (Philippines) ដែលអាជ្ញាធរនៃប្រទេសទាំងនេះ មិនបានចាត់វិធានការម៉ឺងម៉ាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបឡើយ៕

## សមត្ថកិច្ចអះអាងថា កំពុងស៊ើបអង្កេតករណីបង្ខំបូមឈាមជនជាតិចិននៅខេត្តព្រះសីហនុ

https://www.rfa.org/khmer/ ដោយ ម៉ៅ សុជានី 2022-02-18

សមត្ថកិច្ចអះអាងថា កំពុងស៊ើបអង្កេតករណីបោកបញ្ឆោតបូមឈាមជនជាតិចិនម្នាក់ ដែលរងគ្រោះដោយការជួញដូរនៅខេត្តព្រះសីហនុ។ សមត្ថកិច្ចអះអាងថា ករណីនេះពិបាកស្រាវជ្រាវ និងស៊ើបអង្កេត ដោយសារព័ត៌មានដែលជនរងគ្រោះផ្តល់ព័ត៌មានមិនច្បាស់លាស់។ មន្ត្រីអង្គការសង្គមស៊ីវិលជំរុញដល់សមត្ថកិច្ចខេត្តព្រះសីហនុ បើកការស៊ើបអង្កេតឱ្យបានម៉ត់ចត់ ដើម្បីទប់ស្កាត់អំពើឧក្រិដ្ឋទាំងនោះ។ សមត្ថកិច្ចខេត្តព្រះសីហនុអះអាង

ថា មន្ត្រីជំនាញកំពុងស៊ើបអង្កេតករណីជនជាតិចិនម្នាក់ដែលត្រូវបានគេបង្ខំបូមឈាម រហូតដល់មានបញ្ហាសុខភាពធ្ងន់ធ្ងរ។

ស្នងការនគរបាលខេត្តព្រះសីហនុ លោក ជួន ណារិន ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី១៨ កុម្ភៈថា រហូតមកដល់ពេលនេះសមត្ថកិច្ចជំនាញ មិនទាន់រកឃើញទីតាំងធ្វើទារុណកម្ម ឬបង្ខាំង និងការបូមឈាមលក់ដូចការលើកឡើងទេ ដោយសារបុរសជនជាតិចិននោះផ្តល់ព័ត៌មានឱ្យសារព័ត៌មាន និងសមត្ថកិច្ចមិនជាក់លាក់អំពីទីតាំង។ លោកបន្តថា សមត្ថកិច្ចត្រូវការកិច្ចសហការជាមួយគាត់ និងតំណាងស្ថានទូតចិនឱ្យបានច្បាស់លាស់បន្ថែមទៀត ដើម្បីស្រាវជ្រាវ និងចាត់វិធានការតាមផ្លូវច្បាប់លើក្រុមជនល្មើស៖ «ជាប្រធានបទមួយដែលខ្ញុំជាសមត្ថកិច្ចត្រូវការស្រាវជ្រាវ ប៉ុន្តែពីមុនរហូតមកដល់ឥឡូវនេះយើងមិនទាន់ជួបប្រទះថា អ្នកណាមួយដែលចាប់មនុស្សបូមឈាមលក់ទេ ព័ត៌មាននេះយើងកំពុងធ្វើការស្រាវជ្រាវ ហើយគ្មានទីតាំងណាមួយអាចកំបាំងដែលសមត្ថកិច្ចយើងចូលបានទេ ប៉ុន្តែការចង្អុលបង្ហាញរបស់គាត់តាមសារព័ត៌មាន និងគាត់និយាយនេះមិនជាក់លាក់អំពីទីតាំងច្បាស់លាស់ អ៊ីចឹងត្រូវតែសហការជាមួយគាត់ឱ្យបានត្រឹមត្រូវ»។

ជនជាតិចិនដែលរងគ្រោះដោយសារការជួញដូរនោះ មានឈ្មោះ លី អាយុជាង៣០ឆ្នាំ។ ពេលនេះ លោកកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមួយក្នុងខណ្ឌចំការមន រាជធានីភ្នំពេញ។ លោកអះអាងថា លោកត្រូវបានគេបោកបញ្ឆោតឱ្យបង្ហូរឈាមរបស់គាត់ជាច្រើនដងនៅកម្ពុជាចាប់តាំងពីខែសីហា ឆ្នាំ២០២១ ដែលធ្វើឱ្យគាត់ទន់ខ្សោយ និងសុខភាពស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងន់។ លោក លី បានរៀបរាប់ប្រាប់វិទ្យុវីអូឌី (VOD) ថា លោកធ្លាប់ជាផ្ទាំសន្តិសុខនៅទីក្រុងប៉េកាំង ប៉ុន្តែដោយសារមើលឃើញថាមានការផ្សព្វផ្សាយទាក់ទងនឹងការងារដែលទទួលប្រាក់ខែល្អជាងមុន លោកបានធ្វើដំណើរមកនៅខេត្តក្វាងស៊ី (Guangxi) ជិតព្រំដែនវៀតណាម។ បន្ទាប់មក លោក ត្រូវបានគេសម្ភាសន៍ ហើយត្រូវបានដឹកតាមឡានជាច្រើនថ្ងៃឆ្លងកាត់វៀតណាមមកដល់កម្ពុជានៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២១។ លោកអះអាងទៀតថា លោកត្រូវបានគេវាយដំជាច្រើនដងនៅអគារ ដែលលោកស្គាល់ឈ្មោះថា ជីន ស៊ី ១០ (Jinshui 10) និងកៃបូ (Kaibo) នៅក្នុងបរិវេណឆៃណាថោន (Chinatown) ក្បែរផ្លូវអូរត្រេះ ក្រុងព្រះសីហនុ និងនៅខេត្តកោះកុងផងដែរ។ លោកបញ្ជាក់ថា លោកត្រូវបានគេបូមឈាមក្នុងបរិមាណដ៏ច្រើន រហូតដល់លោកមានបញ្ហាសុខភាពធ្ងន់ធ្ងរអំឡុងពេលនោះ។

ជុំវិញរឿងនេះ ស្ថានទូតចិនប្រចាំកម្ពុជា បានចេញសេចក្ដីថ្លែងការណ៍មួយកាលពីថ្ងៃទី១៦ ខែកុម្ភៈ ដោយបានទទួលស្គាល់ថា លោក លី ត្រូវបានបោកបញ្ឆោតតាមការផ្សាយពាណិជ្ជកម្មមិនពិត ហើយត្រូវបានបង្ខិតបង្ខំដោយឧក្រិដ្ឋជនឱ្យឆ្លងកាត់ពន្ធមនុស្សមកកម្ពុជា។ បន្ទាប់មក គាត់ត្រូវបានឃុំខ្លួនដោយខុសច្បាប់ដោយក្រុមល្បែងស៊ីសងតាមអ៊ីនធឺណិត និងក្រុមឆបោកនៅឆៃណាថោន (Chinatown) ក្នុងខេត្តព្រះសីហនុ ហើយបូមឈាមជាច្រើនដងរហូតដល់គាត់ស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ។ ស្ថានទូតបានឱ្យដឹងទៀតថា ស្ថានភាពរាងកាយអ្នកជំងឺមានស្ថានភាពល្អប្រសើរហើយ ហើយស្ថានទូតកំពុងស៊ើបអង្កេតករណីរំលោភបំពាននេះ ដើម្បីកសាងសំណុំរឿងឱ្យបានឆាប់រហ័ស។

ទាក់ទិនរឿងនេះ នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការលីកាដូ (Licadho) លោក អំ សំអាត សង្កេតឃើញថា បទល្មើសឧក្រិដ្ឋភាគច្រើននៅខេត្តព្រះសីហនុបង្កឡើងជនជាតិចិន ហើយបង្កអសន្តិសុខសង្គម និងបង្កភាពភ័យខ្លាចពលរដ្ឋ។ លោកបន្តថា ករណីជួញដូរសរីរាង្គមនុស្សដោយការបង្ខំបូមឈាម គឺជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ដែលទាមទារឱ្យអាជ្ញាធរស៊ើបអង្កេតឱ្យបានច្បាស់លាស់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេះ៖ «ករណីនេះយើងឃើញថា មិនមែនករណីធម្មតាទេ ដែលទាមទារឱ្យមានការស៊ើបអង្កេតឱ្យបានច្បាស់លាស់ ពីព្រោះប្រសិនបើកើតលើទឹកដីកម្ពុជាយើងមែន ត្រូវតែស៊ើបអង្កេតរកឫសគល់ រកបញ្ហា ដូចជាបទល្មើសដែលបានកើត

ឡើងហ្នឹងយ៉ាងម៉េច ហើយអនុវត្តន៍តាមផ្លូវច្បាប់ ប្រសិនអ្វីដែលជនរងគ្រោះរៀបរាប់ពិតប្រាកដ វាគឺជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរណាស់»។

កាលពីឆ្នាំ២០២០ សមត្ថកិច្ចកម្ពុជាបានចាប់ខ្លួនជនជាតិចិនជាង ៥០០ (៥២៣)នាក់ ពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលពួកគេបានប្រព្រឹត្តនៅកម្ពុជា។ សមត្ថកិច្ចឱ្យដឹងថា ជនជាតិចិនដែលត្រូវបានចាប់ខ្លួនភាគច្រើនមានជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើឃាតកម្ម ចាប់ជំរិតទារប្រាក់ អំពើហិង្សា ឆបោក ចោរកម្ម រត់ពន្ធថ្នាំញៀន និងការប្រើប្រាស់អាវុធខុសច្បាប់៕

## កងកម្លាំងអាជ្ញាធរ បន្តទទួលពលករ
## វិលត្រឡប់មកស្រុកវិញ ដែលភាគីថៃ បញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្រុកកំរៀង

https://gdlf-kh.com/ 20/02/2022 Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃអាទិត្យ ៤ រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១២ ដោយអនុវត្តនតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យ ទៅទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។

ពលករដែលវិលត្រលប់មកកម្ពុជាវិញ សរុបចំនួន១៣៨នាក់, ស្រី៤៩នាក់ និងក្មេង២១នាក់ បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩រួចរាល់ ក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័ស និងជាលទ្ធផល គឺវិជ្ជមានកូវីដ-១៩ ២នាក់ (ក្មេងស្រីម្នាក់)។ ក្នុងនោះពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន៧៣នាក់ (ស្រី២៤នាក់, ក្មេង១១នាក់) ចំណែកពលករចំនួន៥៩នាក់, ស្រី២៤នាក់ និងក្មេង៩នាក់ ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ដោយបានចាក់វ៉ាក់សាំងអោយក្មេងចាប់ពីអាយុ ៥ឆ្នាំ ដល់ ១៨ឆ្នាំ ចំនួន៣នាក់ (ស្រី៣នាក់) ហើយក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ៕

## អាជ្ញាធរស្រុកសំពៅលូន ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពី
## ប្រទេសថៃ និងប្រគល់ទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣

https://gdlf-kh.com/ 2022/02/20/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៨និង២០នាទី នាថ្ងៃអាទិត្យ ៣រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹង ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍)សហការជាមួយ

កម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី កៅ-ប៊ុណ្ណា (មេបញ្ជាការរងកងអនុសេនាធំ), កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ធុក-លឹមយី (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញត្រង់ចំណុចភូមិសាស្ត្រ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០៧នាក់, (ស្រី០២នាក់ ក្មេង០៣នាក់ ក្មេងស្រី០១នាក់)។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើការកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣។

## ថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ២០២២

### សម្តេចក្រឡាហោម
### ទាមទារឲ្យមានការដោះស្រាយ បញ្ហាអំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន សកម្មភាពផលិត ចរាចរណ៍ ជួញដូរគ្រឿងញៀនខុសច្បាប់ សកម្មភាពជួញដូរមនុស្ស បទល្មើសបច្ចេកវិទ្យា

https://cen.com.kh/ Posted ByPen Srey NeatFebruary 22, 2022

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានមានប្រសាសន៍ថា ក្រសួងមហាផ្ទៃ ដែលស្ថាប័នទទួលខុសត្រូវ ក្នុងការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ បានខិតខំប្រឹងប្រែងរួមគ្នា រក្សាការពារបានយ៉ាងរឹងមាំនូវសុខសន្តិភាព ស្ថិរភាពនយោបាយ ឯករាជ្យ អធិបតេយ្យជាតិ បូរណភាពទឹកដី សន្តិសុខជាតិ ដោយបញ្ចៀសបានអំពើភេរវកម្ម និងបង្ការទប់ស្កាត់ បានទាន់ពេលវេលា នូវឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ធានារក្សាបានសន្តិសុខផ្ទៃក្នុងប្រទេស យ៉ាងល្អប្រសើរ។ សម្តេច បានគូសបញ្ជាក់ថា នៅមានបញ្ហាប្រឈមដែលទាមទារការដោះស្រាយ ដូចជាអំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន សកម្មភាពផលិត ចរាចរណ៍ ជួញដូរគ្រឿងញៀនខុសច្បាប់ សកម្មភាពជួញដូរមនុស្ស បទល្មើសបច្ចេកវិទ្យា ការប្រែប្រួលធាតុអាកាស ដែលសុទ្ធតែជាបញ្ហាប្រឈម ទាមទារការខិតខំពង្រឹងខ្លួន ដើម្បីឆ្លើយតបឱ្យបានទាន់ ពេលវេលានិងមានប្រសិទ្ធភាព។

នាព្រឹកថ្ងៃអង្គារ ទី២២ ខែកុម្ភៈ ឆ្នាំ២០២២នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីក្នុងពិធីបើកសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ប្រារព្ធនៅសណ្ឋាគាររ៉េស៊ីដង់ សុខា ភ្នំពេញ។ អញ្ជើញមានប្រសាសន៍បើកសន្និបាតនាឱកាសនោះ សម្តេចក្រឡាហោម ស ខេង ឧបនាយរដ្ឋមន្ត្រី បានសម្តែងការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវអស់ជាថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការស៊ីវិល និងនគរបាលជាតិ ដែលបានចូលរួមចំណែក និងផ្តល់នូវកិច្ចសហការគាំទ្រដល់ក្រសួងមហាផ្ទៃ ក្នុងការបំពេញបេសកកម្មបម្រើជាតិមាតុភូមិ សម្រេចបានសមិទ្ធិផលនានាជាច្រើន ក្នុងរយៈពេលមួយឆ្នាំកន្លងទៅនេះ។ សម្តេចក៏បានបង្ហាញការកត់សម្គាល់អំពីសភាពការណ៍ និងសមិទ្ធិផលសំខាន់ៗ ដែលក្រសួងមហាផ្ទៃ ខិតខំសម្រេចបានក្នុងឆ្នាំកន្លងទៅ ក្នុងនោះឆ្នាំ២០២១ជាឆ្នាំដែលសភាពការណ៍ពិភពលោក និងតំបន់មានការប្រែប្រួលឆាប់រហ័ស និងស្មុគស្មាញ ក្នុងនោះការឆ្លងរាតត្បាតជំងឺកូវីដ-១៩ បានបង្កឱ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ច និងសង្គមគ្រប់ប្រទេស ខណៈការប្រកួតប្រជែងខាងភូមិសាស្ត្រនយោបាយ សេដ្ឋកិច្ច បច្ចេកវិទ្យា និងយោធាកាន់តែមានភាពតានតឹង។

សម្តេចបន្ថែមថា ស្របពេលទទួលរងសម្ពាធពីសភាពការណ៍សាកលនេះ នៅក្នុងប្រទេសកម្ពុជា ក្រុមប្រឆាំងជ្រុលនិយម និងមជ្ឈដ្ឋានអគតិ ក្នុងនិងក្រៅប្រទេស បានបន្តខិតខំរិះរកឧបាយកល និងសកម្មភាពខុសច្បាប់ ដើម្បីប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលនិងរបបរាជានិយម ក្នុងគោលបំណងដណ្តើមអំណាចដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរមកលើរដ្ឋធម្មនុញ្ញ និងគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ សម្តេចក្រឡាហោមបាន

ឱ្យដឹងថា ក្រសួងមហាផ្ទៃដែលស្ថាប័នទទួលខុសត្រូវ ក្នុងការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈបានខិតខំប្រឹងប្រែងរួមគ្នា រក្សាការពារបានយ៉ាងរឹងមាំនូវសុខសន្តិភាព ស្ថិរភាពនយោបាយ ឯករាជ្យ អធិបតេយ្យជាតិ បូរណភាពទឹកដី សន្តិសុខជាតិ ដោយបញ្ចៀសបានអំពើភេរវកម្ម និងបង្ការទប់ស្កាត់បានទាន់ពេលវេលានូវឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ធានារក្សាបានសន្តិសុខផ្ទៃក្នុងប្រទេសយ៉ាងល្អប្រសើរជាទូទៅ។ សម្តេចបន្ថែមថា នៅក្នុងឆ្នាំ២០២១កន្លងទៅ កងកម្លាំងនគរបាលជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បានខិតខំពុះពារកែកពន្ធការងារជាច្រើន ប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម ចូលរួមអនុវត្តដោយផ្ទាល់នូវវិធានការរាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ការជួយដោះស្រាយជីវភាពពលរដ្ឋទទួលរងផលប៉ះពាល់ដោយកូវីដ-១៩ និងគ្រោះធម្មជាតិនានា។

អាស្រ័យដោយកិច្ចខិតខំប្រឹងប្រែងពីកងកម្លាំងនគរបាលជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បានធ្វើឱ្យបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទថយចុះ៦ភាគរយ ជាពិសេសបទល្មើសឧក្រិដ្ឋដែលជះឥទ្ធិពលដល់ចិត្តសាស្ត្រសង្គមក៏បានថយចុះ១៤ភាគរយ ហើយលទ្ធផលនៃការបង្ក្រាបបទល្មើសនានាក៏មានកម្រិតខ្ពស់រហូតដល់៩៣ភាគរយ។ សម្តេចបន្តថា យុទ្ធនាការប្រយុទ្ធប្រឆាំងបទល្មើសនានា ក៏ត្រូវបានចាត់ចែងអនុវត្តជាប្រចាំទោះបីជារំខានខ្លះៗដោយជំងឺកូវីដ-១៩ក៏ដោយ ដូចជាយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ សកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផ្លូវភេទ ការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ បទល្មើសសេដ្ឋកិច្ច និងបទល្មើសផ្សេងៗ។ សម្តេចបន្តថា បញ្ហាសណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គមនៅតាមទីក្រុង ទីប្រជុំជន និងតំបន់ទេសចរណ៍សំខាន់ៗ ត្រូវបានបន្តខិតខំយកចិត្តទុកដាក់ ដោយផ្តោតជាសំខាន់លើការផ្សព្វផ្សាយអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹង និងការចូលរួមគោរពអនុវត្តច្បាប់ ហើយទន្ទឹមនឹងការរឹតបន្តឹងការអនុវត្តច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក ក៏បានធ្វើឱ្យគ្រោះថ្នាក់ចរាចរណ៍ មានការថយចុះបើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។

ចំពោះការបង្ការទប់ស្កាត់អគ្គិភ័យវិញ ហេតុការណ៍គ្រោះថ្នាក់អគ្គិភ័យមានការថយចុះ២៨ភាគរយ ខណៈការបំរើសេវាសន្តិសុខ និងសេវាតម្រូវការចាំបាច់នានានៅមូលដ្ឋាន ក៏ត្រូវបានពង្រឹងសមត្ថភាព និងកែលម្អរជាប្រចាំនូវរបៀបរបប និងអាកប្បកិរិយាធ្វើការងាររបស់មន្ត្រីប៉ុស្តិ៍រដ្ឋបាលឃុំសង្កាត់ និងការជំរុញចលនាអនុវត្តគោលនយោបាយជាតិ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព។ ពាក់ព័ន្ធនឹងគ្រប់គ្រងជនបរទេស សម្តេចក្រឡាហោមបានឱ្យដឹងថា ក្រសួងបានបង្កើនការយកចិត្តទុកដាក់ ក្នុងការគ្រប់គ្រងការចេញចូលតាមបណ្តាច្រកព្រំដែននានា ជាមួយនឹងការអនុវត្តវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺនៃកូវីដ-១៩ និងការគ្រប់គ្រងវត្តមានស្នាក់នៅរបស់ជនបរទេស នៅក្នុងប្រទេសដោយយកចិត្តទុកដាក់ ក្នុងការពង្រឹងសមត្ថភាពការងាររបស់មន្ត្រី ការបំពាក់មធ្យោបាយ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ។ ចំណែកការងារអត្តសញ្ញាណកម្ម សម្តេចបានលើកឡើង អំពីការខិតខំអភិវឌ្ឍន៍ទាំងក្របខណ្ឌគោលនយោបាយ ច្បាប់ ការផ្គត់ផ្គង់ឧបករណ៍ សម្ភារៈបច្ចេកទេស ការបណ្តុះបណ្តាល ការកសាងសមត្ថភាពមន្ត្រី និងការលើកកម្ពស់កិច្ចសហការជាមួយក្រសួងស្ថាប័ន និងដៃគូពាក់ព័ន្ធ ដើម្បីពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងអត្តសញ្ញាណបគ្គលសំដៅឆ្លើយតបសំណូមពរពលរដ្ឋ និងកិច្ចអភិវឌ្ឍន៍លើវិស័យនានាដែលប្រើប្រាស់ទិន្នន័យបុគ្គល។ សម្រាប់ការងារពន្ធនាគារវិញ សម្តេចក្រឡាហោម បានបន្តលើកឡើងពីការបន្តប្រមូលផ្តុំយក ចិត្តទុកដាក់លើការគ្រប់គ្រង ថែរក្សាការពារសន្តិសុខតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ ការទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩ដល់មន្ត្រីអនុរក្ស និងជនជាប់ឃុំ ព្រមទាំងបង្កើនកិច្ចសហការជាមួយក្រសួងស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ដើម្បីដោះស្រាយភាពចង្អៀតណែនតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារនានា និងការបន្តខិតខំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារនានា។

ដោយឡែកការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ សម្តេចក្រឡាហោមបានមានប្រសាសន៍ថា ក្រសួងមហាផ្ទៃ បានខិតខំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ដើម្បីរៀបចំបញ្ចប់ និងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចជាផ្លូវការនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ នៅក្នុងដំណាក់កាលទីពីរ ២០២១-២០៣០ ដោយលេខាធិការ គ.ជ.អ.ប ក៏បានខិតខំសហការជាមួយក្រសួងពាក់ព័ន្ធ និងដៃគូពាក់ព័ន្ធនានាដើម្បីរៀបចំនូវផែនការ អនុវត្តកម្មវិធីជាតិដំណាក់កាលទីមួយ ២០២១-២០២៥ និងរៀបចំផែនការថវិកាប្រចាំឆ្នាំ២០២២។ សម្តេចឧបនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់ថា ក្រៅពីសមិទ្ធផលខាងលើនេះ នៅមានសមិទ្ធិផលជាច្រើនទៀតដែល ក្រសួងមហាផ្ទៃសម្រេច បានក្នុងឆ្នាំ ២០២១ ដូចជាការងារកសាងក្របខណ្ឌគោលនយោបាយ ច្បាប់ យុទ្ធសាស្ត្រ ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្ស ទាំងផ្នែកស៊ីវិល និងនគរបាលជាតិ ការងារអធិការកិច្ច ការដោះស្រាយពាក្យបណ្តឹង និងសំណើរ សំណូមពររបស់ប្រជាពលរដ្ឋ ការងារអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន ការលើកម្ពស់ កិច្ចសហការអន្តរស្ថាប័នជាមួយក្រសួងស្ថាប័ននានា នៃរាជរដ្ឋាភិបាល កិច្ចសហប្រតិបត្តិការអន្តរជាតិ ការផ្លាស់ប្តូរបទពិសោធន៍ ជាមួយប្រទេសនានា និងការចូលរួមរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

សមិទ្ធផលដូចបានបញ្ជាក់លើនេះ ត្រូវបានសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី មានប្រសាសន៍ថា ពិតជា បានមកដោយការចូលរួមធ្វើពលីកម្ម យ៉ាងធំធេងរបសកងកម្លាំងនគរបាលជាតិ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់ ដែលបានពុះពារជម្នះគ្រប់ឧបសគ្គ ធានាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ព្រមទាំងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋក្នុងបរិបទ ដែលប្រឈមនឹងការឆ្លងរីករាលដាលជំងឺកូវីដ-១៩។ ទន្ទឹមនឹងសមិទ្ធិផលទាំងនេះដែរ សម្តេចក៏បានគូសបញ្ជាក់ថា នៅមានបញ្ហាប្រឈម ដែលទាមទារការដោះស្រាយ ដូចជាអំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន សកម្មភាពផលិត ចរាចរណ៍ ជួញដូរគ្រឿងញៀនខុសច្បាប់ សកម្មភាពជួញដូរមនុស្ស បទល្មើសបច្ចេកវិទ្យា ការប្រែប្រួលធាតុអាកាស ដែលសុទ្ធតែជាបញ្ហាប្រឈមទាមទារការខិតខំពង្រឹងខ្លួនដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាព។ សម្តេចបន្តថា បញ្ហាសន្តិសុខសណ្តាប់ធ្នាប់ផ្ទៃក្នុងប្រទេស បញ្ហាប្រឈមដែលជាកង្វល់ក្នុងសង្គមគឺការចរាចរណ៍ ជួញដូរ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ក្នុងនោះរួមទាំងនិន្នាការនៃការលួចប្រើប្រាស់សាធាតុគីមីផ្សំដើម្បីផលិតគ្រឿងញៀនខុសច្បាប់ទ្រង់ទ្រាយធំ គ្រោះថ្នាក់ចរាចរណ៍ ការជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងផលិតផលក្លែងក្លាយអន់គុណភាព ហើយបទល្មើសព្រហ្មទណ្ឌទោះបីមានការថមថយ ប៉ុន្តែបទល្មើសមួយចំនួននៅតែមានចំនួនច្រើន ដូចជាអំពើលួច មនុស្សឃាតដោយចេតនា អំពើហិង្សា ការរំលោភនិងការបំពានខាងផ្លូវភេទ។

ដោយឡែកបញ្ហាប្រឈមក្នុងការងារកំណែទម្រង់វិជ្ឈការ និងវិសហមជ្ឈការ សម្តេចបានកត់សម្គាល់ អំពីការលំបាកក្នុងការស្វះស្វែងរកការស្រុះស្រួលឯកភាពគ្នាក្នុងដំណើរការផ្ទេរមុខងារ និងធនធាន ព្រមទាំងសមត្ថភាពយល់ដឹងរបស់មន្ត្រីអំពីប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ ទាំងកម្រិតមន្ត្រីតាក់តែងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានា និងមន្ត្រីអនុវត្ត ខណៈការងារផ្សេងៗទៀតដែលនៅមានការប្រឈម និងខ្វះខាតនោះរួមមានការពង្រឹងសមត្ថភាពវិជ្ជាជីវៈដល់មន្ត្រីទាំងរដ្ឋបាលស៊ីវិល និងនគរបាលជាតិ ការលើកកម្ពស់មនសិការវិជ្ជាជីវៈ ការគោរពវិន័យ និងបទបញ្ជាផ្ទៃក្នុងតាមអង្គភាព និងការលើកកម្ពស់តម្លាភាព គណនេយ្យភាពលើការគ្រប់គ្រង ដឹកនាំអង្គភាព និងការចាត់ចែងការងារនានាផ្អែកតាមតួនាទីភារកិច្ចរបស់អង្គភាពនីមួយៗ។

រាល់បញ្ហាប្រឈមខាងលើនេះ ត្រូវបានសម្តេចក្រឡាហោមបញ្ជាក់ជូនអង្គសន្និបាត អំពីការទាមទារពង្រឹងការប្តេជ្ញាចិត្តរួមគ្នាពុះពារជម្នះដោះស្រាយសំដៅលើកកម្ពស់គុណភាព ប្រសិទ្ធភាពការងារនានា ក្នុងក្របខណ្ឌទទួលនាទី និងការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ ដើម្បីបម្រើផលប្រយោជន៍ជាតិ និងប្រជាជន។ សម្តេច

បន្ថែមថាសន្និបាតនាថ្ងៃនេះនឹងបែងចែកក្រុមពិភាក្សាលើប្រធានបទសំខាន់ៗ ដើម្បីប្រមែលប្រមូលធាតុចូលពីសមាជិកសមាជិការ នៃអង្គសន្និបាតសម្រាប់បំពេញបន្ថែម លើខ្លឹមសាររបាយការណ៍ និងទិសដៅរួមទាំងបញ្ហាប្រឈម និងដំណោះស្រាយ ព្រមទាំងគោលការណ៍សំខាន់ៗសម្រាប់អនុវត្តនៅឆ្នាំ២០២២នេះ។

សូមបញ្ជាក់ថា សន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ នឹងប្រព្រឹត្តទៅរយៈពេល២ថ្ងៃ ពីថ្ងៃទី២២ ដល់ថ្ងៃទី២៣ ខែកុម្ភៈនេះ៕ រក្សាសិទ្ធិដោយ ៖ សិទ្ធិដោយ ៖ សុទ្ធ លី

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស បើកសិក្ខាសាលាពិគ្រោះយោបល់ស្តីពីបែបបទនិងនីតិវិធី នៃការកំណត់អត្តសញ្ញាណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប

http://freshnewsasia.com/ 2022-02-21 12:19pm

**(ភ្នំពេញ)៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២នេះ បានបើកសិក្ខាសាលាពិគ្រោះយោបល់ពិនិត្យ និងកែសម្រួលសៀវភៅគោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។ សិក្ខាសាលានេះ បានធ្វើឡើងក្រោមអធិបតីភាពលោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមទាំងមានការអញ្ជើញចូលរួមពីសំណាក់ភាគីពាក់ព័ន្ធមួយចំនួន នាសណ្ឋាគារភ្នំពេញ។

ក្នុងនាមលោករដ្ឋមន្ត្រី វង សូត, លោកបានថ្លែងថា សៀវភៅគោលការណ៍ណែនាំស្តីពី បែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប បានចងក្រងផលិតតាំងពីឆ្នាំ២០១៥មកម្លេះ មានរយៈពេល ៦ឆ្នាំ មកហើយ។ ដូច្នេះ សមល្មមដល់ពេលដែលត្រូវកែសម្រួលខ្លឹមសារគោលការណ៍ ឬបន្ថែមនូវអ្វីដែលថ្មីៗសម្រាប់ អនុវត្តន៍ទៅតាមបរិបទសង្គមបច្ចុប្បន្ន និងធ្វើឱ្យមានភាពជាក់លាក់ច្បាស់លាស់ ដើម្បីប្រើប្រាស់នីតិវិធីរួមគ្នា។ លោករដ្ឋលេខាធិការ បានបន្តថា ដោយសារតែកន្លងមកទិន្នន័យមិនទាន់មានការបែកដាច់អំពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ឬជនងាយរងគ្រោះនៅឡើយ ពីព្រោះការអនុវត្តរបស់ក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធមានភាពខុសៗគ្នាមិនទាន់ត្រូវគ្នា ឬស៊ីសង្វាក់គ្នាដែលជាមូលហេតុធ្វើឱ្យមន្ត្រីជួរមុខជាអ្នកអនុវត្តផ្ទាល់មានការពិបាក ជាពិសេសធ្វើឱ្យរបាយការណ៍មិនមានការឯកភាពគ្នា។

ជាមួយគ្នានេះដែរ លោក ញឹក វណ្ណារ៉ា បានបញ្ជាក់ថា ម្យ៉ាងវិញទៀតអនុសាសន៍របស់សហរដ្ឋអាមេរិកដែលជារៀងរាល់ឆ្នាំបានលើកអំពីបញ្ហាជនរងគ្រោះ ដោយអំពើជួញដូរមនុស្សដោយភ្ជាប់នឹងការប្រើប្រាស់ពិធីសារ ឬគោលការណ៍នៃការកំណត់អត្តសញ្ញាណជន រងគ្រោះផងដែរ។ ទន្ទឹមនោះដែរក៏មានការដាក់បញ្ចូលបន្ថែមនូវទម្រង់ថ្មីៗ នៃបទល្មើសជួញដូរមនុស្ស ដូចជាករណីប្រព្រឹត្តបទល្មើសតាមប្រព័ន្ធអនឡាញ និងពិនិត្យលើខ្លឹមសារកំរងសំណួរនៃទម្រង់សម្ភាសន៍ វែង ខ្លី នៅមានចន្លោះប្រហោងនៅឡើយ។ ក្នុងនោះដែរការប្រើប្រាស់ពាក្យពេចន៍នៅក្នុងសៀវភៅគោលការណ៍ណែនាំនេះមិនទាន់មានភាពសង្វាក់គ្នានៅឡើយ។ លោករដ្ឋលេខាធិការ បានគូសបញ្ជាក់ថា ទោះបីជាយ៉ាងណាក៏ដោយ គជ.បជ បានខិតខំប្រឹងប្រែងអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទទួលបានលទ្ធផលល្អប្រសើរ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចក្រឡាហោម ស ខេង ក៏ដូចអនុប្រធានអចិន្ត្រៃយ៍ ហើយក៏មានការចូលរួមពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនផងដែរ។ ក្នុងការបំពេញភារកិច្ចទប់ស្កាត់ បង្ក្រាប ផ្តន្ទាទោស បទល្មើសជួញដូរមនុស្ស។

ក្នុងនោះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏បានខិតខំប្រឹងប្រែងបំពេញការងារ ចូលរួមដោះស្រាយបញ្ហានានា ក៏ដូចជាចូលរួមឆ្លើយតបទៅនឹងអនុសាសន៍របស់សហរដ្ឋអាមេរិក និងមានការចូលរួមកិច្ចប្រជុំ សិក្ខាសាលាជាច្រើនទៀតពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ និយាយដល់ចំណុចនេះ មន្ត្រីជាន់ខ្ពស់រូបនេះ ស្នើថាគួរមានយន្តការតែមួយ ទាំងក្រសួង ស្ថាប័ន និងអង្គការដៃគូរ ដើម្បីអនុវត្តឲ្យបានស៊ីសង្វាក់គ្នា ហើយធ្វើការបញ្ជូនទិន្នន័យទាំងអស់នោះ ទៅស្ថាប័នថ្នាក់ជាតិណាមួយជាអ្នកគ្រប់គ្រង និងសូមផ្តាំផ្ញើដល់លោក លោកស្រី មេត្តាចូលរួមពិភាក្សាឱ្យបានផុលផុស និងផ្តល់នូវធាតុចូលល្អៗ ដើម្បីធ្វើយ៉ាងណាឱ្យសៀវភៅនេះកាន់តែគ្រប់ជ្រុងជ្រោយ ងាយយល់ និងអនុវត្តកាន់តែមានប្រសិទ្ធភាព៕

## ពលករខ្មែរចេញពីកម្ពុជាទៅធ្វើការនៅថៃជាង២០០នាក់នៅថ្ងៃនេះ

https://kohsantepheapdaily.com.kh/ ប៉ោយប៉ែត ២១ ខែ កុម្ភៈ ឆ្នាំ ២០២២ ម៉ោង ១១:៥៦

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរតាមរយៈក្រុមហ៊ុនចំនួន២ មានជាង២០០នាក់ ចេញពីកម្ពុជាតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដើម្បីទៅធ្វើការស្របច្បាប់លើទឹកដីថៃ នៅថ្ងៃទី២១ កុម្ភៈ២០២២ នេះ ។ ពលករតាមរយៈក្រុមហ៊ុនទូចម៉ាណាក់ម៉ែនផៅវ័រស៊ុប្លាយមានចំនួន៦៦នាក់ ស្រី៣១នាក់ ។ តំណាងក្រុមហ៊ុនខាងលើប្រាប់កោះសន្តិភាពថា ពលករទាំង៦៦នាក់នេះ ត្រូវទៅធ្វើការផ្នែកសាច់មាន់នៅខេត្តសារ៉ាក់បូរី និងបញ្ជាក់ថា នេះជាលើកទី៣ ហើយដែលក្រុមហ៊ុនខ្លួនបានបញ្ជូនពលករទៅធ្វើការលើទឹកដីថៃ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ក្រោយភាគីថៃបើកដំណើរការទទួលពលករកម្ពុជា។ ដោយឡែក ពលករ១ក្រុមទៀតតាមរយៈក្រុមហ៊ុនSMSគឺSuccess manpower service Co,LTD ត្រូវទៅធ្វើការនៅខេត្តនគររាជសីម៉ាផ្នែករោងចក្រសាច់មាន់ ។ តំណាងក្រុមហ៊ុន SMSប្រាប់ថា ពលករតាមរយៈក្រុមហ៊ុនខ្លួនត្រូវចេញពីកម្ពុជាតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតនៅថ្ងៃនេះ បើតាមទិន្នន័យសរុបមានជាង២០០នាក់ប៉ុន្តែអាច និងមិនគ្រប់តាមចំនួនកំណត់ទេព្រោះពលករមួយចំនួនតូចអវត្តមាន និងខ្លះធ្វើតេស្តតាមម៉ាស៊ីនPCRវិជ្ជមានកូវីដ១៩ត្រូវនៅសម្រាកព្យាបាលក្នុងស្រុកសិន ៕

## កម្ពុជា និងថៃ ប្តេជ្ញាប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន

https://www.khmertimeskh.com/ ទិន សុខាវុធ / Khmer Times February 21, 2022

ប្រទេសថៃបានព្រមព្រៀងជាមួយអាជ្ញាធរកម្ពុជាក្នុងការបញ្ឈប់ពលករខ្មែរខុសច្បាប់ឆ្លងដែនចូលប្រទេសថៃ។ កាលពីថ្ងៃសៅរ៍ ប៉ូលិសព្រំដែនកម្ពុជាបានជួបសមភាគីថៃនៅស្រុកសំពៅលូន ខេត្តបាត់ដំបង ដើម្បីពិភាក្សាពីបញ្ហាពាក់ព័ន្ធនឹងការឆ្លងដែនខុសច្បាប់ និងបញ្ហាបរិស្ថាន។

ស្នងការរងនគរបាលខេត្តបាត់ដំបង លោកវរសេនីយ៍ឯក សួន ស៊ីវ៉ា មានប្រសាសន៍ថា ក្រោយបញ្ចប់កិច្ចប្រជុំ ភាគីទាំងសងខាងបានឯកភាពគ្នាធ្វើការរួមគ្នា ដើម្បីបញ្ឈប់ការឆ្លងដែនខុសច្បាប់ និងអនុវត្តតាមច្បាប់នៃប្រទេសទាំងពីរ។ លោកថា៖« លើសពីនេះ ប៉ូលីសថៃបានសុំឱ្យយើងជួយពួកគេនាំយកជំនួយមនុស្សធម៌ដល់សិស្សដែលរៀននៅតាមព្រំដែន។ យើងក៏បាននិយាយអំពីការប្រកួតបាល់ទាត់នៅពេលខាងមុខនេះផងដែរ»។ លោកក៏បានមានប្រសាសន៍ថា អាជ្ញាធរព្រំដែនក្នុងប្រទេសទាំងពីរបានព្រមព្រៀងជួបគ្នាជារៀងរាល់ខែ ដើម្បីពិភាក្សាអំពីបញ្ហាប្រឈម នៅតាមព្រំដែន។

ស្នងការនគរបាលខេត្ត លោកឧត្តមសេនីយ៍ត្រី សាត គឹមសាន មានប្រសាសន៍ថា មានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់ ហើយមនុស្សមួយចំនួនត្រូវបានចាប់ខ្លួន។ លោកបន្តថា៖ « តាមការណែនាំរបស់រដ្ឋាភិបាល សកម្មភាពឆ្លងដែនខុសច្បាប់ត្រូវបានហាមឃាត់។ យើងនៅតែឃើញមនុស្សឆ្លង

ដែនទៅរកការងារធ្វើនៅប្រទេសថៃ។ យើងនឹងប្រឹងប្រែងឲ្យអស់ពីសមត្ថភាពដើម្បីបញ្ឈប់ពួកគេពីការធ្វើដូច្នេះ»។ កាលពីខែមុន ពលរដ្ឋខ្មែរ ៧នាក់ត្រូវបានឃាត់ខ្លួន ខណៈពួកគេប៉ុនប៉ងឆ្លងដែនខុសច្បាប់ចូលទៅក្នុងប្រទេសថៃ ដោយកងកម្លាំងសន្តិសុខដែលកំពុងបំពេញកាតព្វកិច្ច។ ពួកគេត្រូវបានឃាត់នៅច្រកក្បាលទំនប់ខេត្តបន្ទាយមានជ័យ។

រដ្ឋាភិបាលបានបង្កើតគណៈកម្មការអន្តរក្រសួងមួយដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសការភ្ជាប់និងការប្រើប្រាស់សេវាទូរគមនាគមន៍កម្ពុជា។ កម្ពុជាក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយប្រទេសឡាវ ដើម្បីសហការក្នុងការបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ និងពង្រីកការផ្លាស់ប្តូរព័ត៌មានសម្ងាត់ផងដែរ។ ប្រែសម្រួលដោយ៖ សុ ជាតា

## ពលករខ្មែរ ៧នាក់ ស្លា.ប់ និងរបួស ដោយសារគ្រោះថ្នាក់ចរាចរណ៍ នៅលើទឹកដីថៃ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២១ ខែ កុម្ភៈ ឆ្នាំ ២០២២ ម៉ោង ១៩:២៨

ខេត្តបន្ទាយមានជ័យ៖ មនុស្សយ៉ាងតិច ៤នាក់ បានស្លា.ប់ និង៤នាក់ទៀត បានរងរបួស កាលពីយប់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២២ នៅលើកំណាត់ផ្លូវជាតិលេខ៣៥៩ ក្នុងឃុំក្រុកសំប៊ូន ស្រុកស៊ីមហាផូត ខេត្តប្រាជីនបូរី ដោយសារឧប្បត្តិហេតុគ្រោះថ្នាក់ចរាចរណ៍ រវាងរថយន្តតូច បុកពីក្រោយរថយន្តធំដឹកឈើ។ ក្នុងចំណោមអ្នករបួស និងស្លាប់ទាំងនោះ មានពលករខ្មែរ ៧នាក់។ អ្នករងគ្រោះក្នុងហេតុការណ៍នោះ គេមិនទាន់ស្គាល់អត្តសញ្ញាណនៅឡើយទេ។ តែមាន ៧នាក់ ជាពលករខ្មែរ ក្នុងនោះ ស្លា.ប់ ៣នាក់ និងរបួស ៤នាក់។ រីឯម្នាក់ទៀត ជាអ្នកបើកបរជនជាតិថៃ(ស្លា.ប់)។ នេះបើយោងតាមការចេញផ្សាយលើគេហទំព័រ និងកាសែតថៃមួយ។ ប្រភពបន្តថា មុនកើតហេតុ រថយន្តរងគ្រោះ បានដឹកពលករខ្មែរ ចំនួន ៧នាក់ បើកយ៉ាងលឿន ដោយគេសង្ស័យជាពលករខុសច្បាប់ និងទើបចេញពីព្រំដែន ក្នុងខេត្តបន្ទាយមានជ័យ។ ព្រោះតែលឿនពេក ហើយសង្ស័យរថយន្តជួបគ្រោះថ្នាក់នេះ មើលមិនឃើញរថយន្តធំកង់ ១០ ដឹកឈើ (ដើមប្រេងខ្យល់) ដែលបើកបរខាងមុខ ក៏បុកគូថរថយន្តធំនោះ បណ្តាលឲ្យអ្នកបើកបរ ជាជនជាតិថៃ និងពលករ ក្នុងរថយន្ត ស្លា.ប់ និងរបួសតែម្តង។ ពលករខ្មែរ ដែលរងរបួស ចំនួន ៤នាក់ ត្រូវបានអាជ្ញាធរ និងក្រុមរថយន្តសង្គ្រោះរបស់ថៃ ដឹកទៅព្យាបាលនៅមន្ទីរពេទ្យ កាប៊ីនបូរី ក្នុងខេត្តកើតហេតុ។ យ៉ាងណាក៏ដោយ ករណីនេះ កោះសន្តិភាព មិនអាចទាក់ទងរកអត្ថាធិប្បាយពីមន្ត្រីស្ថានកុងស៊ុលកម្ពុជា ប្រចាំខេត្តស្រះកែវ ប្រទេសថៃ បាននៅឡើយទេ៕ មុត សារុន

## ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០២២

## សម្តេចតេជោ ហ៊ុន សែន ដាក់ចេញ
## គោលការណ៍ណែនាំ ៩ចំណុច ដើម្បីកម្ពុជារក្សាសុខសន្តិភាពទាំងបច្ចុប្បន្ន និងអនាគត

http://freshnewsasia.com/ 2022-02-23 06:36pm

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានផ្តល់នូវគោលការណ៍ណែនាំចំនួន៩ចំណុចដល់ក្រសួងស្ថាប័ននិងអាជ្ញាធរពាក់ព័ន្ធទាំងអស់ដើម្បីឱ្យកម្ពុជារក្សាសុខសន្តិភាពទាំងបច្ចុប្បន្ននិងអនាគត។ គោលការណ៍ណែនាំនេះ ត្រូវបានដាក់ចេញក្នុងឱកាសដែល សម្តេចតេជោ ហ៊ុន សែន អញ្ជើញជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និង លើកទិសដៅការងារ ឆ្នាំ ២០២២ របស់ក្រសួងមហាផ្ទៃ នៅល្ងាចថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២។ **សម្តេចតេជោ ហ៊ុន សែន បានលើកឡើងថា ដើម្បីកម្ពុជារក្សាបាននូវសុខសន្តិភាព ទាំងបច្ចុប្បន្ន និងអនាគត ក្នុងនាមរាជរដ្ឋាភិបាល សម្តេចសូមផ្តល់នូវគោលការណ៍ណែនាំដូចខាងក្រោម៖**

**ទី១៖** បន្តរួមគ្នាថែរក្សាការពារសុខសន្តិភាព ស្ថិរភាព នយោបាយ ឯករាជ្យ បូរណភាពទឹកដី អធិបតេយ្យជាតិ ការពារព្រះមហាក្សត្រ ការពាររបបរាជានិយមអាស្រ័យរដ្ឋ-ធម្មនុញ្ញ បន្តជំរុញលើកកម្ពស់លទ្ធិប្រជាធិបតេយ្យសេរី- ពហុបក្ស ការការពារ និងលើកស្ទួយសិទ្ធិសេរីភាពរបស់ ប្រជាពលរដ្ឋជាមួយនឹងការពង្រឹងនីតិរដ្ឋ ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

**ទី២៖** បង្កើនការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សាធារណៈជាប់ជាប្រចាំ ត្រូវបន្តធ្វើការកែទម្រង់កងកម្លាំង-នគរបាលជាតិ ផ្អែកតាមយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានាដែលបានកំណត់ ពង្រឹងកងកម្លាំងនគរបាលជាតិ កសាងសមត្ថភាពកម្លាំងនគរបាលជាតិប្រកបដោយជំនាញវិជ្ជាជីវៈ និងក្រមសីលធម៌ខ្ពស់ ត្រូវប្រគល់តួនាទីភារកិច្ចមន្ត្រីក្រោមឱវាទស្របតាមមុខជំនាញ បទពិសោធន៍ និង ស្នាដៃបំពេញការងារ ។ ត្រូវទប់ស្កាត់រាល់សកម្មភាពភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងកាត់ព្រំដែនគ្រប់រូបភាព បទល្មើសបច្ចេកវិទ្យា ការចរាចរជួញដូរគ្រឿងញៀនខុសច្បាប់ ការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ និងបទល្មើសផ្សេងៗទៀត ជាពិសេសត្រូវបន្តស្រាវជ្រាវរាល់សកម្មភាពខុសច្បាប់ដែលប៉ុនប៉ងផ្តួល រំលំរាជរដ្ឋាភិបាលស្របច្បាប់ ។

**ទី៣៖** ដើម្បីបន្តពង្រឹងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ប្រកបដោយតម្លាភាព ខ្ញុំសូមណែនាំដល់ក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ : ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងសុខាភិបាល និងអាជ្ញាធរពាក់ព័ន្ធត្រូវសហការត្រួតពិនិត្យការនាំចូល ការគ្រប់គ្រង ការចែកចាយ និងប្រើប្រាស់សារធាតុគីមីផ្សំនៅតាមក្រុមហ៊ុន រោងចក្រ សហគ្រាសឱ្យបានជាប់ជាប្រចាំ ដើម្បីធានាការប្រើប្រាស់ត្រឹមត្រូវស្របតាមគោលការណ៍អនុញ្ញាត ។ ត្រូវពិនិត្យ វាយតម្លៃ និងរៀបចំឡើងវិញនូវគោលការណ៍ព្យាបាល និងការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដែលមានការកើនឡើងជាលំដាប់ ។

**ទី៤៖** កងកម្លាំងមានសមត្ថកិច្ចត្រូវបង្កើនវិធានការអប់រំច្បាប់ចរាចរណ៍ដល់ប្រជាពលរដ្ឋ បង្កើនការរៀបចំស្លាកសញ្ញាចរាចរណ៍ និងសណ្តាប់ធ្នាប់តាមដងផ្លូវ តាមទីក្រុង ទីប្រជុំជននានា ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ហើយធានាសុវត្ថិភាពក្នុងការធ្វើដំណើរ ។

**ទី៥៖** ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមផ្តល់ការណែនាំដល់រដ្ឋមន្ត្រីនៃក្រសួងស្ថាប័ននានា ត្រូវពង្រឹងការចូលរួមប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងយន្តការនានា ដែល រាជរដ្ឋាភិបាលបានបង្កើតឡើង ដើម្បីរួមគ្នាអនុវត្តប្រកប ដោយប្រសិទ្ធភាព នូវផែនការសកម្មភាព នៃយុទ្ធសាស្ត្រជាតិ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទាន ភេរវកម្ម និងផែនការសកម្មភាពនានា ដែលក្រុមការងារត្រួតពិនិត្យ រួមគ្នានៃប្រទេសអាស៊ី-ប៉ាស៊ីហ្វិក បានដាក់ចេញសំដៅការពារ កិត្តិយស កិត្យានុភាពជាតិ និងការចូលរួមរបស់កម្ពុជាក្នុងការរក្សាសន្តិសុខក្នុងតំបន់ និងអន្តរជាតិ ។

**ទី៦៖** ត្រូវបន្តបង្កើនការគ្រប់គ្រងការចេញចូលប្រទេស ទប់ស្កាត់ជនបរទេសចេញចូលស្នាក់នៅខុសច្បាប់ អំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងកាត់ព្រំដែនគ្រប់ប្រភេទ និង បន្តពង្រឹងយន្តការគ្រប់គ្រងវត្តមានជនបរទេសខុសច្បាប់ក្នុងប្រទេស ដែលបានប្រព្រឹត្តបទល្មើសនានា ដើម្បីចាត់វិធានការតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា ។

**ទី៧៖** ផ្អែកលើការវាយតម្លៃសមិទ្ធផលអនុវត្ត "គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព" ដែលបានអនុវត្តក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមក រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវគោលនយោបាយភូមិ ឃុំ សង្កាត់មាន សុវត្ថិភាពថ្មី ដោយពង្រីកវិសាលភាពផ្តល់សេវាសាធារណៈ ជាពិសេសការផ្តល់សេវារដ្ឋបាលប្រកបដោយតម្លាភាព និង ការជឿទុកចិត្ត ការរៀបចំប្រព័ន្ធសម្របសម្រួលដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ ការលើកកម្ពស់ការថែរក្សាការពារបរិស្ថាន អនាម័យ សោភ័ណភាពនៅតាមមូលដ្ឋាន ព្រមទាំងការរៀបចំ និងពង្រឹងប្រព័ន្ធ

គ្រប់គ្រងឆ្លើយតបគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតនានា រួមទាំងជំងឺកូវីដ-១៩ ។ ដូច្នេះ ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវប្រូសរាន់រៀបចំដាក់ចេញនូវគោលការណ៍ និងវិធានការនានាដើម្បីអនុវត្ត រួមទាំងការដាក់ចេញនូវចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព សំដៅលើកកម្ពស់ការចូលរួមពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ដើម្បីភាពសុខដុម-រមនា និងគុណភាពជីវិតប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ។

**ទី៨៖** ឆ្នាំ ២០២២ នេះ ជាឆ្នាំដំបូងដែលត្រូវអនុវត្ត ផែនការ ៥ ឆ្នាំ នៃកម្មវិធីជាតិកែទម្រង់វិមជ្ឈការ និងវិសហ-មជ្ឈការ ដំណាក់កាលទី ២ ដូច្នេះដើម្បីបន្តជំរុញដំណើរការកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យសម្រេចបានតាមគោលដៅ ក្រសួងស្ថាប័ននានា រដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ ត្រូវបន្តចូលរួមរៀបចំផែនការសកម្មភាព និង ថវិកាប្រចាំឆ្នាំ ដើម្បីអនុវត្តការកែទម្រង់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។ ក្នុងនោះ គណៈកម្មាធិការជាតិសម្រាប់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសហការសម្របសម្រួលជាមួយក្រសួងស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ធ្វើការសិក្សាវាយតម្លៃឡើងវិញអំពីដំណើរការនៃការផ្ទេរមុខងារ និងធនធាន ដែលបានអនុវត្តកន្លងមក ហើយ ត្រូវបន្តវាយតម្លៃអំពីសមត្ថភាព និងស្មារតីទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តមុខងារ និង ធនធានដែលបានផ្ទេរ សំដៅបន្តលើកកម្ពស់ភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព ។

**ទី៩៖** ត្រូវបន្តខិតខំរួមគ្នាអនុវត្តវិធានការនានារបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដោយបន្តជំរុញការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដែលជាវិធានការ គន្លឹះ ភ្ជាប់ជាមួយការអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការ "៣កុំ ៣ ការពារ" ឱ្យបានជាប់ជាប្រចាំ ព្រមទាំងប្រកាន់យករបៀបរស់នៅ និងបំពេញការងារជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ។

សម្តេចតេជោ ហ៊ុន សែន ក៏បានលើកទឹកចិត្តដល់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានគ្រប់ថ្នាក់ ត្រូវបង្កើនសកម្មភាពចុះជួយតាមមូលដ្ឋានរៀងៗខ្លួន ហើយត្រូវចូលរួមដោះស្រាយបញ្ហាប្រឈមនានា និងជំរុញការអភិវឌ្ឍមូលដ្ឋានឱ្យបានផុលផុស ដើម្បីជីវភាពប្រជាជនកាន់តែមានភាពល្អប្រសើរឡើង។ សម្តេចបានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ កងកម្លាំងនគរបាល-ជាតិ មន្ត្រីរដ្ឋបាលស៊ីវិល មន្ត្រីពន្ធនាគារ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានខិតខំពុះពារប្រឹងប្រែងសម្រេចបាននូវសមិទ្ធផលការងារគួរជាទីមោទនៈកាលពីឆ្នាំ ២០២១ កន្លងមក ។ សម្តេចមានសុទិដ្ឋិនិយមចំពោះសមិទ្ធផល និងការប្តេជ្ញាចិត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់ក្រសួងមហាផ្ទៃ ដើម្បីសម្រេចបាននូវទិសដៅការងារឆ្នាំ ២០២២៕

## រដ្ឋមន្ត្រីមហាផ្ទៃថា ការបង្ក្រាបបទល្មើសនានាមានកម្រិតខ្ពស់ទទួលបានលទ្ធផលដល់ ៩៣%

https://www.postkhmer.com/ ឡាយ សាមាន | Publication date 23 February 2022 | 09:51 ICT

**ភ្នំពេញៈ** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង បញ្ជាក់ថា ការបង្ក្រាបបទល្មើសនានាមានកម្រិតខ្ពស់ដោយទទួលបានលទ្ធផលរហូតដល់ ៩៣ ភាគរយ ដែលជាលទ្ធផលល្អប្រសើរ ដោយលោកបន្តជំរុញស្ថាប័នមានសមត្ថកិច្ចខិតខំបន្ថែមទៀតស្របពេលមានវិបត្តិសកលដែលនឹងជះឥទ្ធិពលដល់កម្ពុជា។

ក្នុងពិធីបើកសន្និបាតត្រួតពិនិត្យ លទ្ធផលការងារប្រចាំឆ្នាំ ២០២១ និងលើកទិសដៅការងារឆ្នាំ ២០២២ របស់ក្រសួងមហាផ្ទៃ និងលទ្ធផល ការងារប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ ឃុំ-សង្កាត់ មានសុវត្ថិភាព» នាថ្ងៃទី ២២ កុម្ភៈ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីមហាផ្ទៃ លោក ស ខេង បានធ្វើការកត់សម្គាល់នូវសភាពការណ៍ និងសមិទ្ធផលសំខាន់ៗ ដែលក្រសួងមហាផ្ទៃខិតខំសម្រេចបានក្នុងឆ្នាំ ២០២១ ទាំងសភាពការណ៍ពិភពលោក និងក្នុងតំបន់បានបន្តវិវឌ្ឍប្រែប្រួលឆាប់រហ័សស្មុគស្មាញ និងពិបាកប៉ាន់ស្មានស្របពេលដែលបញ្ហាប្រឈមធំៗមួយចំនួននៅសេសសល់ពុំទាន់មានវិធីដោះស្រាយនៅឡើយ។ លោកថា ទន្ទឹមនោះការប្រកួតប្រជែងក្នុង

ចំណោមប្រទេសមហាអំណាច ដើម្បីដណ្តើមភូមិសាស្ត្រនយោបាយ យោធា សេដ្ឋកិច្ច បច្ចេកវិទ្យា មានលក្ខណៈតានតឹង។ ដើម្បីបម្រើឱ្យសកម្មភាពប្រកួតប្រជែងដ៏ស្រួចស្រាល់ខាងលើនេះ មហាអំណាចមួយចំនួនបានបង្កើនសកម្មភាព ជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋតូចៗនិងក្រីក្រ ដើម្បីបម្រើផលប្រយោជន៍របស់ខ្លួន។ ស្របពេលទទួលរងសម្ពាធពីសភាពការណ៍សកលទាំងនេះ នៅផ្ទៃក្នុងកម្ពុជា ក្រុមប្រឆាំងជ្រុលនិយម និងមជ្ឈដ្ឋានអគតិ ក្នុងនិងក្រៅប្រទេសបានបន្ត ខិតខំរកឧបាយកល និងសកម្មភាពខុសច្បាប់ ប៉ុនប៉ងផ្តួលរំលំរដ្ឋាភិបាលក្នុងគោលបំណងដណ្តើមអំណាច ដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរមកលើរដ្ឋធម្មនុញ្ញ។

លោកថា ទោះបីសភាពការណ៍សកលលោក និងតំបន់មានការវិវឌ្ឍប្រែប្រួលស្មុគស្មាញយ៉ាងណាក្តី ប៉ុន្តែក្រោមការដឹកនាំរបស់រដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ក្នុងការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ដោយបញ្ចៀសបានអំពើភេរវកម្ម ព្រមទាំងបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលានូវឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ និងធានារក្សាបានសន្តិសុខក្នុងប្រទេសល្អប្រសើរ។ ក្នុងន័យនេះ លោកថា ក្នុងឆ្នាំ ២០២១ កងកម្លាំងនគរបាលជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បានខិតខំពុះពារកែពុនការងារជាច្រើន ប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការរក្សាសន្តិសុខសណ្តាប់ធ្នាប់សង្គម។ លោកបញ្ជាក់ថា៖ «អាស្រ័យលើកិច្ចខិតខំប្រឹងប្រែងទាំងនេះបានធ្វើឱ្យបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ មានការថយចុះ ៦ ភាគរយ។ ពិសេសបទល្មើសឧក្រិដ្ឋ ដែលជះឥទ្ធិពលដល់ចិត្តសាស្ត្រសង្គមបានថយចុះ ១៤ ភាគរយ ហើយលទ្ធផលនៃការបង្ក្រាបបទល្មើសនានាមានកម្រិតខ្ពស់រហូតដល់ ៩៣%»។ លោកបន្តថា ទន្ទឹមនឹងនេះយុទ្ធនាការប្រឆាំងបទល្មើសនានាក៏ត្រូវបានចាត់ចែងអនុវត្តជាប្រចាំ ទោះបីត្រូវរំខានខ្លះៗពីការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ យ៉ាងណាក្តី ដូចជាយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ សកម្មភាពប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងផ្លូវភេទ ការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយបទល្មើសសេដ្ឋកិច្ច និងបទល្មើសផ្សេងៗទៀត។ ទន្ទឹមនឹងសមិទ្ធផលខាងលើនេះនៅមានបញ្ហាសេសសល់បញ្ហាប្រឈមនានា ដែលត្រូវបន្តខិតខំពុះពាររួមគ្នាដោះស្រាយ។ លោកឧបនាយករដ្ឋមន្ត្រីបន្តថា៖ «បទល្មើសព្រហ្មទណ្ឌទោះបីឆ្នាំកន្លងទៅមានការថមថយ ប៉ុន្តែបទល្មើសមួយចំនួនមានចំនួនច្រើនគួរឱ្យកត់សម្គាល់។ មនុស្សឃាតដោយចេតនា អំពើហិង្សាដោយចេតនា អំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ និងការបំពានខាងផ្លូវភេទ»។ ក្នុងនាមក្រសួងមហាផ្ទៃ និងរូបលោកផ្ទាល់ លោក ស ខេង សំណូមពរដល់សមាជិក សមាជិកានៃអង្គសន្និបាតទាំងមូលប្តេជ្ញាស្មារតី ដើម្បីផ្តល់ធាតុចូលធ្វើការងារឱ្យ សម្រេចបានតាមការគ្រោងទុក។

លោក ប៉ោ ភក្តិ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃថ្លែងថា ក្នុងឆ្នាំ ២០២១ កើតឡើងនូវសភាពការណ៍គួរឱ្យកត់សម្គាល់ដែលបង្កឡើងនូវហានិភ័យដល់សន្តិសុខជាតិ និងអន្តរជាតិ។ ការរីករាលដាលជំងឺកូវីដ ១៩ អំពើភេរវកម្ម-អន្តរជាតិ ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ។ ជាពិសេសទៀតនោះ បទល្មើសបច្ចេកវិទ្យា និងមានការកើនឡើងការផលិត និងចរាចរគ្រឿងញៀន ព្រមទាំងអំពើជួញដូរមនុស្ស បាននិងកំពុងរីករាលដាលក្នុងតំបន់។ លោកបានបញ្ជាក់ថា ក្នុងកិច្ចការងារ ថែរក្សាសន្តិសុខជាតិបានកើតមាននូវព្រឹត្តិការណ៍គួរឱ្យកត់សម្គាល់មួយចំនួន មានដូចជា សកម្មភាព បាតុកម្ម កូដកម្មគ្រប់រូបភាពបានថយចុះ ៨៥៨ លើក ហើយត្រូវបានសម្របសម្រួល និងដោះស្រាយ ដោយសន្តិវិធី ដែលបញ្ចៀសបាននូវបាតុភាពបង្កចលាចលក្នុងសង្គម។ ក្នុងនោះកម្លាំងសមត្ថកិច្ច ក៏បានទប់ស្កាត់ចលនាបដិវត្តន៍ពណ៌ ប្រកបដោយប្រសិទ្ធភាពរាល់ព័ត៌មានប្រឌិត បំភ្លៃសភាពការណ៍ និងបំពុលបរិយាកាសសង្គមត្រូវបានស្រាវជ្រាវ និងប្រតិកម្មបកស្រាយបំភ្លឺទាន់ពេលវេលា។

លោកថា៖ «បទល្មើសព្រហ្មទណ្ឌគិតជាលើក ទូទាំងប្រទេសក្នុងឆ្នាំ ២០២១ ធៀបនឹងឆ្នាំ ២០២០ បទល្មើសរួមថយចុះ ១៩៩ លើក បទឧក្រិដ្ឋថយចុះ ៩៣ លើក បទមជ្ឈិមថយ ១០៦ លើក ស្លាប់ថយចុះ ១៥ លើក របួសថយចុះ ៤៩ លើក»។ ស្ថិតិបទល្មើសគិតជាលើកក្នុងក្របខ័ណ្ឌទូទាំងប្រទេសក្នុងឆ្នាំ ២០២១ បទល្មើសរួម

ថយចុះ ៩៣ លើក លួចមានស្ថានទម្ងន់ថយចុះ ៤២ លើក ឃាតកម្មថយចុះ ១៥ លើក រំលោភសេពសន្ថវៈថយចុះ ៣ លើក បង្ខាំងមនុស្សខុសច្បាប់ថយចុះ ២៣ លើក។ ស្ថិតិបទល្មើសមជ្ឈិមថយចុះ ១០៦ លើក បទល្មើសលួចថយចុះ ៦៨ លើក ឆបោករំលោភទំនុកចិត្ត ថយចុះ ១១ លើក ហិង្សាដោយចេតនាកើនឡើង ៦ លើក បំពានផ្លូវភេទថយចុះ ១ លើក ប្រើប្រាស់អាវុធខុសច្បាប់ថយចុះ ៣ លើក។ លោកបន្តថា លទ្ធផលបង្ក្រាបបទល្មើសព្រហ្មទណ្ឌទូទាំងប្រទេស ឆ្នាំ ២០២១ បទល្មើសសរុបភាគរយនៃការបង្ក្រាបស្មើ ៩៣ ភាគរយ បទល្មើសឧក្រិដ្ឋភាគរយបង្ក្រាប ៩២ ភាគរយ និងមជ្ឈិម ៩៤ ភាគរយ។ បើប្រៀបធៀបការបង្ក្រាបបទល្មើសព្រហ្មទណ្ឌនៃការបង្ក្រាប ៥ ឆ្នាំ ពីឆ្នាំ ២០១៧ ដល់ ២០២១ ក្នុងនោះឆ្នាំ ២០១៧ បង្ក្រាបបាន ៨៦ ភាគរយ និងឆ្នាំ ២០២១ បង្ក្រាប ៩៣ ភាគរយ ។ គ្រោះថ្នាក់ចរាចរណ៍ មាន ២ ៦៥៤ លើក ស្លាប់ ១ ៤៨៥ នាក់ របួស ៣ ៥៩៧ នាក់ អគ្គិភ័យ ៦៧០ លើក ស្លាប់ ១៨ នាក់ របួស ៣៥ នាក់ ឆេះផ្ទះ ៤៧២ ខ្នង ឆេះតូប ២៣១ តូប ករណីផ្ទុះអាវុធកើតឡើង ៣១ លើក ស្លាប់ ៩ នាក់ របួស ៣០ នាក់ និងគ្រោះថ្នាក់ផ្សេងៗ ៣ ៩៩២ លើក ស្លាប់ ៣ ៥៧១ នាក់ របួស ៥៤២ នាក់។ នេះបើតាមលោក ប៉ោ ភក្តិ។

លោកបញ្ជាក់ថាថ្វីបើសម្រេចបានសមិទ្ធផលគួរជាទីមោទនៈយ៉ាងណាក្តី ប៉ុន្តែសភាពការណ៍កម្ពុជានៅពេលខាងមុខនឹងប្រឈម បញ្ហាមួយចំនួនដោយសារការប្រែប្រួល និងភាពស្មុគស្មាញសន្តិសុខសកលលោក។ ក្រសួងមហាផ្ទៃដាក់ចេញយុទ្ធសាស្ត្រជាច្រើនដើម្បីបន្តរក្សាឱ្យបានឯករាជភាពទឹកដី សន្តិភាព និងស្ថិរភាពនយោបាយ សន្តិសុខសាធារណៈ បង្កបរិយាកាសក្នុងការស្តារកំណើន សេដ្ឋកិច្ច ជានា ការពារលើកស្ទួយសិទ្ធិសេរីភាព លើកកម្ពស់ប្រជាធិបតេយ្យសេរីពហុបក្ស៕

## ថៃចាប់ពលករខ្មែរ៨នាក់ ចោទឆ្លងដែនខុសច្បាប់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២២ ខែ កុម្ភៈ ឆ្នាំ ២០២២ ម៉ោង ០៩:១២

បន្ទាយមានជ័យ ៖ ពលករចំនួន៨នាក់ត្រូវទាហានថៃចាប់ខ្លួន កាលពីយប់ថ្ងៃទី២១ កុម្ភៈ ២០២២ នៅឃុំ និងស្រុកអារញ្ញ ខេត្តស្រះកែវចោទលួចឆ្លងដែនខុសច្បាប់ ។ ពលករទាំង៨នាក់ខាងលើនេះ គេមិនទាន់ស្គាល់អត្តសញ្ញាណនៅឡើយទេ ដែលក្នុងនោះមានស្រី៣នាក់ នេះបើយោងតាមការផ្សាយរបស់គេហទំព័រ និងកាសែតថៃ ។ យោងតាមការសាកសួរ ក្រុមពលករទាំង៨នាក់ ប្រាប់សមត្ថកិច្ចថៃថា ពួកគេគ្មានអ្នកនាំផ្លូវ និងមិនបានចំណាយប្រាក់នោះដែរ គឺនាំគ្នាដើរចូលទៅដីថៃ ដោយខ្លួនឯងគ្រោងទៅរកការងារធ្វើផ្នែកសំណង់នៅក្រុងបាងកក ។ ពលករទាំងនេះ ត្រូវខាងទាហានថៃកងរយ១៣០២ប្រគល់ឲ្យផ្នែកជំនាញស្រុកខ្លងលឹក មុនបញ្ជូនមកកម្ពុជាវិញ ។ ករណីឆ្លងដែនខុសច្បាប់ បែបប្រថុយប្រថាននេះមិនគួរកើតមាននោះទេ ព្រោះពេលជួបបញ្ហាជាយថាហេតុណាមួយលើទឹកដីគេគ្មានអ្នកទទួលខុសត្រូវឡើយ ។ ជាក់ស្តែងដូចករណីរថយន្តតូចបុកគូថរថយន្តធំស្លា.ប់របួសពលករខ្មែរ៧នាក់ នៅខេត្តប្រាជីនបូរី កាលពីយប់ថ្ងៃទី២០ ម្សិលមិញជាដើម ៕

## អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋ ដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 22/02/2022 Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង១៩និង២០នាទី នាថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក

ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០២នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១៩នាក់ ស្រី០៧នាក់, ក្មេង០២នាក់ (ស្រីម្នាក់)។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីត្រួតពិនិត្យសម្ភារៈហាមឃាត់ (ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក)។ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍ ជាលទ្ធផល គឺអវិជ្ជមាន។ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន១០នាក់ ស្រី០២នាក់ ក្មេងស្រី០១នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ) ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្ដែនអត់ចេញ ចំនួន០៩នាក់ ស្រី០៥នាក់ ក្មេងប្រុស០១នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## កងកម្លាំងអាជ្ញាធរ បន្តទទួលពលករ
## វិលត្រឡប់មកស្រុកវិញ ដែលភាគីថៃ បញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្រុកកំរៀង

https://gdlf-kh.com/ 2022/02/22/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃអង្គារ ៦ រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០២១២ ដោយអនុវត្តនតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងយោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យ ទៅទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។

ពលករដែលវិលត្រលប់មកកម្ពុជាវិញ សរុបចំនួន១២១នាក់, ស្រី៤១នាក់ និងក្មេង១២នាក់ បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩រួចរាល់ ក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័ស និងជាលទ្ធផល គឺវិជ្ជមានកូវីដ-១៩ ម្នាក់ (ប្រុស)។ ក្នុងនោះពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន៧៦នាក់ (ស្រី២៧នាក់, ក្មេង៧នាក់) ចំណែកពលករចំនួន៤៤នាក់, ស្រី១៤នាក់ និងក្មេង៥នាក់ ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ដោយបានចាក់វ៉ាក់សាំងអោយក្មេងចាប់ពីអាយុ ៥ឆ្នាំ ដល់ ១៨ឆ្នាំ ចំនួនម្នាក់ (ស្រី) ហើយក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ៕

## ២ ឆ្នាំ មានមេខ្យល់នាំពលករ
## ឆ្លងដែនខាង ៦០ នាក់ នៅស្រុកចំនួន ២ ត្រូវបានចាប់ និងឃុំខ្លួនក្នុងពន្ធនាគារ

https://www.postkhmer.com/national/ គឹម សារុំ | Publication date 22 February 2022 | 16:04 ICT

**បាត់ដំបង:** គិតចាប់ពីមានការផ្ទុះជំងឺកូវីដប្រមាណ ២ ឆ្នាំកន្លងមក មានមេខ្យល់ជាង ៦០ នាក់ ដែលបាននាំពលករឆ្លងដែនទៅថៃតាមច្រករបៀងក្នុងស្រុកសំពៅលូន និងស្រុកកំរៀងខេត្តបាត់ដំបង ត្រូវបានសមត្ថកិច្ចចាប់ខ្លួន និងត្រូវតុលាការឃុំខ្លួនក្នុងពន្ធនាគារខេត្ត រីឯនៅថ្ងៃទី ២១-២២ កុម្ភៈ ឆ្នាំនេះ មានពលករប្រុសស្រី ១៨២ នាក់ក្នុងស្រុកទាំង ២ខាងលើ បានវិលមកពីប្រទេសថៃវិញ។

លោក ម៉ង់ ស៊ី មេបញ្ជាការវរ ៨១៩ ប្រចាំការនៅតាមតំបន់ជាយដែនកម្ពុជា-ថៃក្នុងស្រុកកំរៀងបានឱ្យដឹងនៅថ្ងៃទី ២២ កុម្ភៈថា កាលពីថ្ងៃទី ២១ កុម្ភៈ សមត្ថកិច្ចរបស់លោកបានទទួលពលករប្រុសស្រីរួមទាំងកូនៗរបស់ពួកគេមកពីប្រទេសថៃ ចំនួន ១៣៤ នាក់ (ស្រី ៤៨ នាក់ បូករួមទាំងក្មេង ១៥ នាក់)។ ក្នុងនោះពលករ ៤៣ នាក់ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅស្រុកសំពៅលូន។ លោកបន្តថា ពលករទាំង ១៣៤ នាក់នេះ ត្រូវបានទាហានថៃបញ្ជូនមកតាមតាមច្រកតំបន់អូរអន្លក់ ស្ថិតនៅក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។ ពលករទាំងនោះមិនមែនធ្វើដំណើរគ្មានគោលដៅហើយត្រូវទាហានថៃចាប់ទេ តែពួកគាត់បានត្រឡប់មកប្រទេសវិញ តាមបំណងរបស់ពួកគាត់។ ចំពោះពលករខ្លះដែលត្រូវបានក្រុមគ្រូពេទ្យបញ្ជូនទៅធ្វើចត្តាឡីស័ក គឺដោយសារតែពួកគេមិនទាន់បានចាក់វ៉ាក់សាំងការពារជំងឺកូវីដ ពិសេសអ្នកទើបតែទៅដល់ប្រទេសថៃ ហើយគ្មានការងារធ្វើរួចក៏ត្រឡប់មកស្រុកកំណើតវិញ។

លោកបញ្ជាក់ថា៖ «ករណីនេះខាងសមត្ថកិច្ចយើងបានសហការល្អជាមួយភាគីថៃ ហើយថៃគាត់បញ្ជូនមកឱ្យយើង។ និយាយរួមទៅពួកគាត់ត្រឡប់មកវិញព្រោះអស់ការងារធ្វើនិងអ្នកខ្លះទៀតគាត់ទៅយូរឆ្នាំ និងចង់មកលេងក្រុមគ្រួសារ ឬក៏ក្រុមគ្រួសាររបស់ពួកគាត់មានរវល់ចាំបាច់»។ លោកបានបន្ថែមថា ចាប់ពីក្រោយឆ្នាំ ២០២០-២០២១ រហូតមកដល់ពេលនេះហាក់ដូចជាគ្មានមេខ្យល់លួចនាំពលករឆ្លងដែនទៅប្រទេសថៃទៀតទេ ព្រោះមេខ្យល់ប្រុសស្រីជាង ៤០ នាក់ ដែលសមត្ថកិច្ចរបស់លោកបានចាប់ខ្លួនអំឡុងពេលផ្ទុះជំងឺកូវីដខ្លាំងត្រូវបានបញ្ជូនទៅតុលាការខេត្តបាត់ដំបង ហើយត្រូវតុលាការឃុំខ្លួន។ហេតុដូច្នេះនៅពេលនេះសកម្មភាពរបស់មេខ្យល់នាំពលករទៅប្រទេសថៃ ហាក់ដូចជាស្ងប់ស្ងាត់ហើយ។

ដោយឡែក លោក ប្រាក់ សាយ មេបញ្ជាការវរ ៨១៧ ប្រចាំការនៅតាមតំបន់ជាយដែនកម្ពុជា-ថៃក្នុងស្រុកសំពៅលូនបានប្រាប់ ភ្នំពេញ ប៉ុស្តិ៍ នៅថ្ងៃទី ២២ កុម្ភៈថា ក្នុងរយៈពេល ២ ថ្ងៃ (២១-២២ កុម្ភៈ) មានពលករប្រុសស្រីចំនួន ៤៨ នាក់ (ស្រី ៧ នាក់ បូករួមក្មេង ២ នាក់ទៀត) បានវិលត្រឡប់មកពីប្រទេសថៃវិញ តាមប៉ុស្តិ៍គីឡូ១៣ ក្នុងភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន។ ក្នុងចំណោមនោះ មានពលករខ្លះត្រូវបានគ្រូពេទ្យតម្រូវឱ្យធ្វើចត្តាឡីស័កដោយសារតែអ្នកខ្លះបានចាក់វ៉ាក់សាំងមកពីប្រទេសថៃហើយ តែគាត់មានវិមានកូវីដ ១៩។ លោកបញ្ជាក់ថា៖ «ពលករដែលត្រឡប់មកវិញនោះអ្នកខ្លះក៏បានចាក់វ៉ាក់សាំងបាន ៣ ដង អ្នកខ្លះបាន ២ ដង និងខ្លះបានម្តងហើយបើគ្រូពេទ្យពិនិត្យឃើញមានវិជ្ជមានកូវីដទៀតនឹងបញ្ជូនទៅធ្វើចត្តាឡីស័ករយៈពេល ១៤ ថ្ងៃ»។ លោកបន្តថាចំពោះបទល្មើសពាក់ព័ន្ធនឹងមេខ្យល់លួចនាំពលករឆ្លងដែនទៅប្រទេសថៃវិញ ក៏មិនឃើញមានសកម្មភាពអីដែរ ហើយបើគិតក្នុងរយៈពេលជាង ២ ឆ្នាំ (២០២០-២០២១) មកនេះសមត្ថកិច្ចចាប់ខ្លួនមេខ្យល់បានប្រមាណជាង ២០ នាក់ហើយ៕

## ថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ២០២២

### សម្ដេចតេជោ ស្នើឲ្យមានអនុស្សរណៈ
### យោគយល់គ្នាចំនួន ២ សម្រាប់ការបញ្ជូនពលករខ្មែរ ទៅធ្វើការនៅម៉ាឡេស៊ី

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ២៤ កុម្ភៈ ២០២២ដោយ sopheak khoun

នៅក្នុងជំនួបទ្វេភាគីសម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា និងលោក ដាតុ ស្រ៊ី អ៊ីស្មាអែល សាប្រ៊ី ប៊ីន យ៉ាកុប នាយករដ្ឋមន្ត្រីម៉ាឡេស៊ី នៅព្រឹកថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០២២នេះ បានពិភាក្សាស៊ីជម្រៅ អំពីកិច្ចសហប្រតិបត្តិការលើនៅវិស័យជាច្រើន ក្នុងក្របខណ្ឌទ្វេភាគី។ ក្នុងនោះភាគីទាំងពីរ ក៏បានពិភាក្សាទៅដល់បញ្ហាបញ្ជូនពលករកម្ពុជាទៅធ្វើការនៅម៉ាឡេស៊ីផងដែរ។

នៅក្នុងជំនួបនោះ សម្ដេចតេជោនាយករដ្ឋមន្ត្រី បានស្នើឲ្យក្រសួងពាក់ព័ន្ធនៃប្រទេសទាំងពីរ ពិនិត្យរកលទ្ធភាពឲ្យមានកិច្ចព្រមព្រៀង អនុស្សរណៈ នៃការយោគយល់គ្នាចំនួន ២។ សម្ដេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា ចំពោះវិស័យការងារ សម្ដេចអរគុណរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធរបស់ម៉ាឡេស៊ី ដែលបានផ្ដល់កិច្ចសហប្រតិបត្តិការល្អ ជាមួយស្ថានទូតកម្ពុជានៅក្នុងប្រទេសម៉ាឡេស៊ី ក្នុងការយកចិត្តទុកដាក់ដល់សុខទុក្ខ របស់ពលករកម្ពុជា ដែលកំពុងធ្វើការនៅម៉ាឡេស៊ី ក៏ដូចជាការបញ្ជូនពលករខ្មែរ ដែលចូលទៅធ្វើការខុសច្បាប់ ក្នុងប្រទេសម៉ាឡេស៊ីត្រឡប់មកកម្ពុជាវិញ។ ពាក់ព័ន្ធបញ្ហានេះ សម្ដេចតេជោនាយករដ្ឋមន្ត្រី បានស្នើក្រសួងពាក់ព័ន្ធ នៃប្រទេសទាំងពីរពិនិត្យលទ្ធភាព ឲ្យមានកិច្ចព្រមព្រៀងអនុស្សរណៈចំនួន ២គឺ៖ ទី១. ការជ្រើសរើស ការប្រើប្រាស់ និងការធ្វើមាតុភូមិនិវត្តន៍ របស់ពលករទូទៅ។ ទី២.កា រជ្រើសរើស និងការប្រើប្រាស់ និងការធ្វើមាតុភូមិនិវត្តន៍ពលករធ្វើការងារតាមផ្ទះ ត្រូវជំនួសដោយកិច្ចព្រមព្រៀងអនុស្សារណៈ ដែលបានអស់សុពលភាពកាលពីឆ្នាំ ២០២០។

សម្ដេចតេជោនាយករដ្ឋមន្ត្រី បានឲ្យដឹងថា អម្បាញ់មិញសម្ដេច និងលោកនាយករដ្ឋមន្ត្រីម៉ាឡេស៊ី បានពិភាក្សាគ្នា អំពីចំណុចទីពីរទាក់ទង ជាមួយនឹងពលករធ្វើការតាមផ្ទះ ហើយដែលលោកនាយករដ្ឋមន្ត្រីម៉ាឡេស៊ី បាននិយាយយ៉ាងច្បាស់ជាមួយសម្ដេចពីការកែសម្រួល ហើយធានាថា នឹងមិនមានការរំលោភបំពានណាមួយនោះទេ ហើយសង្ឃឹមថាដោយសារតែនៅកម្ពុជា មានសហគមន៍ឥស្លាម ហើយដែលមានទំនៀមទំលាប់ប្រហាក់ប្រហែលជាមួយនិងម៉ាឡេស៊ី។ ដូច្នេះងាយស្រួល ក្នុងការយកទៅធ្វើនៅតាមគេហដ្ឋាន នៅឯប្រទេសម៉ាឡេស៊ីនេះជាចំណុចដែលសុំឲ្យក្រសួងការងារ និងផ្នែកពាក់ព័ន្ធយកចិត្តទុកដាក់ ដើម្បីនឹងចាប់ផ្ដើមឡើងវិញ និងដំណើរការនេះ៕ ណារី

### ពលករខ្មែរម្នាក់ក្នុងចំណោមពលករ
### ជាង១០០នាក់រកឃើញវិជ្ជមានជំងឺកូវីដ-១៩ ដែលថៃចាប់បញ្ជូនមកស្រុកកំណើត

http://nokorwatnews.com/ 23/02/2022

ខេត្តបាត់ដំបង៖ ក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័សរកឃើញពលករខ្មែរម្នាក់ មានផ្ទុកជំងឺកូវីដ-១៩ ក្នុងចំណោមពលករខ្មែរចំនួន ១២១នាក់ ដែលភាគីថៃចាប់បញ្ជូនមកកាន់ស្រុកកំណើតនាព្រឹកថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០២២ តាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។

លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានអោយដឹងថា ករណីរកឃើញវិជ្ជមានជំងឺកូវីដ-១៩លើបុរសម្នាក់ជាពលករខ្មែរនេះ បានកើតឡើងបន្ទាប់ពីកម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងយោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យទៅទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ហើយត្រូវបានក្រុមគ្រូពេទ្យធ្វើតេស្តរហ័សចេញជាលទ្ធផលភ្លាមៗតែម្តង។ ហើយបន្ទាប់ពីសាកសួរកត់ឈ្មោះ ចុះកំណត់ហេតុរួចឃើញថា ពលករខ្មែរទាំងអស់មានចំនួន ១២១នាក់ ស្រី៤១នាក់ និងក្មេង១២នាក់. ដែលក្នុងនោះពលករចំនួន ៤៤នាក់ ស្រី ១៤នាក់ និងក្មេង ៥នាក់ ត្រូវបាន

បញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន ដោយឡែកពលករដែលមានកាតចាក់វ៉ាក់សាំងចំនួន ៧៦នាក់.ស្រី២៧នាក់. និងក្មេង៧នាក់.ខាងក្រុមគ្រូពេទ្យអនុញ្ញាតឱ្យត្រឡប់ទៅស្រុកកំណើតវិញរៀងៗខ្លួន៕

## នៅយប់ថ្ងៃអង្គារ អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/02/23/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង២០និង២០នាទី នាថ្ងៃអង្គារ ៦រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្ដិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្ដិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០២នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន២១នាក់ (ស្រី០៧នាក់ ក្មេង០២នាក់ ក្មេងស្រី០១នាក់)។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីត្រួតពិនិត្យសម្ភារៈហាមឃាត់ (ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក)។ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្ដិ៍ ជាលទ្ធផល គឺអវិជ្ជមាន បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន១១នាក់ ស្រី០៣នាក់ ក្មេងប្រុស០១នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ)។ ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្ដែនអត់ចេញ ចំនួន១០នាក់ ស្រី០៤នាក់ ក្មេងស្រី០១នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## ក្នុងខែមករាពលករត្រឡប់ពីថៃមាន ៦ ៨៩១ នាក់ ក្នុងនោះរកឃើញវិជ្ជមានកូវីដ ៥៤ នាក់

https://www.postkhmer.com/ វី សុចាន់ | Publication date 23 February 2022 | 10:03 ICT

**ភ្នំពេញៈ** ក្នុងខែមករា ពលករចំណាកស្រុកកម្ពុជា ដែលបានវិលត្រឡប់ពីប្រទេសថៃ មានចំនួន ៦៨៩១ នាក់ ដែលក្នុងនោះត្រូវបានរកឃើញមានវិជ្ជមានកូវីដ ១៩ ចំនួន ៥៤ នាក់ និងដាក់ឱ្យស្ថិតក្នុងមណ្ឌលចត្តាឡីស័កមានចំនួន ៥៩៥ នាក់។ នេះបើតាមរបាយការណ៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍ប្រចាំកម្ពុជា (IOM)។ បើតាមរបាយការណ៍ប្រចាំត្រីមាស ដែលបានផ្សព្វផ្សាយនាថ្ងៃទី ២១ ខែកុម្ភៈ បានឱ្យដឹងថា ចាប់តាំងពីខែមីនា ឆ្នាំ ២០២០ ពលករចំណាកស្រុកកម្ពុជា ដែលបានវិលត្រឡប់ពីប្រទេសថៃមានចំនួនជាង ២៧ ម៉ឺននាក់។ IOM បានបញ្ជាក់ក្នុងរបាយការណ៍ថា អង្គការ IOM សហការជាមួយក្រសួងសុខាភិបាលបន្តសម្របសម្រួលការបង្កើតផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ សម្រាប់អនុវត្តគោលនយោបាយសុខភាពពលករចំណាកស្រុក ដើម្បីធានាបានការគាំពារសុខភាព និងសិទ្ធិស្មើៗគ្នាក្នុងការទទួលបានសេវាថែទាំសុខភាព សម្រាប់ពលករចំណាកស្រុក និងក្រុមគ្រួសាររបស់ពួកគេ។

លោកស្រី Kristin Parco ប្រធានបេសកកម្មអង្គការ IOM កម្ពុជាថ្លែងក្នុងរបាយការណ៍នេះថា អង្គការ IOM កោតសរសើរចំពោះការបន្តប្តេជ្ញាចិត្តរបស់ក្រសួងសុខាភិបាល ចំពោះសេចក្តីសម្រេចលេខ 70.15 ស្តីពីការលើកកម្ពស់សុខភាពជនភៀសខ្លួន និងជនចំណាកស្រុក ដែលអនុម័តក្នុងខែឧសភា ឆ្នាំ ២០១៧ ដោយអង្គការសុខភាពពិភពលោក។ លោកស្រីថ្លែងថា៖ «យើងសង្ឃឹមថា ការបង្កើតផែនការយុទ្ធសាស្ត្រថ្នាក់ជាតិសម្រាប់អនុវត្តគោលនយោបាយសុខភាពជនទេសន្តរប្រវេសន៍ឆ្នាំ ២០២១-២០៣០ នឹងលើកកម្ពស់ការទទួលបានការថែទាំសុខភាពប្រកបដោយសមធម៌ និងធ្វើឱ្យសុខភាពសហគមន៍ជនទេសន្តរប្រវេសន៍ប្រសើរឡើង»។ កាលពីខែវិច្ឆិកា អង្គការ IOM និងមូលនិធិសហប្រជាជាតិ សម្រាប់ប្រជាជន (UNFPA) បានចុះទៅកាន់ច្រកព្រំដែន និងមណ្ឌលចត្តាឡីស័ក ដែលសកម្មបំផុតមួយចំនួននៅក្នុងខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ និងបាត់ដំបង។

អង្គការ IOM និង UNFPA បានផ្តល់ឱ្យជនចំណាកស្រុកនូវស្បៀងអាហារ និងផ្គត់ផ្គង់សម្ភារអនាម័យជំងឺកូវីដ ១៩ នៅពេលពួកគេមកដល់ ហើយបានសហការជាមួយអាជ្ញាធរខេត្ត និងមន្ទីរសុខាភិបាលខេត្ត ដើម្បីធានាថាជនចំណាកស្រុកទាំងអស់ មានលទ្ធភាពទទួលបានវិធានការបង្ការជំងឺកូវីដ ១៩ ដើម្បីកាត់បន្ថយហានិភ័យនៃការរីករាលដាលជំងឺនេះចូលក្នុងសហគមន៍ទ្រង់ទ្រាយធំ។ ជាមួយគ្នានេះ អង្គការ IOM បានផ្តល់នូវកញ្ចប់អាហារចំនួន ២៥០០០ កញ្ចប់ និងឧបករណ៍ អនាម័យ កាលពីខែវិច្ឆិកា ឆ្នាំ ២០២១ ដល់ជនចំណាកស្រុកដែលវិលត្រឡប់មកពីថៃវិញក្នុងខេត្តឧត្តរមានជ័យ បន្ទាយមានជ័យ និងខេត្តបាត់ដំបងនៅច្រកព្រំដែន និងមណ្ឌលចត្តាឡីស័ក។ កាលពីខែធ្នូ ឆ្នាំ ២០២១ កញ្ចប់អាហារចំនួន ១១៣៦៥ កញ្ចប់បន្ថែមទៀត និងកញ្ចប់សម្ភារអនាម័យចំនួន ៤៣១០ កញ្ចប់ត្រូវបានផ្គត់ផ្គង់ទៅខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ និងបាត់ដំបង សម្រាប់ចែកដល់ជនចំណាកស្រុកដែលទើបវិលត្រឡប់មកវិញនៅច្រកព្រំដែន មណ្ឌលចត្តាឡីស័ក និងមណ្ឌលព្យាបាល។

អង្គការ IOM ដោយមានការគាំទ្រពីទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ (SDC) បានសហការជាមួយមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបងក្នុងការពន្លឿនកិច្ចខិតខំប្រឹងប្រែងចាក់វ៉ាក់សាំងកូវីដ ១៩ ដល់ជនចំណាកស្រុកត្រឡប់មកពីប្រទេសថៃ។ គោលបំណងរួម គឺដើម្បីធានាថា ពលករចំណាកស្រុកដែលវិលត្រឡប់មកវិញអាចទទួលបានវ៉ាក់សាំងកូវីដ ១៩ យ៉ាងហោចណាស់ដូសដំបូង មុនពេលត្រឡប់ទៅសហគមន៍របស់ពួកគេវិញ។ របាយការណ៍ពីខែវិច្ឆិកា ឆ្នាំ ២០២១ ដល់ខែមករា ២០២២ បានឱ្យដឹងថា អង្គការ IOM បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងវ៉ាក់សាំង និងការចាក់វ៉ាក់សាំងកូវីដ ១៩ ដល់បុគ្គលិកសុខាភិបាលចំនួន១១៨ នាក់នៅខេត្តបន្ទាយមានជ័យក្នុងគោលបំណងលើកកម្ពស់សមត្ថភាពបុគ្គលិកសុខាភិបាលលើវ៉ាក់សាំងកូវីដ ១៩ ការកត់ត្រាទិន្នន័យវ៉ាក់សាំង ការរាយការណ៍ និងការអប់រំសុខភាពស្តីពី វ៉ាក់សាំងកូវីដ ១៩៕

## **ខណៈដែលនាយករដ្ឋមន្ត្រី Sabri Yaakob មានប្រសាសន៍ថា ម៉ាឡេស៊ីនឹងពិនិត្យមើលការជួលកម្លាំងពលកម្មពីកម្ពុជា របាយការណ៍ស្តីពីការរំលោភបំពានស្ត្រីបម្រើការបានរារាំងការចុះ MoU ជាមួយកម្ពុជា**

https://www.khmertimeskh.com/ February 24, 2022

ការបញ្ចប់អនុស្សរណៈនៃការយោគយល់គ្នា (MoUs) ស្តីពីការជ្រើសរើសអ្នកបម្រើការងារតាមផ្ទះ រវាងប្រទេសម៉ាឡេស៊ី និងប្រទេសប្រភពយ៉ាងហោចណាស់មួយ ប្រទេសកម្ពុជាបានពន្យារពេល ដោយសារមានករណីរំលោភបំពានស្ត្រីបម្រើការងារតាមផ្ទះជាច្រើននៅក្នុងប្រទេសម៉ាឡេស៊ី។

រដ្ឋមន្ត្រីក្រសួងធនធានមនុស្ស M Saravanan ដែលបានបង្ហាញនៅថ្ងៃពុធនេះ បានមានប្រសាសន៍ថា ការធ្វើបាបអ្នកបម្រើការងារតាមផ្ទះ គឺជាហេតុផលចម្បង នៃការមិនបន្ត MoU ជាមួយកម្ពុជាចាប់តាំងពីឆ្នាំ២០១៦

ហើយការពន្យារពេលក្នុងការបញ្ចប់កិច្ចព្រមព្រៀងថ្មីមួយ ដែលនឹងចុះហត្ថលេខានៅខែកុម្ភៈ។ លោកបានមានប្រសាសន៍នៅក្នុងសេចក្តីថ្លែងការណ៍មួយកាលពីម្សិលមិញថា "ទោះបីជាករណីទាំងនេះជាឧប្បត្តិហេតុដាច់ដោយឡែកក៏ដោយ ពួកគេបានធ្វើឱ្យខូចមុខមាត់ និងកេរ្តិ៍ឈ្មោះរបស់ប្រទេស ហើយបានប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងក្នុងការបញ្ចប់ MoU ជាមួយប្រទេសកម្ពុជា ក៏ដូចជាប្រទេសឥណ្ឌូនេស៊ី" ។

ដោយមើលឃើញពីបញ្ហានេះ លោកបានព្រមានថា និយោជកដែលធ្វើខុសនឹងត្រូវបានដាក់ក្នុងបញ្ជីខ្មៅ ហើយនឹងមិនអនុញ្ញាតឱ្យជួលអ្នកបម្រើបរទេសទៀតទេនៅពេលអនាគត ដោយបន្ថែមថារដ្ឋាភិបាលនឹងមិនសម្របសម្រួលលើបញ្ហានេះឡើយ។ លោកបានមានប្រសាសន៍ថា "និយោជកដែលមិនបើកប្រាក់បៀវត្សរ៍ ឬទាញយកផលប្រយោជន៍ពីអ្នកបម្រើបរទេស នឹងត្រូវដាក់ក្នុងបញ្ជីខ្មៅ និងបញ្ឈប់ពីការជួលអ្នកបម្រើបរទេសនៅពេលអនាគត"។ លោក Saravanan បានមានប្រសាសន៍ថា បច្ចុប្បន្នមានស្ត្រីបម្រើបរទេសចំនួន ៨៦,០៨៤ នាក់ នៅក្នុងប្រទេសដែលភាគច្រើននៃពួកគេមកពីប្រទេសឥណ្ឌូនេស៊ី (៥៩,៦០៥) បន្ទាប់មកគឺហ្វីលីពីន (២២,៨០៣) វៀតណាម (១,០៣១) និងប្រទេសកម្ពុជា (៩៧៦) ក្នុងចំណោមអ្នកផ្សេងទៀត។ លោកក៏បានមានប្រសាសន៍ដែរថា មានពលករបរទេសចំនួន ១,១៥៧,៤៨១ នាក់ក្នុងប្រទេស។

នៅកម្ពុជា នាយករដ្ឋមន្ត្រីម៉ាឡេស៊ី លោក Dato' Sri Ismail Sabri bin Yaakob មានប្រសាសន៍ថា លោកនឹងពិចារណាណែនាំក្រសួងពាក់ព័ន្ធឱ្យពិចារណាជួលកម្លាំងពលកម្មកម្ពុជា ព្រោះសហគមន៍ចាម ឬឥស្លាមបានចែករំលែកវប្បធម៌ និងភាសាដូចគ្នាជាមួយម៉ាឡេស៊ី ហើយអាចសមស្របជាងសម្រាប់ប្រភេទការងារមួយចំនួន។ លោក Sabri Yaakob បានមានប្រសាសន៍កាលពីយប់មិញក្នុងពិធីជប់លៀងអាហារជុំគ្នាជាមួយអនិកជនម៉ាឡេស៊ីនៅកម្ពុជា បន្ទាប់ពីមកដល់ប្រទេសកម្ពុជាថា "យើងមានពលករបរទេសចំនួនពីរលាននាក់ ហើយយើងគួរតែមានពលករពីកម្ពុជាផងដែរ ដើម្បីបំពេញតម្រូវការពលករបរទេស"។

## ពលករខ្មែរចំនួន៣០០នាក់
## បានមកដល់ប្រទេសថៃក្រោមអនុស្សរណៈយោគយល់គ្នាជាមួយកម្ពុជា

https://www.khmertimeskh.com/ Khmer Times February 24, 2022

ក្នុងចំណោមសំណើចំនួន ១,៨១៣ ដោយក្រុមហ៊ុនអាជីវកម្ម ដើម្បីនាំយកពលករចំណាកស្រុកចំនួន ១១៣,៧១៧ នាក់ តាមរយៈ MoUs ជាមួយប្រទេសជិតខាងនោះ ប្រទេសថៃមកដល់ពេលនេះ មានតែពលករពីកម្ពុជាប្រមាណ ៣០០ នាក់ប៉ុណ្ណោះ ដែលបានមកដល់ និងធ្វើការក្រោមកិច្ចព្រមព្រៀងនោះ។

រដ្ឋមន្ត្រីក្រសួងការងារថៃ លោក Suchart Chomklin មានប្រសាសន៍ថា រហូតមកដល់ពេលនេះ ការនាំចូលកម្លាំងពលកម្មតាមរយៈអនុស្សរណៈនៃការយោគយល់គ្នា (MoU) ដែលបានចុះហត្ថលេខាជាមួយប្រទេសជិតខាង បានខកខានគោលដៅរបស់ពួកគេ ខណៈការលើកឡើងពីជោគជ័យ តូចមួយដែលទទួលបានពីពលករកម្ពុជាក្នុងការធានាការងារនៅក្នុងក្រុមហ៊ុនថៃ។ នេះកើតឡើងបន្ទាប់ពីអាជីវកម្មអំពាវនាវដល់ក្រសួងការងារឲ្យកាត់បន្ថយការចំណាយដែលពាក់ព័ន្ធនឹងការនាំចូលពលករចំណាកស្រុក និងជួយដោះស្រាយកង្វះកម្លាំងពលកម្ម។ ម្ចាស់អាជីវកម្មជាច្រើនបានស្វែងរកការជ្រើសរើសពលករចំណាកស្រុកពីប្រទេសមីយ៉ាន់ម៉ាតាមរយៈMoU។ ទោះជាយ៉ាងណាក៏ដោយ ភាពចលាចលដែលកំពុងបន្តបាន រារាំងដល់ដំណើរជ្រើសរើសពលករចំណាកស្រុក។ រដ្ឋមន្ត្រីបានមានប្រសាសន៍ថា ប្រតិបត្តិករអាជីវកម្មមានការព្រួយបារម្ភថា ប្រសិនបើមិនមានពលករគ្រប់គ្រាន់ត្រូវបាននាំចូលទាន់ពេលវេលាទេ អាជីវកម្មរបស់ពួកគេនឹងមិនអាចបំពេញតាមការបញ្ជាទិញ និងប្រឈមនឹងការផាកពិន័យជាបន្តបន្ទាប់។

លោកនាយករដ្ឋមន្ត្រីប្រាយុទ្ធ ចាន់អូចា មានការព្រួយបារម្ភ ជាពិសេសចំពោះវិស័យសំណង់ដែលពឹងផ្អែកខ្លាំងលើពលករចំណាកស្រុក។ ក្រុមហ៊ុនឯកជនបានជំរុញឱ្យក្រសួងស្វែងរកមធ្យោបាយផ្សេងទៀត ដើម្បីធ្វើវិសោធនកម្មបទប្បញ្ញត្តិគ្រប់គ្រងការនាំចូលកម្លាំងពលកម្មពីបរទេស ដើម្បីកាត់បន្ថយការចំណាយ ឧទាហរណ៍ កាត់បន្ថយការចំណាយទាក់ទងនឹងការពិនិត្យសុខភាព និងការធ្វើចត្តាឡីស័ក។

លោក Suchart បានមានប្រសាសន៍ថា លោកបានណែនាំលោក Pairoj Chotikasathien អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ឱ្យពិគ្រោះជាមួយមជ្ឈមណ្ឌលគ្រប់គ្រងស្ថានការណ៍កូវីដ-១៩ អំពីវិធីកាត់បន្ថយការចំណាយទាក់ទងនឹងការនាំចូលកម្លាំងពលកម្ម។ ការកាត់បន្ថយអាចសម្រេចបានដោយការកាត់រយៈពេលចត្តាឡីស័ក និងបន្ធូរបន្ថយនីតិវិធីធ្វើតេស្តដោយមិនប៉ះពាល់ដល់សុវត្ថិភាពសុខភាពសាធារណៈ។ ថ្មីៗនេះលោក Suchart បានជួបពិភាក្សាក្រៅផ្លូវការជាមួយទីភ្នាក់ងារឯកជន និងរដ្ឋ ដើម្បីដោះស្រាយកង្វះកម្លាំងពលកម្ម។ ទីភ្នាក់ងារទាំងនោះរួមមាន សហព័ន្ធឧស្សាហកម្មថៃ (FTI) សភាពាណិជ្ជកម្មថៃ សមាគមអ្នកម៉ៅការថៃ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាលសាធារណៈ ការិយាល័យអន្តោប្រវេសន៍ (IB) និងនាយកដ្ឋានរដ្ឋបាលខេត្ត។

ក្រសួងការងារបានយល់ព្រមគាំទ្រការនាំពលករចំណាកស្រុកនៅក្នុងខេត្តជាប់ព្រំដែនចំនួនប្រាំបួន ដោយចាប់ផ្តើមពីខេត្តច័ន្ទបុរី។ ក្រោមការរៀបចំនេះ ពលករអាចឆ្លងចូលប្រទេសថៃដើម្បីធ្វើការ និងត្រឡប់មកផ្ទះវិញនៅពេលបញ្ចប់ថ្ងៃធ្វើការនីមួយៗ។ ខេត្តចំនួនប្រាំ រួមទាំងខេត្តច័ន្ទបុរី មានព្រំប្រទល់ជាប់នឹងប្រទេសកម្ពុជា និងខេត្តផ្សេងទៀតជាប់ព្រំប្រទល់ជាមួយប្រទេសមីយ៉ាន់ម៉ា។ លោក Suchart Chantaranakaracha អនុប្រធាន FTI ទទួលបន្ទុកកិច្ចការការងារបានមានប្រសាសន៍ថា កង្វះកម្លាំងពលកម្មបានក្លាយទៅជារឿងសំខាន់ ដោយមានការប៉ាន់ប្រមាណថាមានឱនភាពចំនួនកន្លះលាន ដូច្នេះការបន្ធូរបន្ថយបទប្បញ្ញត្តិដើម្បីបង្វែរស្ថានការណ៍ គឺជារឿងសំខាន់បំផុត។ លោកបានស្នើដល់រដ្ឋមន្ត្រីក្រសួងការងារជួបសមភាគីនៃប្រទេសជិតខាង ដើម្បីទាក់ទាញពួកគេពីភាពបន្ទាន់ក្នុងការផ្គត់ផ្គង់ពលករ និងពិភាក្សាអំពីការផ្តល់ភាពស្របច្បាប់ដល់កម្មករដែលមិនមានឯកសារហើយបានមកដល់ក្នុងប្រទេស ដើម្បីជួយដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្ម។ លោក Suchart បានបន្ថែមថា ការិយាល័យអន្តោប្រវេសន៍ ក៏គួរតែកាត់បន្ថយថ្លៃទិដ្ឋាការពី ២,០០០ ទៅ ៥០០ បាត ក្នុងមនុស្សម្នាក់ ខណៈដែលពលករចំណាកស្រុកដែលបានចាក់វ៉ាក់សាំង គួរតែធ្វើចត្តាឡីស័កខ្លីជាងមុននៅក្នុងប្រទេសថៃ៕ Bangkokpost

## អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋ ដែលវិលត្រឡប់ពីប្រទេសថៃ គ្រប់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/02/23/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០២នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បាន

ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង សរុបចំនួន៤៦នាក់ (ស្រី២០នាក់ ក្មេង០៤នាក់ ក្មេងស្រី០៣នាក់)។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីត្រួតពិនិត្យសម្ភារៈហាមឃាត់ (ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក) ដោយដកហូតបានកាំបិត០២ដើម, ដង្កាប់០១ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យ នៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺវិជ្ជមានចំនួន០២នាក់ ស្រី០១នាក់។ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន២៨នាក់ ស្រី១៦នាក់ ក្មេងស្រី០១នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ)។ ចំណែកអ្នកមានវិជ្ជមានកូវីដ-១៩ ចំនួន០២នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលព្យាបាលកូវីដ-១៩ ស្ថិតនៅក្នុងភូមិអូរកណ្តោល ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង និងអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្ទើនអត់ចេញ ចំនួន១៦នាក់ ស្រី០៣នាក់ ក្មេង០៣នាក់ ក្មេងស្រី០២នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្ហា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## ថ្ងៃទី២៨ ខែ កុម្ភៈ ឆ្នាំ២០២២

### កុមារ និងយុវជនជាច្រើន
### បន្តចូលរួមយុទ្ធនាការគាំទ្រទិវាអន្តរជាតិ ដើម្បីសុវត្ថិភាពអ៊ីនធឺណិតសកល

http://freshnewsasia.com/ 2022-02-25 02:44pm

**(ភ្នំពេញ)៖** អង្គការសកម្មភាពដើម្បីកុមារ (APLE) គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NCCT) ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) និងសាលាប៊ែលធីអន្តរជាតិ (BELTEI International School) នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២នេះ បានសហការគ្នា រៀបចំធ្វើយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាព អ៊ីនធឺណិតឆ្នាំ២០២២ តាមប្រព័ន្ធ Zoom។

យុទ្ធនាការនេះបានធ្វើឡើងក្រោមអធិបតីភាពរបស់ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងមានអ្នកចូលរួមជាកុមារ យុវជន លោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងសាលាប៊ែលធីអន្តរជាតិចំនួន ២៥០នាក់។

សូមបញ្ជាក់ថា កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ យុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២២ ក៏ត្រូវបានធ្វើឡើង ដោយអង្គការសកម្មភាពដើម្បីកុមារ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងសាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ ហើយមានការឧបត្ថម្ភពីអង្គការភ្លែនអន្តរជាតិកម្ពុជា អង្គការយូនីសេហ្វប្រចាំកម្ពុជា ក្រុមហ៊ុន Smart Axiata មូលនិធិ World Childhood មូលនិធិ Bread for the World និងគណៈកម្មាធិការសុវត្ថិភាពអ៊ីនធើណិត ដែលមានអ្នកចូលរួម ៣៨៨នាក់ រួមមាន កុមារ យុវជន មន្ត្រីរាជរដ្ឋាភិបាល គ្រូបង្រៀន បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងប្រតិបត្តិករអ៊ីនធឺណិត។

យុទ្ធនាការនេះមានគោលបំណង លើកកម្ពស់ការយល់ដឹងយ៉ាងទូលំទូលាយ អំពីសុវត្ថិភាពអ៊ីនធឺណិត ជាពិសេស លើកកម្ពស់ការចូលរួមធ្វើឱ្យបច្ចេកវិទ្យាអ៊ីនធឺណិត កាន់តែមានសុវត្ថិភាពសម្រាប់កុមារ និងការប្រើប្រាស់ប្រកបដោយការទទួលខុសត្រូវ សេចក្តីគោរព ការគិតពិចារណា និងភាពច្នៃប្រឌិត ព្រមទាំងដើម្បីផ្សព្វផ្សាយ ទៅដល់ កុមារ និងយុវជនវ័យក្មេង ឪពុកម្តាយ និងអ្នកថែទាំកុមារ គ្រូបង្រៀន អ្នកអប់រំ បុគ្គលិកសង្គម ក្រុមហ៊ុនអ៊ីនធឺ

ណិត អ្នកធ្វើការសម្រេចចិត្ត និងអ្នកនយោបាយ ដើម្បីលើក ទឹកចិត្ត ឱ្យមានការចូលរួមចំណែកក្នុងការធ្វើឱ្យប្រព័ន្ធអ៊ីនធឺណិតកាន់តែល្អប្រសើរ និងមានសុវត្ថិភាព។ យុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២២ ប្រារព្ធឡើងក្រោមប្រធានបទ៖ **«រួមគ្នាលើកកម្ពស់ ការពារ និងគោរពសិទ្ធិកុមារ តាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយការទទួលខុសត្រូវ»**។

សូមរំលឹកផងដែរថា យុទ្ធនាការសុវត្ថិភាពអ៊ីនធឺណិត ត្រូវបានប្រារព្ធឡើងដំបូងបំផុតនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៤ ដោយប្រទេសចំនួន១៤ (១៣ប្រទេសនៅអឺរ៉ុប និងប្រទេសអូស្ត្រាលី) តាមរយៈការសម្របសម្រួលពីបណ្តាញអង្គការជាដៃគូរបស់បណ្តាញសាលារៀននៅសហភាពអឺរ៉ុប (EUN Partnership) ក្នុងនាមគណៈកម្មាការអឺរ៉ុប និងភាពជាដៃគូរួមគ្នារវាងមូលនិធិ INSAFE និង INHOPE របស់មជ្ឈមណ្ឌលសុវត្ថិភាពអ៊ីនធឺណិតនៃសភាពអឺរ៉ុប។ យុទ្ធនាការនេះបានពង្រីកវិសាលភាពរបស់ខ្លួននៅសហភាពអ៊ឺរ៉ុប ដោយមានការចូលរួមយ៉ាងសកម្មពីសំណាក់បណ្តាញជាសកល នៃគណៈកម្មាធិការទិវាសុវត្ថិភាព អ៊ីន ធឺណិតនៅតាមបណ្តាប្រទេសនានា។ យុទ្ធនាការនេះទទួលការគាំទ្រកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ហើយរហូតមកទល់បច្ចុប្បន្ន ទិវានេះបានក្លាយជាព្រឹត្តិការណ៍សកលដ៏សំខាន់មួយ ដែលមានប្រទេស និងដែនដីប្រមាណជា២០០នៅទូទាំងពិភពលោកបានចូលរួមប្រារព្ធអបអរសាទរជារៀងរាល់ឆ្នាំ ដោយមានការចូលរួម ពីមន្ត្រី រាជរដ្ឋាភិបាល អាជ្ញាធរ សិស្សានុសិស្ស គ្រូបង្រៀន តំណាងវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល ឪពុកម្តាយ និងជាពិសេសកុមារ និងយុវវ័យរាប់លាននាក់។

ដោយឡែកនៅប្រទេសកម្ពុជា យុទ្ធនាការសុវត្ថិភាពអ៊ីនធឺណិត ត្រូវបានផ្តួចផ្តើមប្រារព្ធឡើងដោយអង្គការសកម្មភាពដើម្បីកុមារ (APLE) ដែលជាអង្គការ ប្រយុទ្ធប្រឆាំង អំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងជាដៃគូគាំទ្រមួយប្រចាំប្រទេសកម្ពុជា នៃគណៈកម្មាធិការរៀបចំទិវាសុវត្ថិភាពអ៊ីនធឺណិត ចាប់តាំងពីឆ្នាំ២០១៩ មកម្ល៉េះ។ ជាក់ស្តែងនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១កន្លងមកនេះ អង្គការសកម្មភាពដើម្បីកុមារ ដោយទទួលបានកិច្ចសហការយ៉ាងជិតស្និទ្ធពីគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស (គ.ជ.ប.ជ.) និង ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈការឧបត្ថម្ភថវិកាគាំទ្រដោយអង្គការយូនីសេហ្វប្រចាំកម្ពុជា និងទីភ្នាក់ងារផ្តល់ជំនួយ របស់សហរដ្ឋអាមេរិក ក៏បានរៀបចំយុទ្ធនាការនេះឡើង ដោយកំណត់ជាយុទ្ធនាការគាំទ្រ **«ទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងលើកកម្ពស់សីលធម៌ ដើម្បីសុវត្ថិភាពសង្គម»** ក្រោមប្រធានបទ៖ **«រួមគ្នាធ្វើឱ្យអ៊ីនធឺណិតកាន់តែមានសុវត្ថិភាពសម្រាប់កុមារ»** ជាមួយកុមារ យុវជន លោកគ្រូអ្នកគ្រូ បុគ្គលិកអង្គការ មិនមែន រដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាល។ ជាងនេះទៅទៀត យុទ្ធនាការជាស៊េរីផ្សេងទៀតក៏ត្រូវបានរៀបចំឡើងចាប់តាំងពីថ្ងៃទី០៣ រហូតដល់ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ ដែលជាយុទ្ធនាការធំចុងក្រោយ។ ជាលទ្ធផល អ្នកចូលរួមសរុបក្នុងយុទ្ធនាការនៅឆ្នាំ២០២១ មានប្រមាណ ៧៤០នាក់ (ស្រី៣៩២នាក់)។

លោក ខឹម វ៉ាន់ដូ ប្រធានបច្ចេកទេសផ្នែកកិច្ចការពារកុមារនៃអង្គការសកម្មភាពដើម្បីកុមារមានប្រសាសន៍ថា ការចូលរួមប្រារព្ធទិវាសុវត្ថិភាពអ៊ីនធឺណិតនេះ បានសំដែង នូវការប្តេជ្ញាចិត្តដ៏មុះមុតរបស់ភាគីពាក់ព័ន្ធទាំងអស់ក្នុងការការពារកុមារពីគ្រប់ទម្រង់ទាំងអស់នៃការរំលោភបំពាន រួមទាំងការរំលោភបំពានតាមប្រព័ន្ធអនឡាញ និងបានក្លាយជាចំណែកដ៏ធំមួយនៃការផ្លាស់ប្តូរវេវិយាបទ និងការជម្រុញលើកទឹកចិត្តឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាអ៊ីនធឺណិតប្រកបដោយការទទួលខុសត្រូវ ការគោរព ការចេះគិតពិចារណា និងភាពច្នៃប្រឌិត ទិវានេះនឹងក្លាយទៅជាទិវាជាតិមួយដែលត្រូវប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំផងដែរ៕

# អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋ
# ដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/02/24/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង១១និង៤០នាទី នាថ្ងៃព្រហស្បតិ៍ ៨រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុ៊ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០២នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន២៧នាក់ (ស្រី១១នាក់ ក្មេង០៣នាក់ ក្មេងស្រី០២នាក់)។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីត្រួតពិនិត្យសម្ភារៈ ហាមឃាត់ (ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក) រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺអវិជ្ជមាន បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនចំនួន២២នាក់ ស្រី០៨នាក់ ក្មេង០៣នាក់ ក្មេងស្រី០២នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ) ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្ដែនអត់ចេញ ចំនួន០៥នាក់ ស្រី០៣នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្ងា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

# ជនជាតិថៃរហូតដល់ ១២០០ នាក់ ត្រូវបានជួយសង្គ្រោះពីក្រុមឆបោកតាមទូរស័ព្ទនៅកម្ពុជា

https://www.khmertimeskh.com/ Khmer Times February 25, 2022

អ្នកនាំពាក្យក្រសួង លោក Tanee Sangrat បានមានប្រសាសន៍ថា ក្រសួងការបរទេសបានជួយសង្គ្រោះជនជាតិថៃយ៉ាងតិច ១,២០០នាក់ ដែលត្រូវបានគេបញ្ឆោះបញ្ចូលឱ្យធ្វើការដោយខុសច្បាប់នៅកម្ពុជា។ តាំងពីឆ្នាំមុនមក ស្ថានទូតថៃនៅភ្នំពេញបានទទួលសារស្វែងរកជំនួយពីជនជាតិថៃប្រមាណ ១,៥០០ នាក់ ដែលត្រូវបានគេបោកបញ្ឆោតអោយចូលធ្វើការដោយខុសច្បាប់ដោយក្រុមឆបោកតាមទូរស័ព្ទ (Call Center gangs) នៅកម្ពុជា។ រហូតមកដល់ពេលនេះ មនុស្ស១,២០០នាក់ត្រូវបានជួយសង្គ្រោះ និងបញ្ជូនត្រឡប់ទៅប្រទេសថៃវិញហើយ ។ ពួកគេភាគច្រើនជាយុវជនក្រោមសម្ពាធក្នុងការស្វែងរកការងារ ចំពេលមានសេដ្ឋកិច្ចធ្លាក់ចុះដែលបណ្តាលមកពីជំងឺរាតត្បាត។

លោក Tanee បានមានប្រសាសន៍ថា ស្ថានទូតនៅតែទទួលបានសារជូនដំណឹងរបស់បុគ្គលិកអំពីករណីផ្សេងទៀត។ យោងតាមជនរងគ្រោះ ពួកគេបានឃើញការផ្សាយរកការងារនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលសន្យាថានឹងផ្តល់ប្រាក់ឈ្នួលខ្ពស់។ ក្រោយពីបានដាក់ពាក្យធ្វើការក្នុងមុខតំណែងរួចហើយ ពួកគេត្រូវបានរៀបចំឱ្យ

ឆ្លងដែនខុសច្បាប់ចូលប្រទេសកម្ពុជា ដោយនាំយកទៅកន្លែងធ្វើការ។ នៅក្នុងតួនាទីថ្មីរបស់ពួកគេ មនុស្សជាច្រើនត្រូវបានគេដាក់ឱ្យធ្វើការជាអ្នកគ្រប់គ្រងគេហទំព័រ និងប្រតិបត្តិករទូរស័ព្ទដែលហៅទៅមនុស្សនៅក្នុងប្រទេសថៃក្នុងគោលបំណងបោកប្រាស់ពួកគេដើម្បីផ្ទេរប្រាក់ទៅកាន់គណនីធនាគាររបស់ក្រុមធបោក។ អ្នកខ្លះក៏បានធ្វើការដើម្បីបញ្ចុះបញ្ចូលមនុស្សឱ្យចូលរួមក្នុងសកម្មភាពលេងល្បែងអនឡាញផងដែរ។

ប្រសិនបើបុគ្គលិកមិនបានបំពេញការងារបានល្អ ពួកគេនឹងត្រូវផ្លាស់ទៅផ្នែកក្រុមឧក្រិដ្ឋជនផ្សេងទៀត។ បើសិនជាគេចាប់បានអ្នកព្យាយាមរត់គេច ពួកគេនឹងត្រូវគេគំរាមកំហែង ហើយត្រូវសងបំណុលគេទាំងអស់ ដែលពួកគេបានជំពាក់ក្រុមឧក្រិដ្ឋជនដែលនាំពួកគេមកធ្វើការនៅកម្ពុជា។ ស្ថានទូតបានទាក់ទងនគរបាលកម្ពុជាដែលជួយសង្គ្រោះជនជាតិថៃពីក្រុមជនពាលទាំងនោះ។ លោក Tanee បានកើនរំលឹកប្រជាជនឲ្យប្រុងប្រយ័ត្នចំពោះការផ្សាយពាណិជ្ជកម្មការងារដែលមានការសន្យាផ្តល់ប្រាក់ខែខ្ពស់ខុសប្រក្រតី។ ប្រភព: Bangkokpost

## មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ ណែនាំដល់ពលទាហាន បន្តទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ នៅតាមបន្ទាត់ព្រំដែន

https://news.btv.com.kh/ 02/25/2022 02:02 PM

បន្ទាយមានជ័យ៖ មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ បានណែនាំដល់ពលទាហាន ត្រូវបំពេញបេសកកម្មប្រតិបត្តិការសហការជាមួយកងកម្លាំងចម្រុះ ទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រ ខេត្តបន្ទាយមានជ័យ។

លោកឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ បានណែនាំបែបនេះ ក្នុងឱកាសទស្សនកិច្ចសិក្សា ការងារកសាងពង្រឹងអង្គភាពរឹងមាំលើគ្រប់វិស័យ អង្គភាពវរសេនាតូចថ្មើរជើងលេខ៥១១ ដែលកំពុងឈរជើងនៅភូមិកណ្តោល ឃុំអូរស្រឡៅ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ជិតបន្ទាត់ព្រំដែនកម្ពុជា-ថៃ នៅថ្ងៃទី២៥ ខែកុម្ភៈនេះ ។ ក្នុងនោះ ក៏មានការចូលរួមពីអាជ្ញាធរស្រុក កងរាជអាវុធហត្ថស្រុក អធិការនគរបាលស្រុក ប្រធានទំនាក់ទំនងព្រំដែនកម្ពុជាថៃ ច្រកម៉ាឡៃ នគរបាលព្រំដែនគោកលេខ៨១៥ តំបន់ប្រតិបត្តិការសឹករងស្រុកម៉ាឡៃ និងមេបញ្ជាការវរសេនាតូចថ្មើរជើងលេខ៥១២ ៥១៣ ៥១៤ នាយការិយាល័យទាំង៩ កងអនុសេនាធំចំណុះកងពល។ ជាមួយគ្នាឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ បានថ្លែងកោតសរសើរដល់អង្គភាពវរសេនាតូចថ្មើរជើងលេខ៥១១ ខិតខំយកចិត្តទុកដាក់អនុវត្តតាមផែនការដែលថ្នាក់លើប្រគល់ជូន និងអនុវត្តន៍តួនាទីភារកិច្ច ប្រកបដោយការទទួលខុសត្រូវខ្ពស់ តាមផែនការ កសាងអង្គភាពរឹងមាំលើគ្រប់វិស័យ។

ឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ បានដាក់ផែនការឱ្យបន្តខិតខំការងារកសាងហេដ្ឋារចនាសម្ព័ន្ធបង្កបង្កើនផល និងចិញ្ចឹមសត្វ បន្ថែមលើគោលរបបហូបប្រចាំថ្ងៃ សម្រាប់កម្លាំងជួរមុខ និងកម្លាំងត្រៀមក្នុងទីតាំង ក៏ដូចជាគ្រួសារយោធិនក្នុងអង្គភាព និងមួយចំនួនលើសតម្រូវការ លក់ទៅទីផ្សារ សន្សំថវិកាកសាងក្នុងអង្គភាពនីមួយៗ រួមជាមួយបន្តអនុវត្តន៍ វិធានការ៣កុំ ៣ការពារ និង វិធានការសុខាភិបាល៕

## កម្ពុជាស្នើថៃបន្តផ្លាស់ប្តូរព័ត៌មាន ដើម្បីទប់ស្កាត់បទល្មើសឆ្លងដែន ទាន់ពេលវេលា

https://www.kampucheathmey.com/ ថ្ងៃសុក្រ ២៥ កុម្ភៈ ២០២២ដោយ KC Virak

នាយឧត្តមសេនីយ៍ កែវ វណ្ណថន អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានស្នើភាគីថៃបន្តផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក សំដៅទប់ស្កាត់ និងបង្ក្រាបទាន់ពេលវេលា រាល់បទល្មើសឆ្លងដែនគ្រប់ប្រភេទ។ នាយឧត្តមសេនីយ៍ កែវ វណ្ណថន បានមានប្រសាសន៍ថា ការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមកបានទាន់ពេលវេលាក៏អាចឈានដល់ការបង្ក្រាប និងឃាត់ខ្លួនបណ្តាញមេខ្យល់ដែលលួចលាក់នាំជនបរទេសឆ្លងដែនខុសច្បាប់ពីប្រទេសមួយ

ទៅប្រទេសមួយផងដែរ។ ការស្នើសុំនេះបានធ្វើឡើងនៅក្នុងជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោកវរសេនីយ៍ឯក Surasak សេនានុព័ន្ធនគរបាលប្រចាំស្ថានទូតថៃ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២។ នៅក្នុងជំនួបនោះ លោកវរសេនីយ៍ឯក Surasak បានសម្តែងនូវការអរគុណយ៉ាងជ្រាលជ្រៅចំពោះអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដែលកន្លងមកបានផ្តល់កិច្ចសហការយ៉ាងល្អក្នុងការជួយសង្គ្រោះជនជាតិថៃដែលរងគ្រោះ និងសម្រួលបែបបទ នីតិវិធីក្នុងការបញ្ជូនត្រឡប់ទៅប្រទេសថៃវិញប្រកបដោយសុវត្ថិភាព។ លោកបានបញ្ជាក់អំពីជំហររបស់សេនានុព័ន្ធ នគរបាលប្រចាំស្ថានទូតថៃ ចំពោះការផ្តល់នូវកិច្ចសហប្រតិបត្តិការតាមគ្រប់រូបភាពជាមួយអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នាពេលខាងមុខ។

ឆ្លើយតបនឹងការលើកឡើងខាងលើ នាយឧត្តមសេនីយ៍ កែវ វណ្ណថន បានស្វាគមន៍ចំពោះការបន្តពង្រឹងកិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរ និងស្នើភាគីថៃបន្តផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក សំដៅទប់ស្កាត់និងបង្ក្រាបទាន់ពេលវេលារាល់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេសឈានដល់ការបង្ក្រាប និងឃាត់ខ្លួនបណ្តាញមេខ្យល់ដែលលួចលាក់នាំជនបរទេសឆ្លងដែនខុសច្បាប់ពីប្រទេសមួយទៅប្រទេសមួយ។ ក្នុងជំនួបខាងលើ ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះលទ្ធផលកិច្ចសហប្រតិបត្តិការនាពេលកន្លងមករវាង អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងស្ថានទូតថៃ លើការងារអនុវត្តច្បាប់ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សានូវសន្តិសុខសណ្តាប់ធ្នាប់នៃប្រទេសទាំងពីរ ជាពិសេសការពារនូវផលប្រយោជន៍របស់ប្រជាជននៃប្រទេសទាំងពីរ។

យោងតាមរបាយការណ៍របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ បានឱ្យដឹងថា ក្នុងឆ្នាំ ២០២១កន្លងទៅនេះ បានរៀបចំតាមនីតិវិធីបណ្តេញចេញជនបរទេសល្មើសច្បាប់ពីកម្ពុជាមានចំនួន ៣ ៥៩៤ នាក់ មាន ៤៣សញ្ជាតិដែលក្នុងនោះមានជនជាតិថៃចំនួនច្រើនជាងគេគឺ ២ ៨៩៩ នាក់ បន្ទាប់មកជនជាតិចិនមានចំនួន ២៦៦ នាក់ វៀតណាម ១៩៤នាក់ នីហ្សេរីយ៉ា ១០១នាក់ ឥណ្ឌូនេស៊ី ១៩នាក់ ហ្វីលីពីន ១៦នាក់ ម៉ាឡេស៊ី ៧នាក់ និង ៣៦ សញ្ជាតិទៀតមានចាប់តាំងពីម្នាក់ហូតដល់ទៅចំនួន៦នាក់។ បើគិតចាប់ពីបង្កើតអគ្គនាយកដ្ឋានអន្តោប្រវេសន៍ក្នុងឆ្នាំ២០១៤ មកហូតដល់ដំណាច់ខែធ្នូ ឆ្នាំ២០២១នេះ កម្ពុជាបានបណ្តេញចេញជនបរទេសខុសច្បាប់ចំនួន ២០ ៨២៤ នាក់ មានចំនួន ១០៧សញ្ជាតិ៕ អត្ថបទ៖ សំអឿន

## ទំហំថវិកា ៣ពាន់លានដុល្លារ បានហូរចូលកម្ពុជា តាមរយៈពលករខ្មែរ ក្នុង១ឆ្នាំៗ

https://www.kampucheathmey.com/ ថ្ងៃសុក្រ ២៥ កុម្ភៈ ២០២២ដោយ Sophal Tuon

ពលករខ្មែរជាង ១លាននាក់ បាននិងកំពុងបម្រើការងារតាមវិស័យផ្សេងគ្នា នៅក្រៅប្រទេស។ ក្នុង១ឆ្នាំៗ ពួកគេបានផ្ញើថវិកា ជូនគ្រួសារនៅកម្ពុជា រាប់ពាន់ដុល្លារ ក្នុងម្នាក់ ដើម្បីសម្រួលជីវភាពសាច់ញាតិដែលរស់នៅស្រុកខ្មែរ។ ជាក់ស្តែង នៅឆ្នាំ ២០២១ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប៉ាន់ស្មានពីប្រាក់បញ្ញើដែលពលករ បានផ្ញើជូនក្រុមគ្រួសារក្នុង១ឆ្នាំៗ ប្រហែល ៣ពាន់លានដុល្លារអាមេរិក។ តាមរយៈរបាយការណ៍បូកសរុបការងាររបស់ក្រសួងការងារ នៅថ្ងៃទី ២៥ ខែកុម្ភៈ បានបង្ហាញថា ចំណូលរបស់ពលករខ្មែរនេះ បានរួមចំណែកជំរុញដល់កំណើនសេដ្ឋកិច្ចជាតិ ហើយជីវភាពរស់នៅរបស់ក្រុមគ្រួសារពលករ ក៏កាន់តែប្រសើរឡើង។ លើសពីនេះទៀត របាយការណ៍ដដែល បានឲ្យដឹងថា ទំហំថវិកាដែលហូរចូលនេះ បានបន្តជំរុញការអនុវត្តគោលនយោបាយ ស្តីពីទេសន្តរប្រវេសន៍ការងារ សម្រាប់ប្រទេសកម្ពុជា ឆ្នាំ ២០១៩-២០២៣ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្នុងការការពារ លើកកម្ពស់សិទ្ធិ និងផលប្រយោជន៍បងប្អូនពលករទាំងការទទួលបានកិច្ចគាំពារសង្គម ក្នុងពេលបម្រើការងារ និងពេលត្រឡប់មកស្រុកកំណើតវិញ។ សូមបញ្ជាក់ថា បច្ចុប្បន្ននេះ មានពលករខ្មែរ កំពុងបម្រើការងារនៅក្រៅប្រទេសសរុបចំនួន ១ ៣០១ ៦០៩នាក់ ក្នុងនោះ ប្រទេសថៃមានចំនួន ១ ២២០ ១៩៧នាក់ នៅកូរ៉េចំនួន ៤៥ ៨៦៦

នាក់ ម៉ាឡេស៊ី ២៣ ០២៧នាក់ ជប៉ុន ១១ ៤៥៣នាក់ សិង្ហបុរី ៨២១នាក់ ហុងកុង ២០២នាក់ និងអារ៉ាប់ប៊ីសាអូឌីត ចំនួន ៤៣នាក់។ នេះបើតាមរបាយការណ៍ក្រសួងការងារ៕ អត្ថបទ៖ ទូន សុផល

## កិច្ចប្រជុំស្តីពី វឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំឆ្នាំ២០២១ និងទិសដៅបន្តឆ្នាំ២០២២ ក្នុងបរិបទកូវីដ-១៩ របស់ គ.ខ.ប.ជ

https://form.digitalsky.com.kh/ 2022-02-25 03:32 PMអត្ថបទ៖ PK

(ស្វាយរៀង)៖ នៅល្ងាចថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ក្រោមអធិបតីភាពលោកជំទាវ ឯក សុវណ្ណភារៈ អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានអញ្ជើញជាអធិបតីក្នុង កិច្ចប្រជុំស្តីពី វឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំឆ្នាំ២០២១ និងទិសដៅបន្តឆ្នាំ២០២២ ក្នុងបរិបទកូវីដ-១៩ របស់ គ.ខ.ប .ជ ដែរពិធីនេះប្រារព្ធធ្វើឡើងក្នុងសាលាខេត្តស្វាយរៀង។ លោកជំទាវ ឯក សុវណ្ណភារៈ បានកោតសរសើរនិងវាយតម្លៃខ្ពស់ ចំពោះលោក-លោកស្រី ថ្នាក់ដឹកនាំនៃមន្ទីរអង្គភាពពាក់ព័ន្ធ ដែលជាសមាជិកនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទាំងអស់ ក៏ដូចជាអាជ្ញាធរ សមត្ថកិច្ច និងកងកម្លាំងគ្រប់ប្រភេទ ព្រមទាំងលេខការដ្ឋាន គ.ជ.ប.ជ ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត ពុះពារគ្រប់ឧបសគ្គដើម្បីធ្វើឲ្យសម្រេចកិច្ចការជាច្រើនគួរជាទីមោទនៈ ។ ទោះបីស្ថិតក្នុងស្ថានភាពនៃវិបត្តិជំងឺកូវីដ-១៩ក៏ដោយ ក៏នៅក្នុងឆ្នាំ២០២១ គណៈកម្មាធិការប្រយុទ្ធប្រឆាំងជួញដូរមនុស្សខេត្តស្វាយរៀង បានសម្រេចនូវសកម្មភាពធំៗជាច្រើនផងដែរ ។

លោកជំទាវ ឯក សុវណ្ណភារៈ បានមានប្រសាសន៍បន្តទៀតថា: កិច្ចប្រជុំនៅថ្ងៃនេះគឺជាសមិទ្ធផលមួយដែលស្តែងឲ្យឃើញនូវការយកចិត្តទុកដាក់ អនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងកិច្ចខំប្រឹងប្រែងសហការរួមគ្នា ដើម្បីការពារសន្តិសុខ និងសុវត្ថិភាពមនុស្សជាតិ អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងការរំលោភបំពានគ្រប់រូបភាព ទៅលើមនុស្សទាំងក្មេង ចាស់ បុរស ស្ត្រី និងកុមារ ។ លោកជំទាវក៏បានបន្តទៀតថា: គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺត្រូវតែបន្តធ្វើឲ្យកាន់តែសកម្ម និងជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ប្រឆាំងអំពើជួញដូរមនុស្សសម្រាប់ឆ្នាំ២០១៩-ឆ្នាំ២០២៣ ឱ្យបានសម្រេចតាមគោលដៅដែលគ្រោងទុក។ យើងត្រូវការ ការចូលរួមពីក្រសួងស្ថាប័ន ជាសមាជិកក៏ជាដៃគូអភិវឌ្ឍសង្គមស៊ីវិល និងវិស័យឯកជនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងកិច្ចសហការល្អជាមួយប្រទេសពាក់ព័ន្ធនៅក្នុងតំបន់ និងក្នុងពិភពលោក ។

លោកជំទាវ ក៏សូមអំពាវនាវដល់ភាគីប្រទេសជាមិត្តទាំងអស់ សូមមេត្តាចូលរួមសហការជួយជ្រោងជ្រែងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ ឲ្យកាន់តែខ្លាំងក្លាបន្ថែមទៀត និងសូមអំពាវនាវនិងលើកទឹកចិត្តដល់គ្រប់ក្រសួងស្ថាប័ន មន្ទីរអង្គភាព និងថ្នាក់ជាតិថ្នាក់ក្រោមជាតិ សូមពង្រឹងការអនុវត្តសកម្មភាពតាមយុទ្ធសាស្ត្រដែលបានចែងក្នុងផែនការជាតិ ឲ្យបានកាន់តែសកម្មខ្លាំងក្លាបន្ថែមទៀត និងសូមអំពាវនាវដល់គណៈកម្មការថ្នាក់ក្រោមជាតិ សូមបន្តរៀបចំយុទ្ធការ នៃទិវាជាតិ១២ធ្នូ ប្រឆាំងការជួញដូរមនុស្សនេះឲ្យបានផុសផុល សម្រាប់ជាមធ្យោបាយបំផុសការយល់ដឹងដល់ថ្នាក់ដឹកនាំអាជ្ញាធរមានសមត្ថកិច្ច វិស័យឯកជន សង្គមស៊ីវិល គ្រប់កាយនិកាយសាសនា និងភាគីពាក់ព័ន្ធទាំងអស់ អំពីអំពើជួញដូរមនុស្សឲ្យ "រួមសហការគ្នាបង្ការ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះការពារ ដើម្បីកម្ពុជា គ្មានអំពើជួញដូរមនុស្ស" ៕

## នៅថ្ងៃសៅរ៍ អាជ្ញាធរស្រុកសំពៅលូន បន្តទទួល ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/02/27/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃសៅរ៍ ១០រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុ៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី កៅ-ប៊ុណ្ណា (មេបញ្ជាការកងអនុសេនាធំ) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង សរុបចំនួន២៩នាក់ (ស្រី១០នាក់ ក្មេងស្រី០៣នាក់)។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីត្រួតពិនិត្យសម្ភារៈហាមឃាត់ (ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក)។ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍ ជាលទ្ធផល គឺវិជ្ជមានចំនួន០២នាក់ ស្រី០១នាក់។ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន១៣នាក់ ស្រី០៤នាក់ ក្មេងស្រី០២នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ) ចំណែកអ្នកមានវិជ្ជមានកូវីដ-១៩ ចំនួន០២នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលព្យាបាលកូវីដ-១៩ ស្ថិតនៅក្នុងភូមិអូរកណ្តាល ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។ ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្ទើនអត់ចេញ ចំនួន១៤នាក់ ស្រី០៥នាក់ ក្មេងស្រី០១នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្ហា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។